# ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៩
## ពិធីបើកវគ្គបណ្តុះបណ្តាលស្តីពីការធ្វើអាជីវកម្មផ្លូវភេទលើកុមារ

https://cambodiapolice.com/policekh/ 10:35 am 1 កក្កដា 2019 20

**ភ្នំពេញ ៖** ថ្ងៃចន្ទ ១៤រោច ខែជេស្ឋ ឆ្នាំកុរឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០១៩នេះ ឯកឧត្តម ឧត្តមសេនីយ៍ឯក អ៊ិន បូរ៉ា អគ្គស្នងការរងនគរបាលជាតិ ទទួលផែននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ដំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ និងលោកជំទាវ Angela Corcoran ឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីភាពក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពីការធ្វើអាជីវកម្មផ្លូវភេទលើកុមារ (CHILD SEXUAL EXPLOITATION TRAINING PROGRAM)។

សូមជម្រាបថា **វគ្គបណ្តុះបណ្តាលស្តីពីការធ្វើអាជីវកម្មផ្លូវភេទលើកុមារ ធ្វើឡើងរយៈពេល៤ថ្ងៃ ចាប់ពីថ្ងៃទី១** ដល់ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៩ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ៕

## រដ្ឋបាលខេត្តរតនគិរីប្រារព្ធយុទ្ធនាការផ្សព្វផ្សាយស្តីពីសិទ្ធិកុមារ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 29/06/2019

ខេត្តរតនគិរី ៖ នៅព្រឹកថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩នេះ រដ្ឋបាលខេត្តរតនគិរីដែលមាន មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត ជាសេនាធិការបាន សហការណ៍គ្នាជាមួយអង្គការ អេស.អូរ.អេសនិងអង្គការហ្វរ.រ៉ាម. ស៊ីបរៀបចំឲ្យមានយុទ្ធនាការការផ្សព្វផ្សាយស្តីពីសិទ្ធិកុមារ។ យុទ្ធនាការខាងលើនេះ ប្រារព្ធធ្វើឡើងនៅសាលមហោស្រពសម្តេចតេជោ ហ៊ុន សែន ស្ថិតនៅក្នុងបរិវេណមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈក្រោមអធិបតីភាពលោក ថង សាវុនអភិបាលខេត្តរតនគិរី ព្រមទាំងមានការចូលរួមជាភ្ញៀវកិត្តិយស ពីសំណាក់ លោកមេបញ្ជាការ មេបញ្ជារងកងកម្លាំងប្រដាប់អាវុធទាំងបីប្រភេទ និងលោក លោកស្រី ប្រធាន អនុប្រធានមន្ទីរជុំវិញខេត្ត អភិបាល អភិបាលរងក្រុង, ស្រុក យុវជនជន ស.ស.យ.ក យុវជនកាកបាទក្រហម យុវជនកាយរិទ្ធ ព្រមទាំងសិស្សានុសិស្ស មកពីបណ្តាសាលាក្នុងខេត្តរតនគិរី យ៉ាងច្រើនកុះករផងដែរ។

មានប្រសាសន៍ សំណេះសំណាលនាឱកាសនេះ លោក ថង សាវុន បានចាត់ទុកយុទ្ធនាការផ្សព្វផ្សាយស្តីពីសិទ្ធិកុមារ ដែលបានប្រារព្ធធ្វើឡើងនាពេលនេះគឺពិតជាមានសារៈសំខាន់សម្រាប់ក្មួយៗសិស្សានុសិស្សបានយល់កាន់តែច្បាស់អំពីសិទ្ធិរបស់ខ្លួន។ លោកបន្តថា ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ និងបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារ ស្តីពីការជួញដូរកុមារ ការធ្វើបេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ និងស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០២។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលបានដាក់បញ្ចូលគោលការណ៍នៃអនុសញ្ញាស្តីពីសិទ្ធិកុមារនៅក្នុងច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនិងកុមារជាពិសេសបានបញ្ចូលទៅក្នុងមាត្រា៤៨នៃរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃព្រះរាជណាចក្រកម្ពុជាដែលបានកំណត់ថា(រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលបាននូវការអប់រំរៀនសូត្រ សិទ្ធិទទួលបាននូវការគាំពារក្នុងស្ថានភាពមានសង្គ្រាមនិងការការពារប្រឆាំងនិងអាជីវកម្មសេដ្ឋកិច្ច ឫកាមគុណលើកុមារ។ លោកបានបញ្ជាក់ទៀតថា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេច តេជោ ហ៊ុន សែន និងជាប្រធានកិត្តិយសក្រុមប្រឹក្សាជាតិដើម្បីកុមារ កម្ពុជាបានបង្ហាញនូវឆន្ទៈ និងការអនុវត្តអនុញ្ញាស្តីពីសិទ្ធិកុមារ របស់អង្គការសហប្រជាជាតិយ៉ាងសកម្ម។ ដោយតាមរយៈការចូលរួមពីក្រសួងស្ថាប័ន អង្គការសង្គមស៊ីវិល វិស័យឯកជន គ្រួសារក្នុង

សហគមន៍ រួមនឹងអ្នកពាក់ព័ន្ធក្នុងការអនុវត្តនូវកម្មវិធីកាងារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្រជាតិគាំពារសង្គមផងដែរ។

គួរបញ្ជាក់ថា បើតាមការលើកឡើងពីលោក វ៉ា វល័ក្ខណ៍ ប្រធានភូមិកុមារ អេស អូរ អេស ខេត្តរតនគិរី បានឲ្យដឹងថាអង្គការភូមិកុមារ អេស អូរ អេស អន្តរជាតិ បានបង្កើតឡើងដោយលោក បណ្ឌិត ហ៍រមាណ ម៉ៃន័រ នៅឆ្នាំ ១៩៤៩ ហើយមានទីស្នាក់ការនៅប្រទេសអូទ្រីស។ បច្ចុប្បន្នអង្គការនេះ បានធ្វើសកម្មភាពនៅប្រទេសចំនួន ១៣៥ នៅលើសកលលោក។ លោកប្រធានភូមិកុមារអេស អូរ អេស ខេត្តរតនគិរី បានបន្តទៀតថា លោក ហីលមុត គូទីន បានធ្វើជាប្រធានអង្គការ អេស អូរ អេស អន្តរជាតិចាប់ពីឆ្នាំ១៩៨៥ ដល់ឆ្នាំ២០១២។ ប្រធានភូមិកុមារ អេស អូ អេស រូបនេះបន្តថា ក្រោមការដឹកនាំរបស់លោក ហីលមុត គូទីន អង្គការនេះ បានបន្តនិរន្តភាព របស់ខ្លួនបង្កើតបានសមិទ្ធិផលជាច្រើនពាស់ពេញពិភពលោក សម្រាប់សុខុមាលភាពកុមារ។ ទន្ទឹមនឹងនេះដែរ អង្គការ អេស អូរ អេស អន្តរជាតិ ជាអង្គការដែលមើលថែទាំកុមារកំព្រា កុមារបាត់បង់ការថែរទាំពីឪពុកម្តាយ ដោយជម្រុញ និងលើកកំពស់សិទ្ធកុមារគ្រប់រូប ឲ្យធំលូតលាស់ ដោយមានសេចក្តីស្រលាញ់ គោរព និងមានសុវត្ថិភាព ជាពិសេសត្រូវបានទទួលស្គាល់ជាអន្តរជាតិ ដែលបាននិងកំពុងសហការណ៍ជាមួយ ក្រសួងសង្គមកិច្ច អតីតៈយុទ្ធជន និងយុវនីតិសម្បទា តាំងពីឆ្នាំ១៩៩៩ មកម្លេះ ដោយសម្រេចបានសមិទ្ធផលជាច្រើន ។ យុទ្ធនាការផ្សព្វផ្សាយស្តីពីសិទ្ធកុមារនាថ្ងៃនេះដែរ បន្ទាប់ពីធ្វើកម្មវិធីនៅសាលមហោស្រពរួចមក អង្គពិធីនេះ បានដង្ហែរក្បួនផ្សព្វផ្សាយ ក្នុងក្រុងបានលុង និងដង្ហែរព័ទ្ធជុំវិញផ្សារក្រុងបានលុង ខេត្តរតនគិរីផងដែរ៕

## កម្ពុជា-ថៃ នឹងបើកកិច្ចប្រជុំលើកទី២៧ គណៈកម្មការព្រំដែននៅដើមខែនេះ លើទឹកដីថៃ

http://bayontv.com.kh/ 01/07/2019

ភ្នំពេញ ៖ កម្ពុជានិងថៃនឹងបើកកិច្ចប្រជុំគណៈកម្មាធិការព្រំដែនដែលហៅកាត់ថា (RBC) លើកទី២៧ចំនួន ៣ថ្ងៃ គឺចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៩ ខាងមុខនេះ ដើម្បីពិភាក្សាគ្នា នៅក្នុងទិសដៅតែមួយ គឺព្រំដែនដែលមាន សុខសន្តិភាព ស្ថេរភាព នឹងប្រែក្លាយព្រំដែន នៃប្រទេសទាំង២ ឲ្យមានការអភិវឌ្ឍជឿនលឿន បន្ថែមទៀត។ កិច្ចប្រជុំនេះ នឹងប្រព្រឹត្តទៅនៅទីក្រុងបាងកកប្រទេសថៃ ដោយភាគីកម្ពុជា នឹងដឹកនាំដោយ ឯកឧត្តម ឧត្តមសេនីយ៍ឯក ឯក សំអូន មេបញ្ជាការរងកងទ័ពជើងគោក មេបញ្ជាការយោធភូមិភាគទី៥ និងភាគីថៃ ដឹកនាំដោយមេភូមិភាគថៃ ដែលជាប់នឹងព្រំដែនកម្ពុជា។

យោងតាមមន្ត្រីនៃយោធភូមិភាគ៥ ថ្លែងប្រាប់ទូរទស្សន៍បីធីវី នាព្រឹកថ្ងៃទី១ ខែកក្កដា ឆ្នាំ ២០១៩នេះបានឲ្យដឹងថា កិច្ចប្រជុំក្រុមលេខាគណៈកម្មការកម្ពុជា-ថៃ (RBC) លើកទី២៧ ដែលភាគីថៃធ្វើជាម្ចាស់ផ្ទះនេះ គឺនឹងផ្តោតសំខាន់ទៅលើបញ្ហាមួយចំនួនធំដូចជា បញ្ហាប្រជាពលករធ្វើការចំណាកស្រុក បញ្ហាប្រជាពលរដ្ឋធ្វើដំណើរទៅប្រទេសថៃដើម្បីព្យាបាលជំងឺ បញ្ហាបង្ការនិងបង្ក្រាបបទល្មើសឆ្លងដែន បញ្ហាប្រជាពលរដ្ឋខ្មែរចូលឆ្លងដែនទៅកាប់ឈើនៅប្រទេសថៃ បញ្ហាអន្តោប្រវេសន៍ខុសច្បាប់ បញ្ហាការចរាចរណ៍នៅគ្រឿងញៀនបញ្ហាទប់ស្កាត់ និងបង្ក្រាបនូវភាវរកម្មឆ្លងដែនជាដើម។ ប្រភពដដែល បានបន្តទៀតថា កិច្ចប្រជុំគណៈកម្មការព្រំដែន កម្ពុជា-ថៃ (RBC) លើកទី២៧នេះ គឺនឹងលើកឡើងនូវបញ្ហាទាំងប៉ុន្មាននេះ ដើម្បីរួមគ្នាធ្វើការដោះស្រាយ សំដៅធ្វើការពង្រឹង និងពង្រីកបន្ថែមទៀត ទៅលើចំណងសម្ព័ន្ធមេត្រីភាពរវាងព្រំដែនទាំង២ (កម្ពុជា-ថៃ) នៅក្នុងទិសដៅតែមួយ គឺព្រំដែនដែលមាន សុខសន្តិភាព ស្ថេរភាព នឹងប្រែក្លាយព្រំដែន នៃប្រទេសទាំង២ ឲ្យមានការអភិវឌ្ឍជឿនលឿន បន្ថែមទៀត ដើម្បីគុណប្រយោជន៍របស់ប្រជាជននៃប្រទេសទាមងពីរ។

សូមបញ្ជាក់ថា កាលពីកិច្ចប្រជុំRBC លើកទី២៦ កម្ពុជា-ថៃដែលបានធ្វើឡើងនៅទីក្រុង ប៉ាតាយ៉ាប្រទេសថៃ កាលពីកន្លងទៅនោះភាគីទាំងពីរ បានផ្តោតលើកិច្ចសហប្រតិបត្តិការទ្វេភាគី លើវិស័យសន្តិសុខ ដែលមានទី១– ការបង្ការទប់ស្កាត់ការកើតឡើងវិវាទ ទី២– ទប់ស្កាត់បញ្ហាឧក្រិដ្ឋកម្ម និងភេរវកម្មឆ្លងដែន ទី៣– ការពារបង្ក្រាបទប់ស្កាត់គ្រឿងញៀនឆ្លងដែន ទី៤– បង្ក្រាបបទល្មើសតាមព្រំដែន ទី៥– ការឆ្លងកាត់តាមព្រំដែន ទី៦– ទប់ស្កាត់ការជួញដូរមនុស្ស និងក្មេងអនាថា និងទី៧ – ពលករខុសច្បាប់ជាដើម ហើយតាមរយៈកិច្ចប្រជុំភាគីទាំងពីរបាន ស្វែងរកដំណោះស្រាយបង្ការនិងទប់ស្កាត់រួមគ្នា ដើម្បីផលប្រយោជន៍ប្រជាជននិងប្រទេស ទាំងពីរ៕

## របាយការណ៍៖ ពលករចំណាកស្រុកខ្មែរនៅថៃបានជួយសេដ្ឋកិច្ចប្រទេសទាំងពីរយ៉ាងសម្បើម

https://www.rfa.org/khmer/ ដោយ ជី រិតា 2019-06-29

របាយការណ៍ស្រាវជ្រាវរបស់អង្គការទេសន្តប្រវេសក៍អន្តរជាតិ ហៅកាត់ថា អាយអូអិម (IOM) សហការជាមួយមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវអាស៊ីផ្នែកជនចំណាកស្រុក នៃសកលវិទ្យាល័យជូឡាឡុងកន (Chulalongkorn) បង្ហាញថា ពលករខ្មែរចំណាកស្រុកនៅប្រទេសថៃ បានជួយលើកស្ទួយសេដ្ឋកិច្ចកម្ពុជា និងថៃ យ៉ាងសម្បើម។ របាយការណ៍ក៏បង្ហាញដែរថា ក្នុងចំណោមពលករខ្មែរស្របច្បាប់ចំនួនជាង ៦សែននាក់ (៦៥០០០០) បានបញ្ជូនកូនៗរបស់ពួកគេតិចតួចណាស់ដែលបានទៅសាលារៀន។ ការស្រាវជ្រាវរបស់អង្គការអាយអូអិម (IOM) សហការជាមួយសកលវិទ្យាល័យជុឡាឡុងកន(Chulalongkorn) បង្ហាញថា ចំនួនមធ្យមនៃទឹកប្រាក់ដែលពលករខ្មែរម្នាក់ៗផ្ញើទៅឱ្យសាច់ញាតិនៅឯស្រុកកំណើត គឺ ១.២២៨ ក្នុងមួយឆ្នាំៗ។ ក្នុងចំណោមពលករខ្មែរជាងប្រាំបួនរយនាក់ (៩០០) នាក់ ពីខេត្តចំនួនប្រាំមួយ (៦) ក្នុងប្រទេសថៃ ដែលត្រូវបានសាកសួរដោយក្រុមស្រាវជ្រាវធ្វើឡើងពីចន្លោះខែកញ្ញាដល់ខែវិច្ឆិកា ឆ្នាំ២០១៨ និយាយថា លុយចំនួននេះ មានសារសំខាន់ខ្លាំងណាស់សម្រាប់ពួកគេ ព្រោះវាបានជួយឱ្យជីវភាពគ្រួសាររបស់ខ្លួននៅឯស្រុកប្រសើរឡើង។ លទ្ធផលនៃការស្រាវជ្រាវនេះត្រូវបានដាក់បង្ហាញក្នុងសន្និសីទសារព័ត៌មានមួយនៅក្លិបអ្នកការសែតបរទេស (FCC) នៅទីក្រុងបាងកក នៅព្រឹកថ្ងៃសុក្រ ទី២៨ មិថុនា។

ទោះជាយ៉ាងណា ពលករខ្មែរនៅប្រទេសថៃ មានបញ្ហាប្រឈមមួយចំនួន ក្នុងនោះរួមមាន ភាគច្រើននៃកូនៗរបស់ពួកគេមិនបានទៅសាលារៀន ជាពិសេសកូនៗរបស់កម្មករសំណង់ ដោយសារត្រូវផ្លាស់ប្តូរកន្លែងធ្វើការញឹកញាប់ និងដោយសារកង្វះព័ត៌មាន។ ច្បាប់ថៃអនុញ្ញាតឱ្យកូនៗរបស់ពលករចំណាកស្រុកទាំងអស់ មិនថាជាជនជាតិណាទេ អាចចូលរៀនសាលាថៃបាននៅតំបន់ដែលឪពុកម្តាយរបស់ក្មេងៗធ្វើការ។

សាស្ត្រាចារ្យសកលវិទ្យាល័យ ជូឡាឡុងកន (Chulalongkorn) អ្នកស្រីព្រឹមចៃ វុងសិរិភិសាន (Premjai Vungsiriphisal) មានប្រសាសន៍ថា បច្ចុប្បន្នមានកុមារៗសរុបប្រមាណប្រាំបួនម៉ឺន (៩០.០០០នាក់ ដែលជាកូនៗរបស់ពលករចំណាកស្រុកមកពីប្រទេសមីយ៉ាន់ម៉ា ឬភូមា កម្ពុជា និងឡាវ កំពុងរៀននៅក្នុងសាលាថៃក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។ ទោះជាយ៉ាងណា អ្នកស្រីមិនដឹងថា ចំនួនកូនៗពលករខ្មែរមានប៉ុន្មាននោះទេដែលបានចូលរៀន ប៉ុន្តែអ្នកស្រីដឹងថា មានតិចតួចប៉ុណ្ណោះ បើប្រៀបធៀបទៅកូនៗរបស់ពលករជនជាតិភូមា។ អ្នកស្រីថា នៅប្រទេសថៃ មានអង្គការក្រៅរដ្ឋាភិបាលភូមាជាច្រើនធ្វើសកម្មភាពជួយដល់ពលករចំណាកស្រុកភូមា ជាពិសេសបានបង្កើតមណ្ឌលសិក្សាក្រៅប្រព័ន្ធជាច្រើនកន្លែងឱ្យកូនៗរបស់ពលករភូមាអាចរៀនសូត្របាន។ អ្នកស្រីថា សម្រាប់ពលករខ្មែរ នៅមិនទាន់មានអង្គការក្រៅរដ្ឋាភិបាលខ្មែរធ្វើបែបនៅឡើយទេ។ ទោះយ៉ាងណាក្តីអ្នកស្រីថា ឪពុកម្តាយពលករខ្មែរគួរទៅសុំចុះឈ្មោះកូនៗនៅសាលារៀនតាមមូលដ្ឋាននីមួយៗដែលពួកគេរស់នៅ។

ចំណែកស្ថានទូតកម្ពុជានៅទីក្រុងបាងកកវិញ អ្នកស្រីថា គួរជួយពលរដ្ឋខ្លួនឱ្យទទួលបានព័ត៌មានចាំបាច់នានា ដើម្បីឱ្យកូនៗរបស់ពួកគេចូលរៀនសាលាថៃបាន ព្រោះថា ការសិក្សាសំខាន់ណាស់សម្រាប់ក្មេង៖ «ស្ថានទូត

គួរតែជួយសម្រួលដល់ដំណើរនៃការធ្វើចំណាកស្រុករបស់ពលករ ឱ្យមានសុវត្ថិភាព មានថ្លៃចំណាយទាប និងឆាប់រហ័សជាងមុន ដើម្បីឱ្យអ្នកដែលចង់ចំណាកស្រុកមកធ្វើការនៅប្រទេសថៃមិនសូវជួបការលំបាក។ ហើយបើពួកគេយកកូនមកជាមួយ ស្ថានទូតគួរត្រួតពិនិត្យសុខុមាលភាពរបស់ពួកគេ ជាពិសេសការសិក្សារៀនសូត្ររបស់ក្មេង ធានាថាកូនក្មេងទាំងនោះទទួលបានការអប់រំ។ ពេលខ្ញុំនិយាយពីការអប់រំ មិនមែនមានន័យថា យើងត្រូវតែបញ្ជូនពួកគេទៅសាលាទេ គឺយើងអាចផ្តល់ការអប់រំណាដែលសមស្របទៅនឹងតម្រូវការរបស់ពួកគេ»។

ទាក់ទងនឹងការធានារ៉ាប់រងសុខភាពរបស់ពលករខ្មែរវិញ សាស្ត្រាចារ្យ ព្រឹមថៃ វុងសិរិភិសាន (Premjai Vungsiriphisal) មានប្រសាសន៍ថា ច្បាប់ថៃ តម្រូវឱ្យថៅកែក្រុមហ៊ុននីមួយៗនៅក្នុងប្រទេសថៃ ផ្តល់ការធានារ៉ាប់រងផ្នែកសុខភាពដល់ពលករ មានន័យថា យ៉ាងហោចណាស់ ពួកគេអាចទទួលបានការការពារក្នុងកម្រិតណាមួយលះ «ប៉ុន្តែបើសិនជាពួកគេមិនទទួលបានការធានារ៉ាប់រងសុខភាពទេ នៅពេលពួកគេឈឺ ពួកគេទៅមន្ទីរពេទ្យ ពួកគេអាចនឹងត្រូវគេតម្រូវឱ្យបង់ថ្លៃសេវាព្យាបាលដោយខ្លួនឯង។ ទោះជាយ៉ាងណា បើមិនមានលទ្ធភាពបង់ថ្លៃសេវាក៏ដោយ ក៏ពួកគេនៅតែអាចទទួលបានការព្យាបាលដែរ។ ក៏ប៉ុន្តែជាធម្មតា បើមិនមានធានារ៉ាប់រងសុខភាពទេ ពួកគេនឹងត្រូវតម្រូវឱ្យបង់ថ្លៃព្យាបាលសិន មុននឹងទទួលបានការព្យាបាល។ អង្គការក្រៅរដ្ឋាភិបាលកំពុងព្យាយាមណែនាំនូវសេវាធានារ៉ាប់រងប្រភេទផ្សេងៗ ដែលមានតម្លៃថោក តែនៅតែអាចឱ្យយើងទទួលបានសេវាសុខភាព។ ប៉ុន្តែវាអាស្រ័យលើពលករខ្លួនឯង ថាតើពួកគេយល់ដឹងពីសារសំខាន់នៃសេវាធានារ៉ាប់រងឬទេ ព្រោះថា ពួកគេខ្លះមិនចង់ចំណាយបន្ថែមពីលើថ្លៃចុះបញ្ជីនោះទេ។ តាមការពិត សេវាធានារ៉ាប់រង មានប្រយោជន៍សម្រាប់ពួកគេទេតើ។ ដូច្នេះខ្ញុំយល់ថា ការយល់ដឹងរបស់ពលករក៏សំខាន់ដែរ»។

របាយការណ៍ ៧០ទំព័ររបស់អង្គការអាយអូអិម (IOM) សហការជាមួយសកលវិទ្យាល័យជុឡាឡុងកន នៅទីក្រុងបាងកក ស្នើឱ្យរដ្ឋាភិបាលថៃ ធានាដល់ពលករចំណាកស្រុកនូវប្រាក់ខែគោលដែលកំណត់ក្នុងច្បាប់ថៃ។ ត្រូវធានាដល់ពលករចំណាកស្រុកទាំងអស់នូវការធានារ៉ាប់រងសុខភាព និងការធានាថ្លៃចំណាយលើគ្រោះថ្នាក់នៅកន្លែងធ្វើការ។ សំរាប់ការជួយដល់ពលករចំណាកស្រុកខ្មែរវិញ របាយការណ៍ស្នើឱ្យរដ្ឋាភិបាលកម្ពុជា ហ្វឹកហ្វឺនបង្រៀនពលករខ្លួនដែលត្រៀមចាកចេញពីកម្ពុជានូវការយល់ដឹងចាំបាច់នានា រួមទាំងការចុះឈ្មោះកូនចូលរៀននៅប្រទេសថៃ។ បង្កើតមូលនិធិខ្ចីប្រាក់សម្រាប់ពលករដើម្បីកុំឱ្យពលករទៅខ្ចីបុលពួកឈ្មួញដែលយកការប្រាក់ខ្ពស់។ សហការជាមួយស្ថាប័នហិរញ្ញវត្ថុដែលយកថ្លៃសេវាផ្ញើប្រាក់ទៅផ្ទះ សមរម្យ។ របាយការណ៍ក៏ស្នើឱ្យរដ្ឋាភិបាលកម្ពុជា បង្កើតមជ្ឈមណ្ឌលហ្វឹកហ្វឺនដល់ពលករដែលធ្វើមាតុភូមនិវត្តន៍មករស់នៅកម្ពុជាវិញ ដើម្បីសម្រួលឱ្យពួកគេអាចបង្កើតមុខរបរ ឬប្រើប្រាស់ជំនាញរបស់ពួកគេដែលទទួលបានមកពីប្រទេសថៃ ឱ្យមានប្រសិទ្ធភាពក្នុងកម្រិតខ្ពស់៕

## IOM: **ពលករខ្មែរនៅថៃ បានប្រាក់ឈ្នួលតិចជាងប្រាក់ឈ្នួលអប្បបរមា**

https://www.postkhmer.com/ វី សុចាន់ | Publication date 01 July 2019 | 09:29 ICT

**ភ្នំពេញៈ** អង្គការទេសន្តរប្រវេសន៍អន្តរជាតិ IOM និងមជ្ឈមណ្ឌលស្រាវជ្រាវទេសន្តរប្រវេសន៍អាស៊ីនៅសាកលវិទ្យាល័យជូឡាឡុងកន ប្រទេស ថៃ (ARCM) បានរកឃើញថា ពលករកម្ពុជាដែលធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេស ថៃ ភាគច្រើនគឺក្រីក្រ ហើយទៅធ្វើការពឹងផ្អែកលើកម្លាំងពលកម្មដោយទទួលបានប្រាក់ឈ្នួលតិចជាងប្រាក់ឈ្នួលអប្បបរមារបស់ខេត្តថៃដែលពួកគេធ្វើការ។

សេចក្តីប្រកាសព័ត៌មានរបស់ IOM ដែលភ្នំពេញប៉ុស្តិ៍ទទួលបានកាលពីម្សិលមិញបញ្ជាក់ថាៈ «ការវាយតម្លៃពីការផ្លាស់ប្តូរដ៏មានសក្តានុពល ទៅលើលក្ខណៈការធ្វើចំណាកស្រុករបស់ពលករកម្ពុជា និងផលប៉ះពាល់របស់ពួកគេទៅលើប្រទេស ថៃ និងកម្ពុជា» បានអង្កេតពីស្ថានភាពប្រជាជនកម្ពុជា ប្រមាណ ៦៥ ម៉ឺននាក់ ដែលធ្វើការនៅប្រទេស ថៃ គឺស្ថិតក្នុងចំណោមការសិក្សាស្រាវជ្រាវនេះ»។ ការសិក្សានេះបានធ្វើការស្ទង់មតិកម្មករចំណាកស្រុកកម្ពុជាជាង ៩០០ នាក់ នៅក្នុងខេត្តថៃចំនួន ៦ ហើយបានសម្ភាសអ្នកពាក់ព័ន្ធសំខាន់ៗប្រមាណ ១២២ នាក់ រួមមានមន្ត្រីរដ្ឋាភិ

បាលនិយោជិត និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ដោយប្រើប្រាស់វិធីសាស្ត្របរិមាណ និងគុណភាព។ សេចក្តីប្រកាសព័ត៌មាន បន្តថា ពលករចំណាកស្រុកកម្ពុជាភាគច្រើន នៅក្នុងប្រទេសថៃមានភាពក្រីក្រ មុនពេលពួកគេធ្វើចំណាកស្រុកនិងជ្រើសរើសចាកចេញពីប្រទេសកម្ពុជាដោយសារតែមានឱកាសការងារល្អប្រសើរ និងមានប្រាក់ខែខ្ពស់នៅពេលឆ្លងកាត់ព្រំដែន។ ឥឡូវនេះ ពលករចំណាកស្រុកភាគច្រើនធ្វើការនៅក្នុងវិស័យសេដ្ឋកិច្ច ដែលពឹងផ្អែកលើកម្លាំងពលកម្មដែលមានប្រាក់ឈ្នួលទាបរួមមានវិស័យកសិកម្ម សំណង់ នេសាទ និងផលិតកម្ម។ សេចក្តីប្រកាសព័ត៌មានបន្តថា ខណៈដែល ៩៧ ភាគរយ នៃពលករកម្ពុជា បានរាយការណ៍ថា លក្ខខណ្ឌការងាររបស់ពួកគេគឺ «ល្អ» ឬ «ពេញចិត្ត» ការសិក្សាបានរកឃើញថា ១ ភាគ ៣ នៃអ្នកដែលត្រូវបានស្ទង់មតិទទួលបានប្រាក់ឈ្នួលតិចជាងប្រាក់ឈ្នួលអប្បបរមារបស់ខេត្តថៃ ដែលពួកគេធ្វើការ។ សេចក្តីប្រកាសព័ត៌មានបន្តថា ទោះបីជាប្រាក់ឈ្នួលទាប ពលករចំណាកស្រុកកម្ពុជា ក្នុង ១ នាក់ បានផ្ញើប្រាក់ទាំងនេះមកកាន់គ្រួសាររបស់ពួកគេ នៅប្រទេសកម្ពុជាជាមធ្យមចំនួន ៣៩ ៣១២ បាត (១ ២២៨ ដុល្លារ) ក្នុង ១ ឆ្នាំ។ អ្នកដែលត្រូវបានសម្ភាសនិយាយថា ការផ្ញើប្រាក់នេះគឺសំខាន់ណាស់ក្នុងការធ្វើឱ្យជីវភាពរស់នៅគ្រួសាររបស់ពួកគេមានភាពប្រសើរឡើង។

ជាមួយគ្នានេះ ពលករកម្ពុជា ក៏បានរាយការណ៍អំពីអត្ថប្រយោជន៍ផ្សេងទៀតពីការធ្វើចំណាកស្រុកនេះផងដែរ ដូចជាការកើនឡើងនូវប្រាក់សន្សំ និងការអភិវឌ្ឍជំនាញថ្មី ដែលពួកគេរំពឹងថា នឹងជួយឱ្យពួកគេអាចស្វែងរកការងារល្អដែលមានប្រាក់កម្រៃខ្ពស់ទាំងនៅក្នុងប្រទេសថៃ និងកម្ពុជា។ បើតាមសេចក្តីប្រកាសព័ត៌មាន ទោះបើជាច្បាប់ស្តីពីការធ្វើចំណាកស្រុក របស់ថៃ មិនត្រូវបានអនុញ្ញាតឱ្យនាំយកក្រុមគ្រួសារពលករ ទៅជាមួយខ្លួនក៏ដោយក៏ពលករចំណាកស្រុកកម្ពុជា មានបំណងធ្វើចំណាកស្រុកទាំងប្តី ប្រពន្ធផងដែរ។ ៣ ភាគ ៤ នៃអ្នកដែលត្រូវបានសម្ភាសបានរៀបការ ហើយ ៨៥ ភាគរយ នៃអ្នកទាំងនោះ កំពុងរស់នៅជាមួយប្តី ឬប្រពន្ធនៅក្នុងប្រទេស ថៃ។ ជាងពាក់កណ្តាលនៃអ្នកត្រូវបានសម្ភាសមានកូន ប៉ុន្តែកូនរបស់ពួកគេ តែងតែត្រូវបានទុកឱ្យសាច់ញាតិរបស់ពួកគេជាអ្នកមើលថែទាំនៅក្នុងប្រទេស កម្ពុជា។ លើសពីនេះទៅទៀតពលករចំណាកស្រុកកម្ពុជា ហាក់ដូចជាមានបំណងវិលត្រឡប់ទៅប្រទេសថៃវិញជាច្រើនលើក។ ជិត ៣ ភាគ ៤ នៃអ្នកត្រូវបានសម្ភាសបានធ្វើការនៅប្រទេស ថៃ ពីមុនមក។ ទោះបីជាភាគច្រើន មានផែនការវិលត្រឡប់មកប្រទេសកម្ពុជាវិញក៏ដោយ តែមានតិចតួចណាស់ ដែលពួកគេ មានបំណងវិលប្រឡប់មកវិញក្នុងពេលឆាប់ៗ។ ជារឿយៗ ពួកគេចង់ស្នាក់នៅ ៦ ឆ្នាំ ឬក៏ច្រើនជាងនេះទៀត មុននឹងវិលត្រឡប់មកកាន់ស្រុកកំណើតវិញ។ របាយការណ៍នេះសន្និដ្ឋានដោយផ្តល់អនុសាសន៍សម្រាប់រដ្ឋាភិបាលថៃ និងកម្ពុជា និងដៃគូអភិវឌ្ឍន៍ដើម្បីរៀបចំជាគោលនយោបាយយុទ្ធសាស្ត្រ និងអន្តរាគមន៍ផ្អែកលើភ័ស្តុតាង ដើម្បីផ្តល់អត្ថប្រយោជន៍អភិវឌ្ឍនៃការធ្វើចំណាកស្រុក ប្រកបដោយសុវត្ថិភាពត្រឹមត្រូវនិងទៀងទាត់ឱ្យបានកម្រិតខ្ពស់។

លោក Nathan Webb អ្នកគ្រប់គ្រងគម្រោង IOM ដែលជាអ្នកត្រួតពិនិត្យរបាយការណ៍នេះបានបញ្ជាក់ក្នុងសេចក្តីប្រកាសព័ត៌មានថា៖ «រយៈពេលជាង ៥ ទសវត្សរ៍មកនេះ ពលករកម្ពុជា បានធ្វើចំណាកស្រុកទៅប្រទេស ថៃមានចំនួនច្រើនដើម្បីធ្វើការងារ។ ចំណាកស្រុកនេះ បានរួមចំណែកដល់សេដ្ឋកិច្ចថៃនិងដើរតួនាទីយ៉ាងសំខាន់ក្នុងការបំពេញកង្វះខាតកម្លាំងពលកម្មនៅក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗរបស់ថៃ។ ការសិក្សានេះ ដើរតួជាចំណុចចាប់ផ្តើមដ៏ល្អ សម្រាប់ពលករចំណាកស្រុកទាំងអស់ដើម្បីស្វែងយល់ឱ្យបានច្បាស់ពីលក្ខណៈនៃការធ្វើចំណាកស្រុកទៅប្រទេសថៃ»។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រាប់ភ្នំពេញប៉ុស្តិ៍ កាលពីម្សិលមិញថា ការផ្លាស់ប្តូរកម្លាំងពលកម្មនេះ គឺជាចរន្តនៃសកលភាវូបនីយកម្ម និងការសមាហរណកម្មតំបន់ ហើយជាទូទៅប្រទេសដែលពាក់ព័ន្ធតែងតែទទួលផលប្រយោជន៍ទៅវិញទៅមក។ លោកបញ្ជាក់ថា៖ «សម្រាប់កម្ពុជា ក៏យើងទទួលបាននូវផលប្រយោជន៍ ដោយបងប្អូនកម្មករ និយោជិតរបស់យើងទទួលបាននូវប្រាក់បៀវត្សរ៍មួយដែលមានកម្រិតខ្ពស់ជាងបន្តិចនៅក្នុងស្រុក ហើយទី២ គឺមានលទ្ធភាពដើម្បីចាប់យកជំនាញ ឬមួយក៏បច្ចេកវិទ្យាមួយចំនួន ទោះបីជាក្នុងវិ

ស័យកសិកម្មក៏ដោយ ក៏វាអាចខ្ពស់ជាងប្រទេសយើងបន្តិច»។ លោកបញ្ជាក់ថា មួយវិញទៀត ប្រទេសថៃក៏អាចដោះស្រាយកង្វះកម្លាំងពលកម្មផងដែរ។ អ្វីដែលសំខាន់គឺកម្ពុជាត្រូវគ្រប់គ្រងការធ្វើចំណាកស្រុកនេះឱ្យបានល្អប្រសើរ ដើម្បីធានាថា ពលករដែលធ្វើចំណាកស្រុកនោះក្រៅពីទទួលបានប្រាក់បៀវត្សរ៍ និងជំនាញ ពួកគេក៏ទទួលបាននូវការការពារសិទ្ធិមួយពិតប្រាកដ។ លោក ហេង សួរ បញ្ជាក់ថា៖ «សម្រាប់ពលករកម្ពុជានៅថៃនេះដូចដែលយើងបានដឹងហើយ អំពីយុទ្ធនាការនៃការផ្តល់ភាពស្របច្បាប់ដែលយើងនិងរដ្ឋាភិបាលថៃបានឯកភាពគ្នាធ្វើតាំងពីឆ្នាំ ២០១៥ រហូតដល់ ២០១៨ ខែ ៦ (មិថុនា) កន្លងទៅនេះ គឺយើងមានលទ្ធភាពផ្តល់ភាពស្របច្បាប់ ដល់បងប្អូនពលកររបស់យើង ដែលបានចូលទៅដល់ប្រទេស ថៃ មុនខែ មីនា ឆ្នាំ ២០១៨»។

លោក មឿន តុលា នាយកប្រតិបត្តិអង្គការសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស មិនអាចទាក់ទងដើម្បីសុំការបញ្ជាក់បានទេកាលពីម្សិលមិញ។ ប៉ុន្តែលោកធ្លាប់បានប្រាប់ភ្នំពេញប៉ុស្តិ៍កាលពីខែមេសា កន្លងទៅនេះថា ពលករកម្ពុជាធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេស ថៃ កន្លែងខ្លះ មានភាពល្អប្រសើរ។ ប៉ុន្តែកន្លែងខ្លះ នៅមានបញ្ហាខ្លះនៅឡើយ ដូចជាការកាត់ប្រាក់ឈ្នួល ការថែមម៉ោងការងារ ការរក្សាលិខិតឆ្លងដែននៅក្នុងដៃថៅកែ។ល។

លោក តុលា បានបញ្ជាក់ថា ចំណែកពលករធ្វើការនៅលើទូកនេសាទថៃវិញ គឺនៅតែធ្វើការច្រើនម៉ោង ១៨ ម៉ោងក្នុង ១ ថ្ងៃ ឬក៏ច្រើនបំផុត ១០ ម៉ោងក្នុង ១ ថ្ងៃដោយមិនទទួលបានប្រាក់ថែមម៉ោង៕

## ថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ០១នាក់ ឲ្យមកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI **June 28 at 3:16 PM •**

ឧត្តរមានជ័យ៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិជាំ នាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០១នាក់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកចាក់ច្រែង ខេត្តព្រះវិហារ៕

# ថ្ងៃទី ០២ ខែកក្កដា ឆ្នាំ២០១៩

## បញ្ជីឈ្មោះក្រុមហ៊ុនស្របច្បាប់ដែលបញ្ជូនពលករខ្មែរទៅជប៉ុន ម៉ាឡេស៊ី ហុងកុង សិង្ហបុរី និងគូវ៉ែត

http://kleykley.sabay.com.kh/article/ ម៉ោង 14:31 ថ្ងៃទី02-07-2019

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីជូនដំណឹងចុះកាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១៩ ដោយបង្ហាញពីឈ្មោះក្រុមហ៊ុនឯកជន ដែលបានទទួលការអនុញ្ញាតឱ្យធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសចំនួន ០៨ ក្នុងនោះមាន៖ ជប៉ុន ម៉ាឡេស៊ី ហុងកុង សិង្ហបុរី ថៃ អារ៉ាប៊ីសាអូឌីត វៀតកាតា និងគូវ៉ែត ។

## ជប៉ុនបញ្ជូនគ្រូបង្គោលបន្ថែម មកបណ្តុះបណ្តាលជំនាញថែទាំមនុស្សចាស់ នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមពោធិ៍សែនជ័យ

http://grandnewsasia.com/detail/ 02-07-2019

អង្គការ JCIA របស់ជប៉ុនដែលជាដៃគូសហការ និងជួយគាំទ្រមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមពោធិ៍សែនជ័យ ស្ថិតនៅរាជធានីភ្នំពេញនោះ បានបញ្ជូនគ្រូបង្គោលផ្នែកថែទាំមនុស្សចាស់របស់ខ្លួនបន្ថែម មកបណ្តុះបណ្តាលជំនាញមួយចំនួនទៀត ដល់សិក្ខាកាមដែលសិក្សានៅក្នុងមជ្ឈមណ្ឌលមួយនេះ សំដៅបង្កើនចំនួនកម្មសិក្សាការីកម្ពុជាទៅធ្វើការនៅប្រទេសជប៉ុនបន្ថែម។

ការលើកឡើងនេះត្រូវបានធ្វើឡើងក្នុងជំនួបពិភាក្សាការងាររវាងលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយគណៈប្រតិភូជប៉ុនដឹកនាំដោយលោក យ៉ាម៉ាដា ហ្វូមីយ៉ូ (Yamada Fumio) ប្រធានអង្គការ JCIA នាព្រឹកថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងការងារ។

លោក យ៉ាម៉ាដា បានឱ្យដឹងថា ដំណើរការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមពោធិ៍សែនជ័យ ដែលបាននិងកំពុងបណ្តុះបណ្តាលជំនាញផ្នែកថែទាំមនុស្សចាស់ ដល់កម្មសិក្សាការីកម្ពុជានោះ ពិតជាបានប្រព្រឹត្តទៅប្រកបដោយភាពល្អូន ប៉ុន្តែចំនួនកម្មសិក្សាការីដែលបានបញ្ជូនទៅធ្វើការនៅប្រទេសជប៉ុននោះ នៅមានចំនួនតិចតួចនៅឡើយ។ ដូច្នេះហើយបានជាអង្គការ JCIA របស់លោក បានបញ្ជូនគ្រូបង្គោលមួយចំនួនមកជួយបណ្តុះបណ្តាលជំនាញបន្ថែម ពិសេសផ្តោតលើផ្នែកសុខាភិបាល ដើម្បីបង្កើនការជ្រើសរើស គ្រប់គ្រង បណ្តុះបណ្តាល និងបញ្ជូនកម្មសិក្សាការីកម្ពុជាទៅធ្វើការនៅប្រទេសជប៉ុនឱ្យបានកាន់តែច្រើន។

ត្រង់ចំណុចនេះ លោក អ៊ិត សំហេង ពិតជាបង្ហាញការគាំទ្រយ៉ាងពេញទំហឹង ដោយបានលើកទឹកចិត្តឱ្យអង្គការ JCIA អនុវត្តការបណ្តុះបណ្តាលជំនាញដល់កម្មសិក្សាការីនេះឱ្យបានត្រឹមត្រូវ ស្របតាមនីតិវិធីក្នុងអនុស្សរណៈនៃការយោគយល់គ្នារវាងភាគីកម្ពុជា និងជប៉ុន ដែលបានចុះហត្ថលេខាជាមួយគ្នាកាលពីដើមឆ្នាំ២០១៩។ ជាមួយគ្នានោះ លោករដ្ឋមន្ត្រីក៏បានស្នើឱ្យមានការគិតគូរលើបញ្ហាសុវត្ថិភាពរបស់កម្មសិក្សាការីកម្ពុជា ដែលត្រូវបញ្ជូនទៅធ្វើការ និងកំពុងធ្វើការនៅប្រទេសជប៉ុនផងដែរ ដែលនេះក៏ជាការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាប្រជាពលរដ្ឋកម្ពុជាដូចគ្នាដែរ។ ជប៉ុននៅតែលើកសរសើរពីការធ្វើការ អត្តចរិត និងភាពអត់ធ្មត់នឹងការងាររបស់កម្មសិក្សាការីកម្ពុជា ដែលបានទៅធ្វើការនៅប្រទេសជប៉ុន និងនៅតែពេញចិត្តចំពោះការទទួលពួកគេឱ្យធ្វើការនៅជប៉ុនទៀតផង ៕

## ពលរដ្ឋខ្មែរម្នាក់ទៀតហើយត្រូវបានកម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ប្រចាំច្រកទ្វារអន្តរជាតិខ្លងឡឹកស្រុកអរញ្ញ ខេត្តស្រះកែវ ប្រទេសថៃ ធ្វើការឃាត់ខ្លួន ពីបទប្រើត្រាវីសារក្លែងក្លាយ

https://www.facebook.com PheakTra 02-07-2019

យោងតាមរបាយការណ៍របស់កម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ថៃ ប្រចាំច្រកទ្វារអន្តរជាតិខ្លងឡឹក កាលពីថ្ងៃអង្គារ ទី18 ខែមិថុនា ឆ្នាំ2019 កន្លងទៅបានអោយដឹងថា កម្លាំងសមត្ថកិច្ចថៃ បានធ្វើការឃាត់ខ្លួន បុរសជនជាតិខ្មែរម្នាក់ ឈ្មោះចម្រើន អេង អាយុ 24 ឆ្នាំ សញ្ជាតិខ្មែរ កាន់លិខិតឆ្លងដែន លេខ N001494 បន្ទាប់ពីសមត្ថកិច្ចថៃរកឃើញថា ពលរដ្ឋខ្មែរលើ ប្រើប្រាស់ត្រាក្លែងក្លាយ រហ័សលេខកូដ(B225)ដែលសមត្ថកិច្ចថៃឈប់ប្រើប្រាស់យូរហើយ។ តាមការអះអាងរបស់បុរសខាងលើបានប្រាប់ថា គាត់ធ្លាប់ចូលធ្វើការនៅទីក្រុងបាងកកប្រទេសថៃ ហើយស្នាក់នៅ

ហួសសពុលភាពកំណត់ ដោយបានទាក់ទងមិត្តភ័ក្តិជាជនជាតិខ្មែរដូចគ្នា អោយជួយយកលិខិតឆ្លងដែនទៅរ៉ៃត្រាជំនួស ក្នុងតម្លៃ 3000បាត ដោយមិនដឹងថាជាត្រាក្លែងក្លាយ ។

បច្ចុប្បន្នជនសង្ស័យត្រូវបានសមត្ថកិច្ចថៃបញ្ជូនទៅអធិការដ្ឋានតម្រួតខ្លងឡឹកដើម្បីស្រាវជ្រាវបន្ថែម និងកសាងសំណុំរឿងដើម្បីចាត់វិធានការណ៍តាមផ្លូវច្បាប់។

## ក្រសួងកិច្ចការនារី៖ ពលករស្ត្រីមានហានិភ័យខ្ពស់ ពីការកេងប្រវ័ញ្ច កម្លាំងពលកម្មជាងបុរស

https://www.dap-news.com/ ByID:114 Posted on 02 July 2019 | 13:36

ភ្នំពេញ ៖ លោកស្រី ហ៊ូ សាមិត្ត រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី បានលើកឡើងថា ក្រុមស្ត្រីងាយរងគ្រោះខ្ពស់បំផុត ចំពោះពលករស្ត្រី ក្នុងការទទួលរងអំពើហិង្សាផ្លូវកាយ បំពានផ្លូវភេទ កេងប្រវ័ញ្ច កម្លាំងពលកម្ម និងវិសមភាព បើធៀបការងារដូចគ្នាជាមួយបុរស ។ នេះបើយោងតាម បណ្តាញទំនាក់ទំនង សង្គមហ្វេសប៊ុកផ្លូវការ របស់ក្រសួងកិច្ចការនារី ។

ក្នុងកម្មវិធីបើកវគ្គបណ្តុះបណ្តាល ស្តីពី "ការសម្របសម្រួលការផ្តល់សេវា ប្រកបដោយគុណភាព ដល់ពលករទេសន្តរប្រវេសន៍ជាស្ត្រី ដែលទទួលរងផលប៉ះពាល់ ដោយសារអំពើហិង្សាលើស្ត្រី" នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៩ លោកស្រី ហ៊ូ សាមិត្តបានថ្លែងថា អំពើហិង្សាលើស្ត្រី គឺជាការរំលោភបំពាន សិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ដែលរិតត្បិតសិទ្ធិ និងសេរីភាព ជាមូលដ្ឋានរបស់ស្ត្រី។ សកម្មភាពទាំងនោះ រួមមានការប្រើប្រាស់ហិង្សា ការគំរាមកំហែង ការបង្ខិតបង្ខំ ឬការដកហូតសិទ្ធិសេរីភាព អាចកើតមាននៅទីសាធារណៈ ឬក្នុងជីវិតឯកជន ហើយបុព្វហេតុចម្បង នៃអំពើហិង្សាលើស្ត្រី ត្រូវបានទទួលស្គាល់ទូទៅថា បណ្តាលមក វិសមភាពយេនឌ័រ និងការរើសអើង។

លោកស្រីបញ្ជាក់ថា "ក្នុងនោះក្រុមស្ត្រី ងាយរងគ្រោះ ដែលរួមមានក្រុមពលករស្ត្រី ទេសន្តរប្រវេសន៍ផងដែរ មានហានិភ័យខ្ពស់ ក្នុងការទទួលរងនូវអំពើហិង្សា ដូចជាអំពើហិង្សាផ្លូវកាយ ការកេងប្រវ័ញ្ច និងការបំពានផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងវិសមភាព ក្នុងការទទួលបានប្រាក់កម្រៃ ធៀបនឹងការងារដូចគ្នា ជាមួយនឹងបុរសជាដើម" ។ លោកស្រី ហ៊ូ សាមិត្ត បន្ថែមថា ម្យ៉ាងវិញទៀត ការមាក់ងាយ និងការរើសអើង ក្នុងសហគមន៍ ក៏ជាកត្តាសំខាន់ ដែលអាចបង្កើនហានិភ័យនៃអំពើហិង្សា ឬបញ្ហាប្រឈមក្នុងការទទួលបានកិច្ចការពារ និងសេវាសំខាន់ផ្សេងៗ។ កិច្ចការពារ ដល់ស្ត្រីពលករទេសន្តរប្រវេសន៍ ទាំងក្នុងប្រទេស និងក្រៅប្រទេស គឺត្រូវធ្វើឡើង ទាំងកម្រិតថ្នាក់ជាតិ និងកម្រិតទ្វេភាគី ពហុភាគី ឬថ្នាក់តំបន់ ៕ ដោយ៖ ដារាត់

## មន្ត្រីៈ ក្រុមហ៊ុនអ៊ីនធឺណេត មានភាគព្វកិច្ចសំខាន់ដើម្បីទប់ស្កាត់ក្នុងការរំលោភបំពានផ្លូវភេទកុមារ

http://www.rasmeinews.com/ July 2, 2019, 1:38 PM

**ដោយៈ មេសា/ភ្នំពេញៈ** លោកស្រី ញ៉េប សុភាព អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បី កុមារ បានថ្លែងអំពីគុណសម្បត្តិ និង គុណវិបត្តិ នៃ បច្ចេកវិជ្ជា និង អ៊ីនធឺណេតថា **បច្ចេកវិជ្ជាទំនើប និង ប្រព័ន្ធអ៊ីនធឺណេត បានផ្តល់ភាពងាយស្រួល ឱកាស និង ផលប្រយោជន៍យ៉ាងច្រើន ឥតគណនា ដល់ជីវភាពប្រចាំថ្ងៃ វិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច ពាណិជ្ជកម្ម វប្បធម៌ និង ការសិក្សាជាដើម ។ ប៉ុន្តែបច្ចេកវិជ្ជាទំនើប និង ប្រព័ន្ធអ៊ីនធឺណេត ក៏បាននាំមកនូវផលអវិជ្ជមាន និង ស្មុគស្មាញ ចំពោះកុមារច្រើនណាស់ដែរ ដូចជាការរំលោភបំពាន និង កេងប្រវ័ញ្ចផ្លូវភេទកុមារ តាមទម្រង់ថ្មីៗជាច្រើន ដែលវាទាមទារឱ្យមានវិធានការថ្មីៗកាន់តែមានប្រសិទ្ធភាព ការចូលរួមកាន់តែទូលំទូលាយ ហេតុនេះ ក្រុមហ៊ុនបច្ចេកវិជ្ជា ជាពិសេសក្រុមហ៊ុនទូរស័ព្ទដៃ និង ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណេត មានកាតព្វកិច្ចដ៏សំខាន់ ក្នុង**

**ការទប់ស្កាត់នូវការរំលោភបំពាន និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមរយៈការប្លុក ឬ បិទទុក នូវរាល់ភាពអាសអាភាស របស់កុមារ កុំឱ្យបង្ហោះបាន និង រាយការណ៍ជូនអាជ្ញាធរជាដើម ។**

លោកស្រី ញ៉េប សុភាព មានប្រសាសន៍យ៉ាងដូច្នេះនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការទប់ស្កាត់ និង ឆ្លើយតបជាពហុវិស័យចំពោះការរំលោភបំពាន និង ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណេត រៀបចំនៅឯសណ្ឋាគារ សាន់វ៉េ នាថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៩ ចូលរួមដោយអ្នកជំនាញការជាតិអន្តរជាតិ ប្រមាណជាជាង ១០០ នាក់ ។ អ្នកពាក់ព័ន្ធទាំងឡាយ បានមើលឃើញថា ការកេងប្រវ័ញ្ច រំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណេត ដូចជាជនខិលខូចល្បួងលួងលោមបោកបញ្ឆោតកុមារឱ្យផ្ញើទៅពួកគេ នូវរូបភាពអាសអាភាសជាដើម រួចហើយពួកគេយករូបភាពទាំងនោះ ទៅគំរាមកុមារ ឬ គ្រួសារកុមារឱ្យប្រគល់ផលប្រយោជន៍ម្យ៉ាងដល់ពួកគេ ឬ បង្ហោះរូបភាពទាំងនោះ ដើម្បី រកផលប្រយោជន៍ ខណៈជនខ្លះល្បួងកុមារ ទៅសេពសន្ថវៈជាដើម ។

តាមការគ្រោងទុក លទ្ធផល នៃ សិក្ខាសាលានាថ្ងៃនេះ នឹងត្រូវបានដាក់ជាជាតុចូល ដែលអាចឈានដល់ការបង្កើតជាគោលការណ៍ណែនាំ និង វិធានការនានា ដើម្បី ទប់ស្កាត់ការកេងប្រវ័ញ្ច និង រំលោភបំពានផ្លូវភេទកុមារ ជាពិសេសតាមប្រព័ន្ធអ៊ីនធឺណេត ៕ Kh

## ថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ២០១៩

### កងយោធពលខេមរភូមិន្ទ ប្តេជ្ញាបន្តពង្រឹងការពារជាតិ លើគ្រប់វិស័យ នៅតាមតំបន់ព្រំដែន

https://www.dap-news.com/archives/ ByID:113 Posted on 03 July 2019 | 12:40

**ភ្នំពេញ៖** នាយឧត្តមសេនីយ៍ ឈុំ សុជាតិ អ្នកនាំពាក្យក្រសួងការពារជាតិបានថ្លែងថា ឆមាសទី១ ឆ្នាំ២០១៩ កងយោធពលខេមរភូមិន្ទបាន ប្តេជ្ញាបន្តពង្រឹងប្រៀបការពារជាតិ លើគ្រប់វិស័យនៅតាមតំបន់ព្រំដែនដើម្បីតាមដានត្រួតពិនិត្យ គ្រប់គ្រងសភាពការណ៍ ភូមិសាស្ត្រទទួលខុសត្រូវ និងចូលរួមទប់ស្កាត់ បទល្មើសគ្រប់ប្រភេទផងដែរ។

យោងតាមគេហទំព័រ ហ្វេសប៊ុករបស់លោក ឈុំ សុជាតិ នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៩ បានឲ្យដឹងថា "សម្រាប់ឆមាសទី១ ឆ្នាំ២០១៩នេះ កងយោធពលខេមរភូមិន្ទ បានបន្តពង្រឹងការពារជាតិ លើគ្រប់វិស័យនៅតាមតំបន់ព្រំដែន ល្បាតជាប្រចាំ ដើម្បីតាមដានត្រួតពិនិត្យ គ្រប់គ្រងសភាពការណ៍ និងភូមិសាស្ត្រទទួលខុសត្រូវ និងចូលរួមទប់ស្កាត់បទល្មើសគ្រប់ប្រភេទ និងសកម្មភាពឆ្លងដែនខុសច្បាប់ ព្រមទាំងបានបន្តកិច្ចសហប្រតិបត្តិការល្អ ជាមួយប្រទេសជិតខាង ដោះស្រាយបញ្ហាផ្សេងៗ ដែលកើតឡើងដោយសន្តិវិធី"។ លោកបន្តថា សម្រាប់ឆមាសទី១ ឆ្នាំ២០១៩ កងយោធពលខេមរភូមិន្ទ បានបន្តអនុវត្តភារកិច្ចតាមកម្មវិធី នយោបាយយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល និងផែនការកែទម្រង់ កងយោធពលខេមរភូមិន្ទរយៈពេល៥ឆ្នាំ និងកម្មវិធីការងារ ដោយសម្រេចបាននូវ សមិទ្ធផលការងារធំៗ ជាច្រើន។

សូមរំលឹកថា នៅព្រឹកថ្ងៃទី៣ កក្កដា នេះ ក្រសួងការពារជាតិ បានបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងលើកទិសដៅអនុវត្តបន្តសម្រាប់ឆមាសទី២ ឆ្នាំ២០១៩ ក្រោមអធិបតីភាពសម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ៕ ដោយ ៖ អេង ប៊ូឆេង

## ជប៉ុនជួយលើកកម្ពស់សមត្ថភាពពលករកម្ពុជាផ្នែកថែទាំមនុស្សចាស់ដើម្បីឆ្លើយតបតម្រូវការទីផ្សារការងារនៅប្រទេសជប៉ុន

https://www.information.gov.kh/ ចេញផ្សាយថ្ងៃទី 2 ខែកក្កដា ឆ្នាំ2019 វិទ្យុជាតិកម្ពុជា អត្ថបទ៖លោក ជួន បូណា

ភ្នំពេញ៖ អង្គការ JCIA របស់ជប៉ុន ជួយបណ្តុះបណ្តាលពលករកម្ពុជាពីជំនាញថែទាំមនុស្សចាស់ ដើម្បីបង្កើនសមត្ថភាពសម្រាប់ឆ្លើយតបទីផ្សារការងារនៅក្នុងប្រទេសជប៉ុន។ ក្រោយបញ្ចប់ជំនួបពិភាក្សាការងាររវាងឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយគណៈប្រតិភូជប៉ុនដឹកនាំដោយលោកយ៉ាម៉ាដា ហ្វូមីយ៉ូ (Yamada Fumio) ប្រធានអង្គការ JCIA នាព្រឹកថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ នៅទីស្តីការក្រសួង។

ឯកឧត្តម ហ៊ូ វុឌ្ឍី អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានប្រសាសន៍ថា លោកយ៉ាម៉ាដាបានឱ្យដឹងថា មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមពោធិ៍សែនជ័យកំពុងដំណើរការបណ្តុះបណ្តាលជំនាញផ្នែកថែទាំមនុស្សចាស់ដល់កម្មសិក្សាការីកម្ពុជា ដែលបានប្រព្រឹត្តទៅដោយរលូន ស្របនឹងស្តង់ដារប្រទេសជប៉ុន។ ឯកឧត្តមបានបញ្ជាក់ថា ទីផ្សារការងារថែទាំមនុស្សចាស់នៅប្រទេសជប៉ុនមានតម្រូវការ ខ្ពស់ ដូច្នេះដែលទាមទារការបណ្តុះបណ្តាលកម្មសិក្សាការីជំនាញនេះឲ្យបានច្រើនបន្ថែមទៀតដើម្បីឆ្លើយតម្រូវការចង់បាននៅក្នុងប្រទេសជប៉ុន។ ឯកឧត្តមបញ្ជាក់ថា ដោយមើលឃើញកត្តាទាំងនេះហើយ អង្គការ JCIA របស់ជប៉ុនដែលជាដៃគូសហការនិងជួយគាំទ្រមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមពោធិ៍សែនជ័យ បានបញ្ជូនគ្រូបង្គោលផ្នែកថែទាំមនុស្សចាស់របស់ខ្លួនបន្ថែមមកបណ្តុះបណ្តាលជំនាញមួយចំនួននៅកម្ពុជា ដើម្បីបង្កើនការជ្រើសរើសគ្រប់គ្រងបណ្តុះបណ្តាលនិងបញ្ជូនកម្មសិក្សាការីកម្ពុជាទៅធ្វើការនៅប្រទេសជប៉ុនអោយកាន់តែច្រើនថែមទៀត។ ឯកឧត្តមបានន្ថែមថា ការពង្រីកគ្រូបង្គោលផ្នែកថែទាំមនុស្សចាស់ដល់ពលកម្ពុជានេះ ខណៈដែលពលករកម្ពុជាមានអត្តចរិតល្អ ភាពអត់ធ្មត់ និងតស៊ូ ដែលបានទៅធ្វើការនៅប្រទេសជប៉ុន ។

ជាការឆ្លើយតប ឯកឧត្តមបណ្ឌិត អ៊ិត សំហេង បានស្វាគមន៍ និងគាំទ្រយ៉ាងពេញទំហឹងដោយបានលើកទឹកចិត្តឱ្យអង្គការJCIA អនុវត្តការបណ្តុះបណ្តាលជំនាញដល់កម្មសិក្សាការីនេះឱ្យបានត្រឹមត្រូវស្របតាមនីតិវិធីក្នុងអនុស្សរណៈនៃការយោគយល់គ្នារវាងភាគីកម្ពុជា និងជប៉ុន ដែលបានចុះហត្ថលេខាជាមួយគ្នាកាលពីដើមឆ្នាំ២០១៩ មកនោះ។ ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រីក៏បានស្នើឱ្យមានការគិតគូរលើបញ្ហាសុវត្ថិភាពរបស់កម្មសិក្សាការីកម្ពុជា ដែលត្រូវបញ្ជូនទៅធ្វើការនិងកំពុងធ្វើការនៅប្រទេសជប៉ុនផងដែរ ដើម្បីធានាសុវត្ថិភាព និងសិទ្ធិ ពលករកម្ពុជា។

សូមបញ្ជាក់ថា បច្ចុប្បន្ននេះ ពលករកម្ពុជាដែលបានបញ្ជូនទៅធ្វើនៅប្រទេសជប៉ុន មានចំនួនជាង៨ពាន់នាក់ ហើយកម្ពុជា-ជប៉ុនគ្រោងនឹងបញ្ជូនពលករទៅការនៅជប៉ុននាពេលខាងមុខនេះអោយកាន់តែច្រើនបន្ថែមទៀ៕

# ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១៩

## ការិយាល័យប្រឆាំងការជួញដូរ និងការពារអនីតិជន ចុះបង្ក្រាបទីតាំងម៉ាស្សា បង្កប់សេវាផ្លូវភេទ សង្ស័យបម្រើដោយអនីតិជន

http://nokorwatnews.com/archives/ 05-07-2019

ភ្នំពេញ៖ កម្លាំងនគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនសហការជាមួយនគរបាលមូលដ្ឋានខណ្ឌបឹងកេងកង បានចុះប្រតិបត្តិការបង្ក្រាបទីតាំងម៉ាស្សាឃីហោ កោសជប់ម៉ាស្សា១ម៉ឺនរៀលមានបង្កប់សេវាផ្លូវភេទ ឃាត់ខ្លួនមនុស្សចំនួន៧នាក់ ក្នុងនោះស្ត្រីម្ចាស់ទីតាំង១ម្នាក់ នារីរងគ្រោះចំនួន៦នាក់ ។ ប្រតិបត្តិការនេះធ្វើឡើងកាលពីវេលាម៉ោង ២ និង០០នាទីរសៀលនាថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ ស្ថិតនៅផ្ទះលេខ ២២B ផ្លូវ២៨៨ សង្កាត់បឹងកេងកងទី២ ខណ្ឌ បឹងកេងកង រាជធានីភ្នំពេញ ។

ប្រតិបត្តិការនេះ ដោយមានចង្អុលបង្ហាញពី លោកឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការរង និងជាស្នងការនគរបាលរាជធានីភ្នំពេញ មានការចុះដឹកនាំបញ្ជាផ្ទាល់ ពីលោកស្រី សឺ វណ្ណនី ព្រះរាជអាជ្ញារង អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និង លោក ឧត្តមសេនីយ៍ទោ ចាន់ កិត្តិខុម ស្នងការរងទទួលដឹកនាំការងារការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជាធានីភ្នំពេញ ។

នគរបាលបានអោយដឹងថា ស្ត្រីម្ចាស់ទីតាំងមានឈ្មោះ ង្វៀង ធីង្វធី ភេទស្រី អាយុភេទស្រី អាយុ៤០ឆ្នាំ ស្នាក់នៅទីតាំងម៉ាស្សាផ្ទះលេខ២២B ផ្លូវ២៨៨ សង្កាត់បឹងកេងកងទី២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ។ កម្លាំងនគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានឲ្យដឹងថាទីតាំងម៉ាស្សាកោសជប់ យីហោកោសជប់ម៉ាស្សា១ម៉ឺនរៀល ចាប់ផ្តើមបើកបម្រើសេវាចាប់ពីម៉ោង៩ព្រឹក រហូតដល់យប់ជ្រៅរំលងអាធ្រាតដោយមាននារីក្មេងចំនួន៦នាក់ ដោយសង្ស័យជាអនីតិជន ចំនួន២នាក់ រងចាំភ្ញៀវ មកម៉ាស្សាធម្មតាតម្លៃ១ម៉ឺនរៀល រយៈពេល១ម៉ោង និងរួមភេទ តម្លៃចាប់ពី ១៥ដុល្លារ ទៅ២០ដុល្លារ ក្នុងមួយដង ។

ក្រោយពេលបញ្ចប់ប្រតិបត្តិការនេះផងដែរកម្លាំងនគរបាលបានឃាត់ខ្លួនមនុស្សចំនួន ៧នាក់ក្នុងនោះនារីរងគ្រោះចំនួន ៦នាក់ ស្ត្រីម្ចាស់ទីតាំងម្នាក់ និងដកហូតវត្ថុតាងរួមមានស្រោមអនាម័យប្រើរួច និងមិនទាន់ប្រើប្រាស់មួយចំនួនធំ ផងដែរ បាននាំយកមកការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនដើម្បីបន្តការសាកសួរ និងចាត់ការតាមនីតិវិធី ៕ ស ស្មើ

## ដាក់បទបញ្ជាឲ្យនាយប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ទប់ស្កាត់រាល់បទល្មើសគេចពន្ធ ការជួញដូរស្ត្រី កុមារ ឲ្យមានប្រសិទ្ធភាព

http://www.cen.com.kh/archives/ July 4, 2019

ឧត្តរមានជ័យ៖ អភិបាលខេត្តឧត្តមានជ័យ បានស្នើដល់នាយប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ដែលតែងតាំងថ្មី ត្រូវរក្សាឲ្យបានល្អ នូវក្រមសីលធម៌ វិជ្ជាជីវៈ យកចិត្តទុកដាក់ឲ្យបានខ្ពស់បំផុត ក្នុងកិច្ចសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ និងភាគីថៃ ទប់ស្កាត់រាល់បទល្មើសគេចពន្ធនានា ការជួញដូរស្ត្រី កុមារ បទល្មើសគ្រឿងញៀន និងរាល់បទល្មើសឆ្លងដែនផ្សេងៗទៀត។

លោក ប៉ែន កុសល្យ អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ ថ្លែងបែបនេះ កាលពី ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៩ ក្នុងពិធីប្រកាសផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ដោយលោកវរសេនីយ៍ឯក ថេរ សុរិទ្ធីយ៉ា ជំនួស លោកឧត្តមសេនីយ៍ត្រី ខូង ទីន។

លោកនាយឧត្តមសេនីយ៍ យុន សំបូរ អគ្គនាយករងអន្តោប្រវេសន៍ បានមានប្រសាសន៍ លើកឡើងថា នាយប៉ុស្តិ៍នគរបាលច្រកព្រំដែនអន្តរជាតិអូរស្មាច់ ដែលចូលកាន់តំណែងថ្មី ត្រូវយកចិត្តទុកដាក់ បម្រើផលប្រយោជន៍ ជូនប្រជាពលរដ្ឋ និងបំពេញបែបបទចេញ ចូល ក្នុងប្រទេសឲ្យ បានទាន់ពេលវេលា ជាពិសេសខិតខំពង្រឹងការងារផ្ទៃក្នុងឲ្យបានល្អ ត្រូវចេះរឹតចំណងសាមគ្គីភាព ឲ្យបានទូលំទូលាយ សហការជាមួយបណ្តាស្ថាប័ន និងអង្គភាពជំនាញនានា ដើម្បីអនុវត្តន៍ការងារ ទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់ ស្របតាមគោលការណ៍ របស់ក្រសួងមហាផ្ទៃ។ ជាងនេះទៀត ភារកិច្ចរបស់មន្ត្រីនគរបាលច្រកទ្វារព្រំដែន គឺការទទួលខុសត្រូវគ្រប់បែបយ៉ាង ពីសន្តិសុខសណ្តាប់ធ្នាប់ក្នុងតំបន់ នៃខ្សែបន្ទាត់ព្រំដែន។

យ៉ាងណាមិញ លោក ប៉ែន កុសល្យ អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ ក៏បានផ្តាំផ្ញើ ដល់លោកនាយប៉ុស្តិ៍ដែលតែងតាំងថ្មី ត្រូវរក្សាឲ្យបានល្អ នូវក្រមសីលធម៌ វិជ្ជាជីវៈ យកចិត្តទុកដាក់ឲ្យបានខ្ពស់បំផុត ក្នុងកិច្ចសហការជាមួយ សមត្ថកិច្ចពាក់ព័ន្ធ និងភាគីថៃ ទប់ស្កាត់រាល់បទល្មើសគេចពន្ធនានា ការជួញដូរស្ត្រី កុមារ បទល្មើសគ្រឿងញៀន និងរាល់បទល្មើសឆ្លងដែនផ្សេងៗទៀត ឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ជាពិសេសត្រូវអនុវត្តន៍ ឲ្យបាននៅគោលនយោបាយ និងស្របតាមយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា

ក្រោមមគ្គុទ្ទេសក៍ដឹកនាំដ៏ប៉ិនប្រសព្វប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា៕ ដោយៈកូឡាប

## កម្ពុជា-ថៃចាប់ដៃគ្នាសម្រេចយល់ព្រម និងចុះហត្ថលេខាលើកំណត់ហេតុរួម

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៩ ម៉ោង ១០:៥៤ ហួត សុងហាក់

ខេត្តបាត់ដំបង ៖ ការសម្រេចយល់ព្រម និងចុះហត្ថលេខាលើកំណត់ហេតុរួម ក្នុងកិច្ចប្រជុំក្រុមលេខាគណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគលើកទី២៧ បានធ្វើឡើងនៅសណ្ឋាគារហូលីដេ អ៊ិន នៅទីក្រុងបាងកក ប្រទេសថៃវេលាព្រឹកថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៩ ដែលភាគីកម្ពុជាចំនួន៤៣ រូប ដឹកនាំដោយលោកឧត្តមសេនីយ៍ទោ សេង ជារិន មេបញ្ជាការរង នាយសេនាធិការយោធភូមិភាគទី៥ ជាប្រធានក្រុមលេខាខាងកម្ពុជា រួមសហការជាមួយភាគីថៃ ជាម្ចាស់ផ្ទះ ដឹកនាំដោយលោកឧត្តមសេនីយ៍ត្រី ថាណាស៊ីន ស៊ុកឃោ (Thanasin sokkho)នាយសេនាធិកាកងទ័ពភូមិភាគទី១ ជាប្រធានក្រុមលេខាភាគីថៃ ។

ភាគីទាំងពីរបានទទួលយកសំណើទាំងសងខាង ដើម្បីដាក់ជូនគណកម្មាធិការព្រំដែនសម្រេចវេលាថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៩ ដោយមានលោកឧត្តមសេនីយ៍ឯក ឯក សំអួន ប្រធានគណៈកម្មាធិការខាកម្ពុជា និងលោកឧត្តមសេនីយ៍ទោ ណារ៉ុងផាន់ ជិតកែផៃ ប្រធានគណៈកម្មាធិការថ្នាក់ភូមិភាគថៃ ដោយមានខ្លឹមសារអំពី ពិភាក្សាដើម្បីរំលឹក និងផ្សះផ្សាការយោគយល់គ្នាក្នុងការការពារ និងដោះស្រាយបញ្ហាដែលកើតមានឡើង ដោយប្រើយន្តការក្នុងក្របខ័ណ្ឌរបស់គណៈកម្មធិការព្រំដែនថ្នាក់ភូមិភាគ (RBC)ដោយមានលើកគំពោង កិច្ចសហការដោសសំអាតមីនតាមបណ្តោយព្រំដែនថៃ-កម្ពុជា ។ ភាគីទាំងពីរថៃរក្សា គាំទ្រឲ្យមានលំហាត់ក្នុងការជួយសង្គ្រោះ មហន្តរាយក្នុងភូមិសាស្ត្រព្រំដែន ផ្លាស់ប្តូរទិន្នន័យបទពិសោធន៍រវាងអាជ្ញាធរពាក់ព័ន្ធតាមបណ្តោយព្រំដែន កិច្ចសហការលើវិស័យសុខាភិបាលរវាងកងទ័ពបន្ថែមទៀតឲ្យមានភាពច្បាស់លាស់, បន្តគាំទ្រការងារសុវត្ថិភាពទន្លេមេគង្គ គម្រោងការភូមិពណ៌ស រួចចាកពីគ្រឿងញៀន បំផ្លាញចោលបណ្តាញផលិតគ្រឿងញៀនរវាងប្រទេសទាំងពីរមិនឲ្យកើតមានតាមព្រំដែនឡើយ ។

បន្តមកទៀតខ្លឹមសារបានផ្តោតលើកិច្ចសហប្រតិបត្តការវិស័យសន្តិសុខ ការបង្ការកើតឡើងនូវវិវាទ, ទប់ស្កាត់បទឧក្រិដ្ឋកម្ម និងអំពើភេវកម្មឆ្លងដែន,ការឆ្លងកាត់ព្រំដែន, ការជួញដូរមនុស្ស និងក្មេងអនាថា , ពលករចំណាកស្រុកខុសច្បាប់, កិច្ចសហការប្រតិបត្តការវិស័យសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន វិទ្យាសាស្ត្រ និងបច្ចេកទេស, លើកស្ទួយវិស័យទេសចរណ៍ , វិស័យអប់រំផ្សព្វផ្សាយដើម្បីលើកស្ទួយសន្តិភាពយូរអង្វែង និងជំរុញកិច្ចសហប្រតិបត្តការដោះស្រាយបញ្ហាដែលអាចមានផលប៉ះពាល់ដល់ទំនាក់ទំនងកម្ពុជា-ថៃ (ក្នុងអំឡុងពេលប្រតិបត្តការវាស់វែង និងខណ្ឌសីម៉ាព្រំដែនគោក) ។ បន្ទាប់មកលោកឧត្តមសេនីយ៍ទោ ណារ៉ុងផាន់ ជិតកែផៃ ប្រធានគណៈកម្មាធិការថ្នាក់ភូមិភាគថៃ និងលោកឧត្តមសេនីយ៍ឯក ឯក សំអួន ប្រធានគណៈកម្មាធិការខាងភាគីកម្ពុជា បានត្រួតពិនិត្យឯកភាពចុះហត្ថលេខាលើកំណត់ហេតុរួមគ្នា ហើយឲ្យបន្តចុះអនុវត្តន៍ឲ្យមានភាពល្អប្រសើរឡើងដូចៗគ្នាតាមព្រំដែន ៕

## ជនអន្តោប្រវេសន៍១៣៤នាក់ ត្រូវបពួករត់ពន្ធមនុស្សញាត់ចូលក្នុងរថយន្តតែមួយ

http://www.rasmeinews.com/ July 5, 2019, 9:38 AM

រូបភាពទើបត្រូវបានបញ្ចេញកាលពីពេលថ្មីៗ បង្ហាញជនអន្តោប្រវេសន៍អាម៉េរិកកណ្តាលជាង១០០នាក់ ត្រូវបានរំដោះចេញពីរថយន្តធំដែលត្រូវគេបោះបង់ចោលមួយនៅម៉ិកស៊ិកកាលពីសប្តាហ៍មុន។ អ្នកស្រុកនៅទីក្រុង អូហ្ស៊ុយឡូម៉ា ក្នុងរដ្ឋវេរ៉ាគ្រូស របស់ម៉ិកស៊ិចបានឮសំឡេងស្រែកយំចេញពីកន្ទុយរថយន្តទ្រុងធំប៉ុនកុងតឺន័រកាលពីថ្ងៃ២៧ មិថុនា។យោធានិងប៉ូលិសមូលដ្ឋានត្រូវបានជូនដំណឹងប្រាប់ និងគេបានបើកទ្វារទ្រុងរថយន្តហើយបានឃើញមនុស្ស

ជាង១០០នាក់ បន្ទាប់ពីរថយន្តបានឈប់នៅជិតស្ថានីយប៉ូលិសមួយអស់ពេលជាង៣ម៉ោង។ អាជ្ញាធរម៉ិកស៊ិកបានផ្ដល់សេវាវេជ្ជសាស្ត្រដល់ជនចំណាកស្រុកទាំង១៣៤នាក់ រួមមានកូនក្មេង៧១នាក់ ដែលបង្ហាញការខ្សោះជាតិទឹកនិងរបួសតិចតួច។ ជនអន្តោប្រវេសន៍គ្មានអាវត្រូវបានគេឃើញជួយគ្នាលោតចេញពីរថយន្ត។យោងតាមសារព័ត៌មាន ពួកគេបានព្យាយាមទម្លុះទ្វារចេញពីខាងក្នុងតែមិនបានសម្រេច។

បើតាមប៉ូលិស ជនអន្តោប្រវេសន៍គ្មានឯកសារទាំងនេះមកពីប្រទេសអែលសាល់វ៉ាឌ័រ ហុងឌុយរ៉ាស និងហ្គាតេម៉ាឡា។ គោលដៅរបស់គេគឺសហរដ្ឋអាម៉េរិក តែអ្នកបើករថយន្តបានទុកពួកគេចោល។ កាលពីខែមុន ជនក្វាតេម៉ាឡា ១៤២នាក់ ក៏ត្រូវបានសង្គ្រោះក្រោយពីពួកគេត្រូវបានទុកចោលក្នុងរថយន្តធំមួយនៅក្នុងទីក្រុងដដែល។

សូមបញ្ជាក់ថា ម៉ិកស៊ិកក្លាយជាចំណុចឆ្លងកាត់សម្រាប់ក្រុមជនអន្តោប្រវេសន៍អាម៉េរិកកណ្ដាលដែលព្យាយាមរកការជ្រកកោននៅអាម៉េរិក ។ ឥឡូវ រដ្ឋាភិបាលម៉ិកស៊ិកត្រូវអាម៉េរិកតម្រូវឲ្យបង្ក្រាបលំហូរជនអន្តោប្រវេសន៍មកពីអាម៉េរិកកណ្ដាល និងអាហ្វ្រិក ព្រមទាំងប្រទេសហៃទី បើខ្លួនមិនចង់រងទណ្ឌកម្មពីរដ្ឋាភិបាលក្រុងវ៉ាស៊ីនតោនទេ។ ម៉ិកស៊ិកបានប្រកាសកាលពីសប្ដាហ៍មុនថា ខ្លួនបានបញ្ជូនទាហាន ១៥.០០០ បន្ថែមទៅការពារព្រំដែនប្រវែងជាង ៣០០០គីឡូម៉ែត្ររបស់ខ្លួនជាមួយអាម៉េរិកដើម្បីបញ្ឈប់ការហូរចូលជនអន្តោប្រវេសន៍៕ ដោយៈ**វាសនា**/Ha

## ថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០១៩

## ឃាត់ខ្លួនមេខ្យល់ម្នាក់ នាំនារីក្មេងៗឲ្យរួមភេទជាមួយភ្ញៀវនៅតាមផ្ទះសំណាក់ និងសណ្ឋាគារ

http://cambodiapolice.com/policekh/ 9:39 am 6 កក្កដា 2019

ភ្នំពេញ ៖ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានឃាត់ខ្លួនមេខ្យល់ម្នាក់ នាំនារីក្មេងៗឲ្យរួមភេទជាមួយភ្ញៀវនៅតាមផ្ទះសំណាក់ និងសណ្ឋាគារ នៅចំណុចភោជនីយ៍ដ្ឋាន ឈូករ័ត្ន ម្ហូបខ្មែរ ផ្លូវលេខ ១៩៨៦ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ (ឃាត់ខ្លួន៣នាក់) និងនៅចំណុចផ្ទះសំណាក់ ស្រែផល ផ្លូវបេតុង សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ (ឃាត់ខ្លួន៣នាក់) កាលពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង១៤និង០០នាទី ។

ការឃាត់ខ្លួនមេខ្យល់និងនារីរងគ្រោះ៥នាក់ ដោយបានចុះអនុវត្តចំណារអនុញ្ញាតិឲ្យបង្ក្រាបជាក់ស្តែងលេខ ០៦៥ អ.យ.ខ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ របស់លោកស្រី ស៊ី វណ្ណនី ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ធ្វើការបង្ក្រាបជាក់ស្តែង ករណី ប្រព្រឹត្តិអំពើសញ្ចារកម្មមានស្ថានទម្ងន់ទោស (នាំនារីក្មេងៗឲ្យរួមភេទជាមួយភ្ញៀវនៅតាមផ្ទះសំណាក់ និងសណ្ឋាគារ) ឃាត់ខ្លួនមនុស្សចំនួន៦នាក់។

មនុស្សទាំង៦នាក់ដែលឃាត់ខ្លួនរួមមាន (មេខ្យល់ ឈ្មោះ ខន ចាន់ណារី ភេទស្រី អាយុ២២ឆ្នាំ ជនជាតិខ្មែរ និងជនរងគ្រោះ៥នាក់ អនីតិជន៣នាក់) នៅចំណុចភោជនីយ៍ដ្ឋាន ឈូករ័ត្ន ម្ហូបខ្មែរ ផ្លូវលេខ១៩៨៦ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ (ឃាត់ខ្លួន៣នាក់) និងនៅចំណុចផ្ទះសំណាក់ ស្រែផល ផ្លូវបេតុង សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ (ឃាត់ខ្លួន៣នាក់) ។ បច្ចុប្បន្នសមត្ថកិច្ចកំពុងធ្វើការសាកសួរ និងស្រាវជ្រាវតាមនីតិវិធី៕

## បញ្ជូនស្ត្រីរកស៊ីផ្លូវភេទ៩នាក់ ទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ

https://www.chnchannel.com/article/ អត្ថបទដោយ Asmatt កាលបរិច្ឆេទ ថ្ងៃទី 8 ខែ កក្កដា ឆ្នាំ 2019

ភ្នំពេញ ៖ កម្លាំងអធិការដ្ឋាននគរបាលខណ្ឌដូនពេញ កាលពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង២០និង ០០នាទី បានចុះបង្ក្រាប ករណីស្ត្រីរកស៊ីផ្លូវភេទ និងអ្នកគួកជេរ (អ្នកចាប់ម៉ូយ) ស្ថិតនៅចំណុចផ្លូវលេខ ៩២. ៩៤. ៩៦ និងជុំវិញរង្វង់មូលវត្តភ្នំ ចំនួន៩នាក់។ ការចុះប្រតិបត្តិការនេះ ជាលទ្ធផលបានបញ្ចប់នៅវេលាម៉ោង២និង០០

នាទីរំលងអាធ្រាត ចូលថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ សមត្ថកិច្ចប្រមូលបានសរុបរួមចំនួន៩នាក់ ក្នុងនោះប្រុសខ្ទើយចំនួន៣នាក់ ស្រី០៦នាក់។ ចំពោះមុខ អធិការដ្ឋានបានបញ្ជូនស្ត្រីរកស៊ីផ្លូវភេទ និងអ្នកគួកជេរខាងលើទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ហើយកិច្ចប្រតិបត្តិការនេះ សមត្ថកិច្ចនឹងបន្តអនុវត្តន៍ជាប់ជាប្រចាំ៕

## សមកិច្ចថៃចុះចាប់បានពលករខ្មែរខុសច្បាប់ចំនួន41នាក់ ធ្វើការកន្លែងអេតចាយមួយកន្លែង

https://www.facebook.com/ ទឹកចិត្ត ពលករ ឆ្លងដែន 07-07-2019

ថ្ងៃទី 07-07-2019 សមកិច្ចថៃចុះចាប់បានពលករខ្មែរខុសច្បាប់ចំនួន41នាក់ ធ្វើការកន្លែងអេតចាយមួយកន្លែង នៅក្នុងស្រុក វ៉ាណាមយិន ខេត្តស្រះកែវ ប្រទេសថៃ។

## ស្ត្រីមេខ្យល់នាំនារីក្មេងៗឲ្យត្រៀវតាមផ្ទះសំណាក់ និងសណ្ឋាគារ ត្រូវនគរបាលបញ្ជូនខ្លួនមកតុលាការ

https://www.chnchannel.com/article/ អត្ថបទដោយ Asmatt កាលបរិច្ឆេទ ថ្ងៃទី 8 ខែ កក្កដា ឆ្នាំ 2019

ភ្នំពេញ៖ ស្ត្រីម្នាក់ទៅកាន់កម្លាំងនគរបា លការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៅព្រឹកថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០១៩ បានបញ្ជូនខ្លួន ទៅសាលាដំបូងរាជធានីភ្នំពេញ ពាក់ព័ន្ធ អំពើសញ្ជារកម្ម។ នគរបាលបានប្រាប់ឲ្យដឹងថា ស្ត្រីជាជន សង្ស័យមានឈ្មោះ ខន ចាន់ណារី ភេទ ស្រី អាយុ ២២ឆ្នាំ ជនជាតិខ្មែរ ត្រូវបាននគរបាល ស៊ើបអង្កេតស្រាវជ្រាវ និងឃាត់ខ្លួនកាលពីរសៀលថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៩។ បើតាមសមត្ថកិច្ចជំនាញ ស្ត្រីសង្ស័យ តែងតែនាំនារីក្មេងៗ ទៅជូនភ្ញៀវ នៅតាមផ្ទះសំណាក់ និងសណ្ឋាគារ។ នៅថ្ងៃឃាត់ខ្លួនស្ត្រីសង្ស័យ បាននាំនារីរងគ្រោះ ៥នាក់ ទៅជួបជូនភ្ញៀវនៅចំណុចភោជនីយ៍ដ្ឋានឈូករ័ត្នម្ហូបខ្មែរ នៅតាមបណ្តោយផ្លូវលេខ១៩៨៦ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ និងនៅ ចំណុចផ្ទះសំណាក់ ស្រែផល ផ្លូវបេតុង សង្កាត់អូរបែកក្អម ខណ្ឌសែន សុខ រាជធានីភ្នំពេញ។

ទោះជាយ៉ាងណា មិនមានសេចក្តីរាយការណ៍ និយាយអំពីការឃាត់ខ្លួន ឬអត្តសញ្ញាណរបស់ក្រុមបុរសដែលបញ្ជាទិ ញសេវាផ្លូវភេទពីនារីខ្មែរក្មេងៗតាមរយៈជនសង្ស័យនោះទេ។ ក្រោយនាំខ្លួនយកទៅសាកសួរ ជនរងគ្រោះ ជាស្ត្រីអនីតិជន ចំនួន ៥នាក់ត្រូវសមត្ថកិច្ចអនុញ្ញាតឲ្យត្រលប់ទៅផ្ទះវិញ ចំណែកស្ត្រីឈ្មោះ ខន ចាន់ណារី ត្រូវបានសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនទៅតុលាការចាត់ការតាមច្បាប៕

## នគរបាលបញ្ជូនខ្លួនស្ត្រីជាម្ចាស់ហាង «ម៉ាស្សា» បង្កប់សេវាផ្លូវភេទ ទៅតុលាការចាត់ការតាមច្បាប់

https://www.chnchannel.com/article/ អត្ថបទដោយ Asmatt កាលបរិច្ឆេទ ថ្ងៃទី 8 ខែ កក្កដា ឆ្នាំ 2019

ភ្នំពេញ៖ កម្លាំងនគរបាលនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន នៅព្រឹក ថ្ងៃ ទី ០៧ ខែ កក្កដា ឆ្នាំ ២០១៩ បានបញ្ជូនខ្លួនស្ត្រីជាម្ចាស់ទីតាំងម៉ាស្សា បង្កប់សេវាផ្លូវភេទ ទៅកាន់ សាលាដំបូង រាជធានីភ្នំពេញ ដើម្បីចាត់ការបន្តតាមនីតិវិធី ។ របាយការណ៍ របស់ នគរបាល បានអោយដឹង ស្ត្រីម្ចាស់ទីតាំងមានឈ្មោះ ង្វៀង ធីងូធី ភេទស្រី អាយុភេទស្រី អាយុ៤០ឆ្នាំ ស្នាក់នៅទីតាំងម៉ាស្សាផ្ទះលេខ២២B ផ្លូវ២៨៨ សង្កាត់បឹងកេងកងទី២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

សូមរំលឹកថា កាលពីវេលាម៉ោង២និង០០ នាទីរសៀលនាថ្ងៃទី០៤ ខែកក្កដា ឆ្នាំ ២០១៩ កម្លាំងនគរបាលនៃនាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន សហការជាមួយនគរបាលមូល ដ្ឋានខណ្ឌបឹងកេងកង បានចុះប្រតិបត្តិការបង្ក្រាបទីតាំងម៉ាស្សាឃីហោ កោសជប់ម៉ាស្សា១ម៉ឺនរៀល ដែលស្ថិតនៅចំណុច ផ្ទះលេខ២២B ផ្លូវ

២៨៨ សង្កាត់បឹងកេងកងទី២ ខណ្ឌ បឹងកេងកង មានបង្កប់សេវាផ្លូវភេទ ដោយឃាត់ខ្លួនមនុស្សចំនួន៧នាក់ ក្នុងនោះស្ត្រីម្ចាស់ទីតាំង១ម្នាក់ នារីរងគ្រោះចំនួន៦នាក់ ។

ក្រោយពេលកម្លាំងនគរបាលបានឃាត់ខ្លួនមនុស្សចំនួន ៧នាក់ក្នុងនោះនារីរងគ្រោះចំនួន ៦នាក់ ស្ត្រីម្ចាស់ទីតាំងម្នាក់ និង ដកហូតវត្ថុតាងរួមមាន ស្រោមអនាម័យប្រើរួច និងមិន ទាន់ប្រើប្រាស់មួយចំនួនធំ បាននាំយកមកការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនដើម្បីបន្តការសាកសួរ ។ ចំណែកនារីរងគ្រោះទាំង៦នាក់នោះត្រូវបាន នគរបាល ប្រគល់ ជូនមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ៕

## ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៩

## កងកម្លាំងការពារព្រំដែនកម្ពុជា-ថៃ ប្រជុំសហការទប់ស្កាត់បទល្មើសឆ្លងដែន

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 09/07/2019

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងការពារព្រំដែនជួរមុខកម្ពុជា-ថៃ បានបន្តប្រជុំពិភាក្សាសហការគ្នាដើម្បីទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់និងរក្សាសុវត្ថិភាព តាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ។ កិច្ចប្រជុំបានធ្វើឡើងនៅព្រឹកថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៩នៅប៉ុស្តិ៍នគរបាលព្រំដែនចំបក់ ក្នុងទឹកដីកម្ពុជា។រវាង នគរបាលការពារព្រំដែនគោកលេខ៨១៥ ប៉ុស្តិ៍ព្រំដែនចំបក់ ប៉ុស្តិ៍ព្រំដែនសង្កែ និងកម្លាំងយោធាសឹករងម៉ាឡៃសរុប១១នាក់ ឈរជើងក្នុងភូមិសាស្ត្រស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ និងកម្លាំងទាហានឈុតខ្មៅថៃនៃកងអនុសេនាធំលេខ១៣០២ ចំនួន៦នាក់ ឈរជើងនៅភូមិសាស្ត្រស្រុកខ្លងហាត ខេត្តស្រះកែវ ប្រទេសថៃ។

កិច្ចប្រជុំកម្លាំងការពារព្រំដែនកម្ពុជាដឹកនាំដោយលោកអនុសេនីយ៍ឯក ឡុក ធី នាយប៉ុស្តិ៍នគរបាលការពារព្រំដែនសង្កែ នៃវរៈសេនាតូចនគរបាលការពារព្រំដែនគោក៨១៥ ចំណែកទាហានឈុតខ្មៅថៃដឹកនាំដោយលោកអនុសេនីយ៍ទោ សំភោគ ចាវ៉ាន់យ៉ាអន មេបញ្ជាការកងអនុសេនាធំលេខ១៣០២។លោក ឡុក ធី បានប្រាប់ឱ្យដឹងថា រវាងកងកម្លាំងជួរមុខការពារព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ និងភូមិសាស្ត្រស្រុកខ្លងហាត ស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃភាគីទាំង២ បានធ្វើឡើងជាងរៀងរាល់ខែគឺក្នុង១ខែជួបប្រជុំពិភាក្សាគ្នា១ដង។កិច្ចប្រជុំភាគីទាំង២បានជជែកនៃការពង្រឹងកិច្ចសហប្រតិបត្តិការរវាងគ្នានិងគ្នាឱ្យកាន់តែរឹងមាំ អនុវត្តតាមខ្លឹមសារនៃកិច្ចប្រជុំរបស់គណៈកម្មាធិការព្រំដែនរវាងយោធភូមិ៥កម្ពុជានិងយោធភូមិភាគ១ថៃ ដែលបានជួបប្រជុំនៅទីក្រុងបាងកកប្រទេសថៃកន្លងទៅថ្មីៗនេះ ឯកភាពគ្នាលើកិច្ចសហប្រតិបត្តិការចុះល្បាតតាមព្រំដែនដើម្បីទប់ស្កាត់ការលបលួចកាប់ឈើខុសច្បាប់,ការប្រយុទ្ធប្រឆាំងការជួញដូរគ្រឿងញៀន, ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនខុសច្បាប់។

លោកអនុសេនីយ៍ឯក ឡុក ធី នាយប៉ុស្តិ៍នគរបាលការពារព្រំដែនសង្កែ នៃវរៈសេនាតូចនគរបាលការពារព្រំដែនគោក៨១៥ បានលើកឡើងទៀតថា រវាងកងកម្លាំងការពាព្រំដែនជួរមុខកម្ពុជា-ថៃ នៅក្នុងភូមិសាស្ត្រស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ និងភូមិសាស្ត្រស្រុកខ្លងហាត និងស្រុកអារញ្ញ ខេត្តស្រះកែវប្រទេសថៃ កន្លងមកសហការគ្នាបានល្អ ដោយធ្លាប់ទប់ស្កាត់ និងបង្ក្រាបបានករណីជួញដូរអាវុធខុសច្បាប់កាលពីប៉ុន្មានឆ្នាំកន្លងទៅនេះ និងបទល្មើសឆ្លងដែនខុសច្បាប់មួយចំនួនទៀតផងដែរ។ លោកនាយប៉ុស្តិ៍ក៏បានស្នើសុំឱ្យទាហានឈុតខ្មៅថៃក៏ដូចជាប្រជាពលរដ្ឋថៃកុំធ្វើអ្វីប៉ះពាល់ដល់ការប្រែប្រួលបន្ទាត់ព្រំដែន ដែលមិនទាន់មានការទទួលស្គាល់ដោយគណៈកម្មាធិការព្រំដែននៃប្រទេសទាំង២។ មិនតែប៉ុណ្ណោះលោកក៏ស្នើសុំឱ្យភាគីថៃជួយសម្រួលដល់ពលករខ្មែរដែលឆ្លងដែនធ្វើការងារទៅព្រឹកវិលល្ងាចក្នុងប្រទេសថៃឱ្យមានសុវត្ថិភាពល្អ។ក្នុងករណីដែលមានការឆ្លងដែនខុសច្បាប់ពីសំណាក់ពលករខ្មែរ ចូលក្នុងទឹកដីថៃ សូមឱ្យភាគីថៃមានការយោគយល់កុំប្រើអំពើហឹង្សារឺបាញ់សម្លាប់ជាដើមនោះ។ ជាងនេះថែមទៀតបើកើត

មានបញ្ហាតាមបន្ទាត់ព្រំដែនត្រូវជូនដំណឹងគ្នាទៅវិញទៅមក ដើម្បីប្រជុំពិភាក្សារកដំណោះស្រាយតាមសន្តិវិធី បញ្ចៀសការតានតឹងដាក់គ្នាដោយកម្លាំងប្រដាប់អាវុធ។ ក្នុងកិច្ចពិភាក្សារវាងកងកម្លាំងជួរមុខនៃប្រទេសទាំង២ ក៏បានធ្វើឡើងក្នុងបរិយាកាសស្និតស្នាល សាមគ្គីភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការកាន់តែល្អប្រសើរ៕

## ពលរដ្ឋខ្មែរ៧០នាក់ត្រូវអាមេរិកបញ្ជូនមកកម្ពុជាវិញគិតត្រឹមពាក់កណ្តាលឆ្នាំ២០១៩

http://km.rfi.fr/cambodia/ ដោយ អេង គីមហុង 07/07/2019

យ៉ាងហោចណាស់ ពលរដ្ឋខ្មែរអាមេរិកាំងចំនួន៧០នាក់ ដែលធ្លាប់ប្រព្រឹត្តបទឧក្រិដ្ឋនៅសហរដ្ឋអាមេរិក ត្រូវបានបញ្ជូនមកដល់ប្រទេសកម្ពុជា គិតត្រឹមថ្ងៃទី៤ខែកក្កដា ឆ្នាំ២០១៩នេះ។ រាប់ចាប់តាំងពីការចុះកិច្ចព្រមព្រៀងរវាងកម្ពុជាអាមេរិក នៅក្នុងឆ្នាំ២០០២ រហូតមកទល់ពេលនេះ អាមេរិកបានបញ្ជូនពលរដ្ឋខ្មែរអាមេរិកកាំងត្រឡប់មកកម្ពុជាវិញ ជាង៧០០នាក់ហើយ។

ថ្លែងប្រាប់វិទ្យុបារាំងអន្តរជាតិRFI នៅថ្ងៃអាទិត្យនេះ មន្ត្រីជាន់ខ្ពស់ផ្នែកអត្តសញ្ញាណកម្មបានគូសបញ្ជាក់ថា ៦ខែក្នុងឆ្នាំ២០១៩ ពលរដ្ឋខ្មែរអាមេរិកកាំង៧០នាក់ ត្រូវអាមេរិកបញ្ជូនមកកម្ពុជាវិញ ដោយលើកទីមួយមានចំនួន ៣៣នាក់ បញ្ជូនមកកាលពីដើមឆ្នាំ២០១៩ ខណៈលើកទីពីរ ៣៧នាក់មកដល់នៅដើមខែកក្កដានេះ។ បើតាមភ្នាក់ងារអនុវត្តច្បាប់អន្តោប្រវេសន៍អាមេរិក ពលរដ្ឋខ្មែរ៣៧នាក់បញ្ជូនមកនេះ ភាគច្រើនជាប់ពាក់ព័ន្ធ នឹងការប្រព្រឹត្តបទឧក្រិដ្ឋកម្ម ដោយក្នុងនោះរួមមាន ឃាតកម្ម រំលោភបំពានលើកុមារ បង្កហិង្សាក្នុងគ្រួសារ ជួញដូរនិងប្រើប្រាស់គ្រឿងញៀនជាដើម។

ប៉ុន្តែយ៉ាងណាក៏ដោយ ក្រោយមកដល់ប្រទេសកម្ពុជា អាជ្ញាធរនឹងធ្វើសមាហរណកម្មពួកគេជាមួយពលរដ្ឋខ្មែរទូទៅ ដោយផ្តើមដំបូងគឺ ផ្តល់សំបុត្រកំណើត សៀវភៅស្នាក់នៅ និងការធ្វើអត្តសញ្ញាណប័ណ្ណជាដើម។ ចំណែកពលរដ្ឋខ្មែរដែលបណ្តេញចេញពីសហរដ្ឋអាមេរិកមួយក្រុមមុន បានរៀបចំធ្វើយុទ្ធនាការ រៃអង្គាសប្រាក់សម្រាប់ជួយផ្គត់ផ្គង់ដល់អ្នក៣៧នាក់ដែលទើបបញ្ជូនមកថ្មី។

ទោះជាបែបនេះក្តី អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ Human Rights Watch កាលពីថ្ងៃទី៥ខែកក្កដា បានស្នើឲ្យអាមេរិកបញ្ឈប់ការចាប់បញ្ជូនពលរដ្ឋខ្មែរមកកម្ពុជាទៀតទៅ ចំពោះអ្នកដែលបានស្តារនីតិសម្បទារួច។ សម្រាប់ Human Rights Watch ការចាប់បញ្ជូនបែបនេះ ដូចជាធ្វើឲ្យពួកគាត់ទទួលរងទណ្ឌកម្មទ្វេដង តាមរយៈការទទួលទោសដោយជាប់ពន្ធនាគារនៅសហរដ្ឋអាមេរិកម្តងហើយ ដល់ចុងក្រោយក៏ត្រូវនិរទេសខ្លួនអស់មួយជីវិត ទៅរស់នៅប្រទេសកម្ពុជា។

សូមជម្រាបថា គិតមកដល់ពេលនេះ ពលរដ្ឋខ្មែរអាមេរិកកាំងជាង៧០០នាក់ហើយ ត្រូវបានបញ្ជូនមកកម្ពុជា បន្ទាប់ពីកម្ពុជានិងអាមេរិក ចុះកិច្ចព្រមព្រៀងរួមគ្នាក្នុងឆ្នាំ២០០២។ក្នុងចំណោមពួកគេ មួយចំនួនបានក្លាយខ្លួនជាអ្នកជំនួញ និងគ្រូបង្រៀនភាសាអង់គ្លេសជាដើម។ នេះបើតាមអង្គការKVAO៕

## ដំណឹងល្អសំរាប់បងប្អូនពលករនៅប្រទេសថៃគួរអាន

https://www.facebook.com/ ទឹកចិត្ត ពលករ ឆ្លងដែន 08-07-2019

យោងតាមពត៌មានចេញពីក្រសួងការងារថៃ បានអោយដឹងថា ខណៈរដ្ឋមន្ត្រីថៃ បានប្រជុំនៅថ្ងៃច័ន្ទទី8 ខែ7 ឆ្នាំ2019 បានអោយដឹងថា ខណៈរដ្ឋមន្ត្រីថៃបានព្រមព្រាងអនុញ្ញាតពលករទាំងបីប្រទេសដូចជា ពលករជនជាតិភូមារ នឹងពលករជនជាតិឡាវ នឹងពលករកម្ពុជា ដែលមានបែអនុញ្ញាតធ្វើការដែលជាច់អាយុមុនខែ12 ឆ្នាំ2019 នឹងពលករមួយក្រុមទៀតដែលមានបែអនុញ្ញាតធ្វើការដាច់អាយុនៅថ្ងៃទី31-3-2020 ពលករទាំងអស់នេះត្រូវដំណើរការតាមបេប MOU នៅក្នុងប្រទេសថៃបាន ដោយមិនចាំបាច់ចុះទៅធ្វើនៅខ្មែរ។ សម្រាប់ការដំណើរការតេវីសារ និងបែអនុញ្ញាតធ្វើ

ការរបស់បងប្អូនពលករ ខណៈរដ្ឋមន្ត្រីថៃបានអនុញ្ញាតអោយក្រសួងក្រសួងការងារថៃនឹង(តម៉)ថៃចាប់ផ្តើមដំណើរការតវីសារនិងបែអនុញ្ញាតធ្វើការអោយបងប្អូនពលករទាំងបីប្រទេសបានចាប់ផ្តើមតាំងតែថ្ងៃទី15 ខែ8 ឆ្នាំ2019នេះរហូតដល់ថ្ងៃទី31-3-2020 ទើបផុតកំណត់ ខ្ញុំសូមបញ្ជាក់ប្រាប់បងប្អូនពលករខ្មែរអោយបានជ្រាបថា សម្រាប់បងប្អូនពលករដែលមានបែអនុញ្ញាតធ្វើការផុតកំណត់មុនខែ12 ឆ្នាំ2019 ត្រូវប្រញ៉ាប់ដំណើរការសុំតវីសារនៅ(តម៉)ថៃ និងសុំតបែអនុញ្ញាតធ្វើការនៅក្រសួងការងារថៃបានចាប់ពីខែ8 ឆ្នាំ2019 នៅតទៅ សម្រាប់ពលករដែលមានបែអនុញ្ញាតធ្វើការដាច់អាយុនៅថ្ងៃទី31-3-2020 បងប្អូនពលករត្រូវដំណើរការសុំត(វីសារ)និងបែអនុញ្ញាតធ្វើការរបស់បងប្អូនពលករអោយរួចរាល់មុន90ថ្ងៃ មុនបែអនុញ្ញាតធ្វើការផុតកំណត់នៅថ្ងៃទី31-3-2020 ។

បើបងប្អូនពលករដំណើរការសុំតវីសារ និងបែអនុញ្ញាតធ្វើការរបស់បងប្អូនពលករមិនទាន់កំណត់ដូចដែលបានបញ្ជាក់នៅខាងលើទេបងប្អូនពលករមិនអាចធ្វើការនៅប្រទេសថៃបានទៀតទេ បងប្អូនពលករបើចង់ធ្វើការនៅប្រទេសថៃបន្តទៀត ត្រូវធ្វើ MOU ពីខ្មែរមកវិញទើបធ្វើការនៅប្រទេសថៃបាន (អំពីខ្ញុំ ទឹកចិត្ត ពលករ ឆ្លងដែន) ផ្សាយនៅថ្ងៃទី9-7-2019 ដកស្រង់ពត៍មានចេញពីក្រសួងការងារថៃចុះផ្សាយនៅថ្ងៃទី8-7-2019។

## មហាសេដ្ឋីអាមេរិកម្នាក់ រងការចោទប្រកាន់ពីបទជួញដូរនិងរួមភេទជាមួយអនីតិជន

http://www.freshnewsasia.com/ 2019-07-08

**(ញូយ៉ក)៖** មហាសេដ្ឋីអាមេរិកម្នាក់ឈ្មោះ Jeffrey Epstein ត្រូវបានរដ្ឋអាជ្ញាអាមេរិកចោទប្រកាន់ពីបទជួញដូរ និងរួមភេទជាមួយ ក្មេងស្រីៗដែលជាអនីតិជន។ នេះបើតាមការដកស្រង់ការផ្សាយចេញពីសារព័ត៌មាន CNBC នៅយប់ថ្ងៃចន្ទ ទី០៨ ខែកក្កដា ឆ្នាំ២០១៩។ លោក Epstein វ័យ៦៦ឆ្នាំ បានរងការចោទប្រកាន់ពីបទជួញដូរ និងរួមភេទជាមួយក្មេងស្រីជាច្រើននាក់ ដែលមានវ័យក្រោម១៨ឆ្នាំ កាលពីចន្លោះឆ្នាំ២០០២ និងឆ្នាំ២០០៥ នៅរដ្ឋញូយ៉កនិងរដ្ឋផ្លរីដា ដោយក្មេងស្រីខ្លះមានអាយុត្រឹមតែ១៤ឆ្នាំថែមទៀតផង នាពេល នោះ។

បើតាមរដ្ឋអាជ្ញាអាមេរិក លោក Epstein តែងបានឲ្យក្មេងស្រីទាំងនោះនូវលុយរាប់រយដុល្លារ ក្រោយត្រូវបានលួងលោមឲ្យរួមភេទជាមួយលោក នៅឯភូមិគ្រឹះក្នុងសង្កាត់ Manhattan ក្នុងទីក្រុងញូយ៉កនៃរដ្ឋញូយ៉ក ឬនៅភូមិគ្រឹះមួយទៀតក្នុងទីក្រុង Palm Beach នៃរដ្ឋផ្លរីដា។ ជាដំបូងក្មេងស្រីទាំងនោះ ត្រូវបានបញ្ឆោតឲ្យទាក់ទងជាមួយលោក Epstein ក្រោមលេសថា ពួកគេនឹងគ្រាន់តែផ្តល់ការ ម៉ាស្សា ធ្វើ សសៃឲ្យមហាសេដ្ឋីរូបនេះប៉ុណ្ណោះ។ បន្ថែមពីនេះដើម្បីរក្សាក៏ដូចជាបង្កើនចំនួនក្មេងស្រីសម្រាប់បំពេញតណ្ហារបស់ខ្លួន លោក Epstein ក៏បានទិញទឹកចិត្តក្មេង ស្រីមួយចំនួន ដែលជាជនរងគ្រោះរបស់លោក ឲ្យទាក់ទាញក្មេងស្រីដែលជាអនីតិជនផ្សេងៗទៀត ដើម្បីយកមកឲ្យខ្លួនរំលោភបំពាន ស្រដៀងគ្នាផងដែរ។ តាមរយៈវិធីសាស្ត្រនេះ លោក Epstein បានបង្កើតនូវបណ្តាញដ៏ធំមួយនៃជនរងគ្រោះជាអនីតិជន សម្រាប់ការសប្បាយផ្លូវភេទរបស់ខ្លួន។ រដ្ឋអាជ្ញាអាមេរិកបានអះអាងទៀតថា លោក Epstein ក៏បានរួមគំនិតនិងសហការជាមួយបុគ្គលដទៃទៀត ដែលបានជួយលោក តាមរយៈការទាក់ទងជាមួយជនរងគ្រោះ ហើយរៀបចំឲ្យពួកគេទៅជួបលោកផងដែរ។ ម្យ៉ាងវិញទៀត ការបំពានផ្លូវភេទទៅលើ អនីតិជននេះ គឺលោក Epstein បានប្រព្រឹត្តទាំងខ្លួនដឹងច្បាស់ថា ក្មេងស្រីទាំងនោះ សុទ្ធតែមានអាយុក្រោម១៨ឆ្នាំ។

គួរជម្រាបថា លោក Jeffrey Epstein ត្រូវបានចាប់ខ្លួននៅរដ្ឋ New Jersey កាលពីថ្ងៃសៅរ៍សប្តាហ៍មុនក្រោយពីលោក បាន ត្រឡប់ មកពីប្រទេសបារាំង។ លោក Epstein ក៏ធ្លាប់មានទំនាក់ទំនងជិតស្និទ្ធិជាមួយបុគ្គលល្បីៗនៅអាមេរិក រួមមានអតីតប្រធានាធិបតីអាមេរិក លោក ប៊ីល គ្លីនតុន និងប្រធានាធិបតីអាមេរិក លោក ដូណាល់ត្រាំ ជាដើមថែមទៀតផង៕

# ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១៩

## ឃាត់ខ្លួនស្ត្រីវ័យចំណាស់ម្នាក់ពីបទឆបោក និងធ្វើអាជីវកម្មលើផ្លូវភេទ

http://ppd-news.net/ ថ្ងៃចេញផ្សាយ: July 10, 2019

ខេត្តក្រចេះ ៖ ដោយមានចង្អុលបង្ហាញ អនុញ្ញាតិពីលោកព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តក្រចេះ នៅថ្ងៃទី០៩ខែកក្កដា ឆ្នាំ ២០១៩ម្សិលមិញ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន បានធ្វើការឃាត់ខ្លួនស្ត្រីវ័យចំណាស់ម្នាក់ជាមេខ្យល់ឆបោក និងធ្វើអាជីវកម្មលើផ្លូវភេទ យកមកធ្វើការសួរនាំ និងកសាងសុំណុំរឿង ចាត់ការតាមផ្លូវច្បាប់។

តាមរបាយការណ៍បានបង្ហាញថា កាលពីអំឡុង ខែកក្កដា ឆ្នាំ២០១៨ មេខ្យល់ ឈ្មោះ ថាប់ ឆេងលឹង ភេទស្រី អាយុ៦៦ឆ្នាំ មានទីលំនៅភូមិរកាធំ ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ បានមកផ្ទះ ឈ្មោះ ឆាយ ប៉ាត ឃោសនាអូសទាញឲ្យចៅស្រីរបស់គាត់ ឈ្មោះ ប៉ាត គុន្ធា អាយុ១៥ឆ្នាំទៅធ្វើការនៅប្រទេសចិន មានប្រាក់ឈ្នួលខ្ពស់ ហើយរាល់ការចំណាយផ្សេងៗ មេខ្យល់ជាអ្នកចំណាយទាំងអស់។ ដោយជឿតាមការឃោសនានេះ ឈ្មោះ ឆាយ ប៉ាត និងជនរងគ្រោះក៏យលព្រម។ របាយការណ៍បន្តថា នៅអំឡុងខែសីហា ឆ្នាំ២០១៩ មេខ្យល់បានឲ្យឈ្មោះ ឆាយ ប៉ាត នាំចៅស្រីឡើងមកភ្នំពេញ ដោយមានឈ្មោះ ម៉ុក ឱុល ភេទប្រុស អាយុប្រហែល៤៥ឆ្នាំ កូនបង្កើតរបស់ឈ្មោះ ថាប់ ឆេងលឹង យកម៉ូតូកង់បីមកទទួល យកទៅផ្ទះជួលមួយកន្លែង ម្តុំផ្សារបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល។ របាយការណ៍បន្តទៀតថា ពេលនោះបានជួប ឈ្មោះ ថាប់ ឆេងលឹង និងស្នាក់នៅទីនោះអស់ រយៈពេលបីយប់ ទើបឈ្មោះ ឆាយ ប៉ាត វិលត្រឡប់មកផ្ទះឯខេត្តក្រចេះវិញ ដោយទុកចៅស្រីនៅផ្ទះឈ្មោះ នាទ ដើម្បីរៀបចំឯកសារ និងបញ្ជូនទៅប្រទេសចិន។

របាយការណ៍បញ្ជាក់ថា រហូតរយៈ២០ថ្ងៃ ក្រោយមក ឈ្មោះ ថាប់ ឆេងលឹង ត្រឡប់មកដល់ផ្ទះនៅរកាធំ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះវិញ ហើយក៏មកផ្ទះ ឆាយ ប៉ាត ប្រាប់ថា ចៅស្រីបានទៅដល់ប្រទេសចិនហើយ និងបានឲ្យលុយចំនួន៥០០ដុល្លារ ទៅឈ្មោះ ឆាយ ប៉ាត ដោយប្រាប់ថា ចៅស្រីផ្ញើមក។ លុះដល់មួយខែក្រោយមកឈ្មោះ ថាប់ ឆេងលឹង បានប្រាប់ទៅឈ្មោះ ឆាយ ប៉ាត ថា ចៅស្រីសុខសប្បាយទេ។ ហើយចាប់ពីពេលនោះមកបាត់ដំណឹងចៅស្រីរហូត ពេលដែលទៅសួរដំណឹងចៅស្រី ឈ្មោះ ថាប់ ឆេងលឹង ឆ្លើយដោះ សារតែរហូត។ ចំណែកនាង ប៉ាត គន្ធា ត្រូវបានមេខ្យល់យកទៅលក់ ឲ្យបុរសម្នាក់ជាជនជាតិធ្វើជាប្រពន្ធ។ ហើយត្រូវបានសមត្ថកិច្ចចិនចាប់ឃុំខ្លួនអស់រយៈពេល៦ខែ ទើបបញ្ជូនឲ្យត្រឡប់មកកម្ពុជាវិញនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ថ្មីៗនេះ៕ ដោយ ស៊ានច័ន្ទដា

## ថៃបញ្ជូនពលករខ្មែរ ២១នាក់មកកម្ពុជាវិញ

https://www.dap-news.com/archives/ ByID:030 Posted on 09 July 2019 | 21:54

ភ្នំពេញ៖មន្ត្រី ស្ថានអគ្គកុងស៊ុលខ្មែរ សហការជាមួយសមត្ថកិច្ច នគរបាល អន្តោប្រវេសន៍ខេត្តសាកែវ ប្រទេសថៃ ទទួល និងជូនដំណើរពលករខ្មែរសរុប ២១នាក់ (ប្រុស ១៥នាក់) ត្រឡប់ទៅកម្ពុជាវិញ តាមច្រកអន្តរជាតិ ប៉ោយប៉ែត នៅរសៀលថ្ងៃ ទី ៩ ខែកក្កដា ឆ្នាំ ២០១៩។ ពលករទាំង ២១នាក់ខាងលើ ត្រូវបានសមត្ថកិច្ចចម្រុះខេត្តសាកែវ ចាប់ឃាត់ខ្លួនពីបទធ្វើការដោយគ្មានច្បាប់ អនុញ្ញាតកាលពីថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០១៩ នៅស្រុកវ៉ាំងណាមយេន ខេត្តសាកែវ ។ សមត្ថកិច្ច ថៃបានធ្វើការ ផាកពិន័យពួកគាត់ ១ម៉ឺនបាត ក្នុងម្នាក់ ៗ។ ដោយមានការសម្រួលរវាងស្ថាប័នពាក់ព័ន្ធ ថៅកែជនជាតិថៃបានចេញ ថ្លៃផាកពិន័យជំនួសបងប្អូនទាំង ២១នាក់៕

## មនុស្សរាប់សិបនាក់ ត្រូវគេរកឃើញជាប់តែលតោលនៅរដ្ឋរ៉ាក់ឃីននៃមីយ៉ាន់ម៉ា

https://www.postkhmer.com/ AFP | Publication date 10 July 2019 | 12:02 ICT

**ក្រុងយ៉ាំងហ្គោនៈ** មន្ត្រីម្នាក់បានថ្លែងកាលពីថ្ងៃចន្ទថា មនុស្សជាង ៦០ នាក់ ត្រូវបានគេរកឃើញជាប់តែលតោលនៅក្បែរទូកមួយនៅរដ្ឋរ៉ាក់ឃីននៃប្រទេស មីយ៉ាន់ម៉ា ជាច្រកផ្លូវជួញដូរមនុស្សមួយកន្លែងសម្រាប់ក្រុមជនមូស្លីមរ៉ូហ៊ីងយ៉ាដែលត្រូវគេធ្វើទុក្ខបុកម្នេញ ហាក់ដូចបើកចំហឲ្យជួញដូរមនុស្ស ទោះបីជាមានការបង្ក្រាបក្តី។

កាលពីដើមឆ្នាំ ជនរ៉ូហ៊ីងយ៉ារាប់ពាន់នាក់ និងជាពលរដ្ឋបង់ក្លាដែសគ្មានសញ្ជាតិ បានព្យាយាមធ្វើដំណើរទៅប្រទេស ម៉ាឡេស៊ី ឬឥណ្ឌូនេស៊ីតាមសមុទ្រ។ ប៉ុន្តែទូកដឹកជនរ៉ូហ៊ីងយ៉ា ជាទូទៅត្រូវបានគេបង្ក្រាបនៅឆ្នេរសមុទ្រមីយ៉ាន់ម៉ា ឬប្រទេស ថៃ ជាពិសេសនៅក្នុងស្ថានភាពដ៏គ្រោះថ្នាក់ ដែលបង្កឡើងដោយភ្លៀងរដូវវស្សា។

អភិបាលស្រុកលោក Soe Aung បានថ្លែងប្រាប់ AFP ចេញពីសង្កាត់ Maungdaw នៅរដ្ឋរ៉ាក់ឃីនភាគខាងជើងថា «ជនមូស្លីម» ៦៣ នាក់ ត្រូវបានគេប្រទះឃើញកាលពីព្រឹកថ្ងៃអាទិត្យ ហើយបានចាប់បញ្ជូនទៅកាន់ប៉ុស្តិ៍ប៉ូលិស ដែលនៅជិតនោះ។ លោក Soe Aung បានថ្លែងប្រាប់តាមទូរស័ព្ទថាៈ «យើងបានរកឃើញបុរស ៤ នាក់ នៅលើទូក និងអ្នកផ្សេងៗទៀតនៅក្បែរនោះផងដែរ។ សរុបទៅមានមនុស្សចំនួន ៦៣ នាក់» ដោយបានបន្ថែមថា វានៅមិនទាន់ដឹងច្បាស់នៅឡើយទេ ថាតើពួកគេជាពលរដ្ឋបង់ក្លាដែស ឬជាជនរ៉ូហ៊ីងយ៉ាយ៉ាងណានោះទេ។

ក្រុមមន្ត្រីមីយ៉ាន់ម៉ា មិនទទួលស្គាល់ជនរ៉ូហ៊ីងយ៉ានោះថា ជាក្រុមជនជាតិភាគតិចទេ ហើយនិយាយសំដៅទៅលើពួកគេថា ជាក្រុមបែងហ្គាល់ ឬជាក្រុមជនមូស្លីមមកពីរដ្ឋរ៉ាក់ឃីន។ ក្រុមអាជ្ញាធរ បានព្យាយាមបិទផ្លូវមិនឲ្យមានការជួញដូរមនុស្ស ដែលមានទឹកប្រាក់រាប់លានដុល្លារកាលពីឆ្នាំ ២០១៥ ក្រោយពីបានរកឃើញផ្នូរកប់សាកសពយ៉ាងច្រើននៅប្រទេសថៃ ភាគខាងត្បូង។ ប៉ុន្តែមានមនុស្សជាច្រើននៅតែលះបង់ជីវិតរបស់ពួកគេ ដើម្បីឡើងទូកធ្វើដំណើរតាមសមុទ្រប្រកបដោយគ្រោះថ្នាក់នោះ។ ចំណែកឯក្រុមជនមូស្លីមរ៉ូហ៊ីងយ៉ា ដែលកំពុងរស់នៅក្នុងរដ្ឋរ៉ាក់ឃីននៃប្រទេសមីយ៉ាន់ម៉ា នាពេលបច្ចុប្បន្ននេះកំពុងក្លាយទៅជាជនរងគ្រោះរបស់ក្រុមឈ្មួញជួញដូរមនុស្សខុសច្បាប់៕

# ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៩

## ៣យប់ នគរបាលប៉ុស្តិ៍រដ្ឋបាលវត្តភ្នំ ចាប់ប្រមូលស្រ្តីរកស៊ីផ្លូវ និងអ្នកក្អកជេស្រីបានជិត៣០នាក់

http://kampucheathmey.com/ 10/7/2019 1:56 Pm **ដោយ ៖ វស្នី**

ភ្នំពេញ ៖ ស្រីរកស៊ីផ្លូវភេទ ក៏ដូចជាក្រុមកាងស្រី និងខ្ទើយរកស៊ីផ្លូវភេទ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលវត្តភ្នំ ធ្វើការចាប់ប្រមូលក្នុងរយៈពេល០៣ថ្ងៃជាបន្តបន្ទាប់នេះ ដោយឃាត់បានជិត៣០នាក់ បញ្ជូនទៅអប់រំនៅមន្ទីរសង្គមកិច្ច។

លោក ហៅ ស៊ីនិត ចៅសង្កាត់វត្តភ្នំ និងលោកអ៊ុន សំអាត មេប៉ុស្តិ៍វត្តភ្នំ បានឲ្យដឹងថា ដោយអនុវត្តតាមការណែនាំរបស់លោកសុខ ពេញវុធ អភិបាល នៃគណៈអភិបាលខណ្ឌដូនពេញ ដែលបានជំរុញឲ្យប៉ុស្តិ៍ និងសង្កាត់ ត្រូវធ្វើយ៉ាងណាត្រូវតែរក្សាឲ្យបាននូវសន្តិសុខសណ្តាប់ធ្នាប់ឲ្យមានរបៀបរៀបរយបានល្អប្រសើរនៅក្នុងមូលដ្ឋានរបស់ខ្លួននោះ ជាក់ស្តែងនៅបីយប់ជាប់គ្នានេះ កម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលវត្តភ្នំ និងសង្កាត់វត្តភ្នំបាន ចាប់ប្រមូលនូវស្ត្រីរកស៊ីផ្លូវភេទ និងខ្ទើយរកស៊ីផ្លូវភេទ រួមជាមួយក្រុមអ្នកកាងស្រី ដែលតែងតែប្រពាក់ប្រពូននៅតាមសួនច្បារ ជាពិសេសនៅតាមសួនច្បារវត្តភ្នំ និងសួនច្បារមុខសាលានីម ត្រូវបានប្រមូលបន្តបន្ទាប់សរុប២៥នាក់។

លោកអ៊ុន សំអាត មេប៉ុស្តិ៍វត្តភ្នំ បានបញ្ជាក់ទៀតថា ជាក់ស្តែងករណីទី១ នៅវេលាម៉ោង២០យប់ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៩ កម្លាំងជំនាញខណ្ឌ ប៉ុស្តិ៍នគរបាលវត្តភ្នំបានចុះបង្ក្រាប ករណីស្ត្រីរកស៊ីផ្លូវភេទ និងអ្នកក្អកជេ (អ្នកចាប់ម៉ូយ) ស្ថិតនៅចំណុចផ្លូវលេខ៩២. ៩៤. ៩៦ និងជុំវិញរង្វង់មូលវត្តភ្នំ។ ជាលទ្ធផល នៃកិច្ចប្រតិបត្តិការនេះ បាន

បញ្ចប់នៅវេលាម៉ោង២យប់រំលងអធ្រាត្រ ចូលថ្ងៃទី០៨កក្កដា សមត្ថកិច្ចប្រមូលបានសរុបរួមចំនួន០៩នាក់ ក្នុងនោះប្រុសខ្ទើយចំនួន០៣នាក់ ស្រី០៦នាក់។

ករណីទី២ នៅថ្ងៃទី៨ ខែកក្កដា វេលាម៉ោង២០និង០០នាទី កម្លាំងជំនាញខណ្ឌ .ប៉ុស្ដិ៍នគរបាលវត្តភ្នំបានចុះបង្ក្រាប ករណីស្ត្រីរកស៊ីផ្លូវភេទ និងអ្នកក្ជកជេ(អ្នកចាប់ម៉ូយ) ស្ថិតនៅចំណុចផ្លូវលេខ៩២. ៩៤. ៩៦ និងជុំវិញរង្វង់មូលវត្តភ្នំ។ ជាលទ្ធផល នៃកិច្ចប្រតិបត្តិការនេះ បានបញ្ចប់នៅវេលាម៉ោង០២រំលងអធ្រាត្រឈានចូលថ្ងៃទី០៩ សមត្ថកិច្ចប្រមូលបានសរុបរួមចំនួន០៨នាក់ ក្នុងនោះប្រុសចំនួន០១នាក់ ស្រី០៧នាក់។

ករណីទី៣ នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង២០និង០០នាទី កម្លាំងជំនាញខណ្ឌ .ប៉ុស្ដិ៍នគរបាលវត្តភ្នំបានចុះបង្ក្រាប ករណីស្ត្រីរកស៊ីផ្លូវភេទ និងអ្នកក្ជកជេ(អ្នកចាប់ម៉ូយ) ស្ថិតនៅចំណុចផ្លូវលេខ៩២. ៩៤. ៩៦ និងជុំវិញរង្វង់មូលវត្តភ្នំ។ ជាលទ្ធផល នៃកិច្ចប្រតិបត្តិការនេះ បានបញ្ចប់នៅវេលាម៉ោង០២ និង០០នាទី រំលងអធ្រាត្រចូលថ្ងៃទី១០កក្កដា សមត្ថកិច្ចយើងប្រមូល បានសរុបរួមចំនួន០៨នាក់ ក្នុងនោះខ្ទើយប្រុស០៣នាក់ និងស្រី០៥នាក់។ ចំពោះមុខ អធិការដ្ឋាន បានបញ្ជូនស្ត្រីរកស៊ីផ្លូវភេទ និងអ្នកក្ជកជេខាងលើ ទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ៕

## បើកសិក្ខាសាលាពិគ្រោះយោបល់សម្រាប់ទីភ្នាក់ងារជ្រើសរើសពលករ

https://www.facebook.com/ អគ្គនាយកដ្ឋានការងារ General Department of Labour 11-07-2019

នៅថ្ងៃព្រហស្បតិ៍ ១០កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ នៅសណ្ឋាគារសោម៉ាទេវីអង្គរីសត ខេត្តសៀមរាប ឯកឧត្តម ហ៊ូ វុឌ្ឍី អនុរដ្ឋលេខា តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បើកសិក្ខាសាលាពិគ្រោះយោបល់សម្រាប់ទីភ្នាក់ងារជ្រើសរើសពលករ ស្ដីពីការអនុលោមតាមការជ្រើសរើសពលករដោយក្រមសីលធម៌ និងរាជបញ្ញត្តិរបស់ប្រទេសថៃ ស្ដីពីការនាំពលករទេសន្តរប្រវេសន៍ទៅធ្វើការជាមួយនិយោជកនៅក្នុងប្រទេសថៃ។

## មន្ត្រីនៃអគ្គនាយកដ្ឋានការងារ បានធ្វើការណែនាំតម្រង់ទិសដល់កម្មសិក្សាការី ដែលត្រូវចេញទៅធ្វើកម្មសិក្សានៅបរទេស

https://www.facebook.com/ អគ្គនាយកដ្ឋានការងារ-General Department of Labour July 2 at 4:10 PM •

នាថ្ងៃអង្គារ៍១កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ នៅទីស្ដីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ត្រីនៃអគ្គនាយកដ្ឋានការងារ បានធ្វើការណែនាំតម្រង់ទិសដល់កម្មសិក្សាការី ដែលត្រូវចេញទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន សឹង្ហបូរី និងហុងកុង សរុបចំនួន ៤៨នាក់ (ស្រី១៦នាក់)។ វគ្គសិក្សានេះរៀបចំឡើងក្នុងគោលបំណងផ្ដល់ចំណេះដឹងដល់កម្មសិក្សាការី ឱ្យមានការយល់ដឹងអំពីៈ

១-ការរៀបចំខ្លួន ដើម្បីធ្វើការនៅបរទេស
២-ភូមិសាស្ត្រ បរិស្ថាន និងវប្បធម៌នៅបរទេស
៣-ការធ្វើដំណើរតាមផ្លូវ និងការមកដល់បរទេស
៤-ការធ្វើការងារ និងការរស់នៅក្នុងបរទេស
៥-ការគ្រប់គ្រងប្រាក់
៦-សុខភាព និងអនាម័យ
៧-ការធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ
៨-សុវត្ថិភាព និងសេវាគាំទ្រ។

ក្រុមហ៊ុនដែលបានបញ្ជូនកម្មសិក្សាការី ទទួលការបណ្តុះបណ្តាលក្នុវគ្គនេះមានចំនួន៩ គឺ

១. ក្រុមហ៊ុន Ung Rithy
២. ក្រុមហ៊ុន Axel
៣.ក្រុមហ៊ុន Agri Farmer
៤.ក្រុមហ៊ុន Big Bi
៥. ក្រុមហ៊ុន Kei Kei
៦. ក្រុមហ៊ុន International Easy Reach
៧. ក្រុមហ៊ុន Master Cam
៨. ក្រុមហ៊ុន Nicam
៩. ក្រុមហ៊ុន PITT

## នគរបាលខេត្តភ្នំ ប្រតិបត្តិការប្រមូលនារីរកស៊ីផ្លូវភេទ ជុំវិញរង្វង់មូលខេត្តភ្នំ ឃាត់ខ្លួន៤នាក់

https://www.dap-news.com/ ByID:112 Posted on 11 July 2019 | 10:48

ភ្នំពេញ ៖ កម្លាំង ប៉ុស្តិ៍នគរបាលវត្តភ្នំ បានចុះបង្ក្រាប ស្ត្រីរកស៊ីផ្លូវភេទ និងអ្នកគួកជេរស្រី ស្ថិតនៅចំណុចផ្លូវលេខ ៩២. ៩៤. ៩៦ និងជុំវិញរង្វង់មូលវត្តភ្នំ នៅវេលាម៉ោង ២ រំលងអាធ្រាត ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ សមត្ថកិច្ចប្រមូលបាន ប្រុសខ្ទើយចំនួន ១នាក់ ស្រី ៣នាក់ ។

តាមការបញ្ជាក់ពីសមត្ថកិច្ច ស្ត្រីរកស៊ីផ្លូវភេទទាំងនេះ និងត្រូវបញ្ជូន ទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ។ សមត្ថកិច្ចបញ្ជាក់ទៀតថា កិច្ចប្រតិបត្តិការ បង្ក្រាបនេះ នឹងបន្តអនុវត្តន៍ជាប់ជាប្រចាំ ដើម្បីលុបបំបាត់ សេវារកស៊ីផ្លូវភេទតាមដងផ្លូវសាធារណៈ កែលំអសោភ័ណភាពទីក្រុង ៕

## ភាគីថៃបានបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ០៧នាក់ មកកម្ពុជាវិញ

https://www.facebook.com/ General-Department-of-Immigration-GDI 11-07-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃ ចំនួន ០៧នាក់ នាវេលាម៉ោង ១៧និង៤០នាទី ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

# ថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៩

## មន្ត្រីនៃអគ្គនាយកដ្ឋានការងារ បានធ្វើការណែនាំតម្រង់ទិសដល់កម្មសិក្សាការី ដែលត្រូវចេញទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន និងហុងកុង

https://www.facebook.com/ អគ្គនាយកដ្ឋានការងារ-General Department of Labour 12-07-2019

នាថ្ងៃព្រហស្បតិ៍ ១០កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ត្រីនៃអគ្គនាយកដ្ឋានការងារ បានធ្វើការណែនាំតម្រង់ទិសដល់កម្មសិក្សាការី ដែលត្រូវចេញទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន និងហុងកុង សរុបចំនួន ៨៣នាក់ (ស្រី ៣១នាក់)។ វគ្គសិក្សានេះរៀបចំឡើងក្នុងគោលបំណងផ្តល់ចំណេះដឹងដល់កម្មសិក្សាការី ឱ្យមានការយល់ដឹងអំពី៖

| | |
|---|---|
| ១-ការរៀបចំខ្លួន ដើម្បីធ្វើការនៅបរទេស | ២-ភូមិសាស្ត្រ បរិស្ថាន និងវប្បធម៌នៅបរទេស |
| ៣-ការធ្វើដំណើរតាមផ្លូវ និងការមកដល់បរទេស | ៤-ការធ្វើការងារ និងការរស់នៅក្នុងបរទេស |
| ៥-ការគ្រប់គ្រងប្រាក់ | ៦-សុខភាព និងអនាម័យ |
| ៧-ការធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ | ៨-សុវត្ថិភាព និងសេវាគាំទ្រ។ |

ក្រុមហ៊ុនដែលបានបញ្ជូនកម្មសិក្សាការី ទទួលការបណ្តុះបណ្តាលក្នុងវគ្គនេះមានចំនួន៧ គឺ៖

| | | | |
|---|---|---|---|
| ១. Axel | ២. Gala Tokyo | ៣. International Easy Reach | |
| ៤. JNN | ៥. Phillimore | ៦. Pro Cast | ៧. Top Manpower |

## ពលរដ្ឋខ្មែរ៦នាក់ ត្រូវអាជ្ញាធរបញ្ជូនមកឲ្យកម្ពុជាវិញ ពីបទឆ្លងដែនខុសច្បាប់ ចូលកាប់ឈើគ្រញូងក្នុងដីថៃ

http://kampucheathmey.com/ 11/7/2019 11:15 Pm

ឧត្តរមានជ័យ ៖ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង១៥និង០៥នាទី អាជ្ញាធរថៃ បានបញ្ជូនពលរដ្ឋខ្មែរចំនួន០៦នាក់ តាមច្រកអន្លង់វែង ដែលភាគីថៃចាប់ខ្លួនពីបទកាប់ឈើគ្រញូងក្នុងទឹកដីថៃ ជាប់គុកខេត្តស៊ីសាកេត ប្រទេសថៃ មកឲ្យកម្ពុជាវិញ ដែលមានឈ្មោះដូចខាងក្រោម ៖

០១.ឈ្មោះ ណន ទីណា ភេទប្រុស អាយុ៣៩ឆ្នាំ រស់នៅភូមិឃ្លាំងកណ្តាល ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តមានជ័យ ចាប់ខ្លួនថ្ងៃទី០៦.០១.២០១៣ ចូលតាមច្រកអូរស្វាយ។

០២.ឈ្មោះ រ៉ក ខួន ភេទប្រុស អាយុ៤៩ឆ្នាំ រស់នៅភូមិជ្រៃឆ្មោត ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ចាប់ខ្លួនថ្ងៃទី២១.០២.២០១៦ ចូលតាមច្រកអូរស្វាយ។

០៣.ឈ្មោះ ឈូក ខូរ ភេទប្រុស អាយុ៤៣ឆ្នាំ រស់នៅភូមិល្បើក ឃុំល្បើក ស្រុកឈូក ខេត្តកំពត ដូចគ្នា។

០៤.ញៀន គាវ ភេទប្រុស អាយុ៣១ឆ្នាំ រស់នៅភូមិមេម៉ៃ ឃុំក្រែក ស្រុកក្រែក ខេត្តកំពង់ចាម ចាប់ខ្លួនថ្ងៃទី០៧.០៦.២០១៨ ចូលតាមច្រកដើមស្តុង។

០៥.ឈ្មោះ ដួន ហេង ភេទប្រុស អាយុ៣៧ឆ្នាំ រស់នៅភូមិតាឡូ ឃុំតាឡូ ស្រុកបាកាន ខេត្តពោធិ៍សាត់ ចាប់ខ្លួនថ្ងៃទី២០.០២.២០១៦ ចូលតាមច្រកអូរស្វាយ។

០៦.ឈ្មោះ ចាន់ ធៃ ភេទប្រុស អាយុ២៩ឆ្នាំ រស់នៅភូមិលំទងថ្មី ឃុំលំទងថ្មី ស្រុកអន្លង់វែង ខេត្តឧត្តមានជ័យ ចាប់ខ្លួនថ្ងៃទី២០.០៤.២០១៧ ចូលតាមច្រកអូរស្វាយ។

បច្ចុប្បន្ន ប្រជាពលរដ្ឋទាំង៦នាក់ ដែលថៃ បញ្ជូនមកឲ្យកម្ពុជាវិញនោះ ត្រូវបានសមត្ថកិច្ចធ្វើការអប់រំ រួចក៏ឲ្យវិលទៅលំនៅដ្ឋានវិញ៕ ដោយ ៖ ចាន់ ធី

## វគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តបែបកុមារមេត្រីដើម្បីការពារកុមាររងគ្រោះនិងកុមារជាសាក្សីក្នុងការស៊ើបអង្កេតបទល្មើសកេងប្រវ័ញ្ចផ្លូវភេទ

https://gdlf-kh.com/ 12/07/2019 Kao sophy ខេត្តព្រះសីហនុ

ខេត្តព្រះសីហនុ៖ ព្រឹកថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ នេះ នៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការអនុវត្តបែបកុមារមេត្រី ដើម្បី ការពារកុមាររងគ្រោះ និងកុមារជាសាក្សីក្នុងនីតិវិធីស៊ើបអង្កេត បទល្មើសកេងប្រវ័ញ្ចផ្លូវភេទ។

វគ្គបណ្តុះបណ្តាលនេះ មានរយៈពេលមួយថ្ងៃ រៀបចំដោយអង្គការសកម្មភាពដើម្បីកុមារ (APLE) ក្រោមជំនួយឧបត្ថម្ភរបស់ terre des hommes ដោយមានសិក្ខាកាមចូលរួមចំនួន៣៥នាក់ មកពីការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន អធិការក្រុងស្រុក និង ប៉ុស្តិ៍នគរបាលរដ្ឋបាលនានា ក្នុងក្រុងព្រះសីហនុ។

លោកផៃ សុភ័ក្រ ប្រធានកម្មវិធីCJD (អង្គការAPLE) និងលោកស្រីឧត្តមសេនីយ៍ត្រី ប៉ែន កញ្ញា ស្នងការរងទទួលការងារ យ៉េនឌ័ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានមានប្រសាសន៍ ផ្តាំផ្ញើឲ្យសិក្ខាកាមទាំងអស់ ត្រូវយកចិត្តទុកដាក់គោរពវិន័យបទបញ្ជាផ្ទៃក្នុងរបស់សាលា ខិតខំរៀនសូត្រ ទទួលយកចំណេះដឹង យកទៅអនុវត្តជាក់ស្តែងក្នុងពេលបំពេញការងារកុំឲ្យមានការធេកល្វែង។

## ពលករខ្មែរ-ឡាវ និងមីយ៉ាន់ម៉ា ជាង២លាននាក់ ធ្វើការនៅថៃ អាចបន្តចុះឈ្មោះការងារ

https://www.dap-news.com/ ByID:112 Posted on 12 July 2019 | 13:54

ភ្នំពេញ ៖ ពលករទេសន្តរប្រវេសន៍ ចំនួន២.០៥៦.៤៦៧នាក់ ដែលមកពីប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា មានលិខិតអនុញ្ញាត ឲ្យធ្វើការងារនៅថៃ ផុតកំណត់ឆ្នាំ២០១៩-២០២០ អាចធ្វើការចុះឈ្មោះ ដើម្បីបន្តការងាររបស់ពួកគេបាន ដោយមិនចាំបាច់ចាកចេញពីថៃឡើយ។ នេះបើតាមការចុះផ្សាយ របស់ក្រសួងព័ត៌មាននៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩។

ប្រភពឲ្យដឹងទៀតថា ពលករទេសន្តរប្រវេសន៍ ត្រូវបានបែងចែកចេញជាពីរក្រុម គឺក្រុមទីមួយមានចំនួន ៥៨៧.៥៣៣នាក់ ជាពលករទេសន្តរប្រវេសន៍មានលិខិតអនុញ្ញាត ការងារផុតកំណត់មុនថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០២០ ដែលនឹងត្រូវបានអនុញ្ញាតឲ្យធ្វើការរហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ហើយក្រុមទីពីរមានចំនួន ១.៤៦៨.៩៣៤នាក់ មានលិខិតអនុញ្ញាតការងារផុត កំណត់ចាប់ពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ នឹងត្រូវបានអនុញ្ញាត ឲ្យធ្វើការរហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២។ សម្រាប់ពលករទេសន្តរប្រវេសន៍ ដែលមិនចង់ស្នាក់នៅថៃ ត្រូវតែវិលត្រឡប់ទៅកាន់ប្រទេសដើមវិញ នៅចុងបញ្ចប់នៃលិខិតអនុញ្ញាតការងារ ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើពួកគេចង់ធ្វើការ ម្តងទៀត ត្រូវតែត្រឡប់ទៅថៃដោយស្របច្បាប់ ឬទៅតាមរយៈប្រព័ន្ធ អនុស្សារណៈយោគយល់ប៉ុណ្ណោះ៕ ដោយៈធី លីថូ

## ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១៩

## សមត្ថកិច្ចនគរបាលរដ្ឋបាលប៉ុស្តិ៍វត្តភ្នំ ដែលបង្ក្រាបបាននារីរកស៊ីផ្លូវភេទ ជាបន្តបន្ទាប់ ថា បញ្ជូនទៅមន្ទីរសង្គមកិច្ច ពេលនេះឃើញនៅឈរម្ញុំរង្វង់មូលដដែល

https://www.chnchannel.com/ អត្ថបទដោយ Asmatt កាលបរិច្ឆេទ ថ្ងៃទី 13 ខែ កក្កដា ឆ្នាំ 2019

ភ្នំពេញ៖ សមត្ថកិច្ចនគរបាលរដ្ឋបាលប៉ុស្តិ៍វត្តភ្នំ ដែលបង្ក្រាបបាននារីរកស៊ីផ្លូវភេទ ជាបន្តបន្ទាប់ ថាបញ្ជូនទៅមន្ទីសង្គមកិច្ច ពេលនេះឃើញនៅឈរម្ញុំរង្វង់មូលវត្តភ្នំដដែល ខណៈដែលសមត្ថកិច្ចចុះបង្ក្រាបជាប្រចាំរាល់ថ្ងៃ និងបញ្ជូនតែមាត់ ចំណែកមនុស្សត្រូវដោះលែងវិញ។

គួររំលឹកថា នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង២០ម៉០០នាទី កំលាំងជំនាញខណ្ឌ ប៉ុស្តិ៍នគរបាលវត្តភ្នំបានចុះបង្ក្រាប ករណីស្ត្រីរកស៊ីផ្លូវភេទ និងអ្នកគកជេរ (អ្នកចាប់ម៉ូយ) ស្ថិតនៅចំណុចផ្លូវលេខ៩២.៩៤.៩៦ និងជុំវិញរង្វង់មូលវត្តភ្នំ។ ជាលទ្ធផលនៃកិច្ចប្រតិបត្តិការនេះ បានបញ្ចប់នៅវេលាម៉ោង ០២:០០ នាទីរំលងអាធ្រាតចូលថ្ងៃទី១១ សមត្ថកិច្ចយើងប្រមូលបានសរុបរួមចំនួន ០៤នាក់ ក្នុងនោះប្រុសខ្ទើយចំនួន០១នាក់ ស្រី០៣នាក់។ ចំពោះមុខអធិការដ្ឋានបានបញ្ជូនស្ត្រីរកស៊ីផ្លូវភេទ និងអ្នកគកជេរខាងលើទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ហើយកិច្ចប្រតិបត្តិការនេះសមត្ថកិច្ចយើងនឹងបន្តអនុវត្តន៍ជាប់ជាប្រចាំ។

ក្រោយពីមានការផ្សាយព័ត៌មានថា កម្លាំងសមត្ថកិច្ចខណ្ឌ និងប៉ុស្តិ៍វត្តភ្នំបានបង្ក្រាបស្ត្រីរកស៊ីផ្លូវភេទកាលពីថ្ងៃទី១០ខែកក្កដាឆ្នាំ២០១៩ចាប់បាន៤នាក់ក្នុងនោះខ្ទើយប្រុសម្នាក់ និងយប់ថ្ងៃទី១១ខែកក្កដាឆ្នាំ២០១៩ បង្ក្រាបបានចំនួន៥នាក់ទៀត ថាបញ្ជូនទៅមន្ទីសង្គមកិច្ចអស់ហើយជាបន្តបន្ទាប់ តាមពិតត្រូវបានដោះលែងអស់ហើយ ។

តាមប្រភពពីស្ត្រីម្នាក់ (សុំមិនបញ្ចេញឈ្មោះ) ដែលបានរួចផុតពីកន្លែងឃុំខ្លួនប៉ុស្តិ៍វត្តភ្នំ បានប្រាប់អោយដឹងថា ពួកគាត់ចំនួន៤នាក់ទាំងខ្ទើយម្នាក់ ត្រូវបានសមត្ថកិច្ចថា អោយរកលុយក្នុងម្នាក់២០០០០០៛(មួយម្ភៃម៉ឺនរៀល) ជាថ្នូរនិងការដោះលែង តែស្ត្រីរកស៊ីផ្លូវភេទថា ពួកខ្ញុំរកមួយថ្ងៃស៊ីមួយថ្ងៃ គ្មានប្រាក់ច្រើនយ៉ាងនេះទេ តែទោះជាយ៉ាងណា៤នាក់ដែលចាប់បាននៅយប់ថ្ងៃទី១០ខាងលើ ត្រូវបានដោះលែងមកវិញអស់ហើយ។

ចំណែកក្រុមទី២ ដែលចាប់បាននៅយប់ថ្ងៃទី១១ ត្រូវជាប់នៅសាលាខណ្ឌ ត្រូវចំណាយប្រាក់អស់ក្នុងម្នាក់ ១០ ០០០៛(ដប់ម៉ឺនរៀល) ជាថ្នូរនិងការដោះលែង ធ្វើជាលេះថាលួចរត់ចេញពីខណ្ឌ អស់៣នាក់ដែលបានបង់លុយ ចំណែក២នាក់ទៀតទុកត្រូវបញ្ជូនទៅសង្គមកិច្ច ព្រោះគ្មានប្រាក់សូក។ ប្រជាពលរដ្ឋរិះគន់ចំៗទៅលើសមត្ថកិច្ចនិងអាជ្ញាធរខណ្ឌដូនពេញ ដែលចាប់ស្ត្រីរកស៊ីផ្លូវភេទ បានលែងៗជាប់តែ អ្នកក្រអត់លុយបានជាប់ បើអ្នកមានលុយ50$ ទៅ100$ រួចខ្លួន ។

## កម្លាំងអធិការដ្ឋានខណ្ឌដូនពេញ បញ្ជូនស្ត្រីរកស៊ីផ្លូវភេទ២នាក់ ទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ

http://cambodiapolice.com/policekh/ 10:06 am 13 កក្កដា 2019

ភ្នំពេញ ៖ ស្ត្រីរកស៊ីផ្លូវភេទ២នាក់ នៅម្តុំវត្តភ្នំ ត្រូវបានកម្លាំងអធិការដ្ឋានខណ្ឌដូនពេញ ចុះទៅឃាត់ខ្លួននិងអប់រំ ហើយបញ្ជូនពួកគេទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ។ ការឃាត់ខ្លួនស្ត្រីរកស៊ីផ្លូវភេទនេះ បានធ្វើឡើងកាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង២២និង០០នាទី និងបានបញ្ចប់នៅវេលាម៉ោង ០២និង០០ នាទីរំលងអាធ្រាត ស្ថិតនៅចំណុចផ្លូវលេខ ៩២. ៩៤. ៩៦ និងជុំវិញរង្វង់មូលវត្តភ្នំ ។ កម្លាំងអធិការដ្ឋានបានបញ្ជូនស្ត្រីរកស៊ីផ្លូវភេទ និងអ្នកគួកជេរខាងលើទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ហើយកិច្ចប្រតិបត្តិការនេះសមត្ថកិច្ច នឹងបន្តអនុវត្តន៍ជាប់ជាប្រចាំ ៕

## តុលាការសម្រេចឃុំខ្លួន មេបនរកស៊ីជួញដូរផ្លូវភេទទាំងពីរនាក់ប្តីប្រពន្ធ នៅស្រុកពញាក្រែក

http://nokorwatnews.com/ 13-07-2019

ខេត្តត្បូងឃ្មុំ ៖ ម្សិលមិញនេះ តុលាការខេត្តត្បូងឃ្មុំបានសម្រេចឃុំខ្លួនជនសង្ស័យប្តីប្រពន្ធពីរនាក់ ពីបទដឹកនាំគ្រប់គ្រងគ្រឹះស្ថានសម្រាប់ធ្វើពេស្យាចារប្រព្រឹត្តនៅភូមិត្រពាំង ព្រីង២ ឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ។ ជនសង្ស័យពីរនាក់នេះមានឈ្មោះ សោម ប៊ុនរ៉ាន់ ភេទប្រុស អាយុ៤៨ឆ្នាំជាតិខ្មែរ(ត្រូវជាប្តី ) និងឈ្មោះ សំ ពេជ្រ អាយុ៤៥ឆ្នាំ ជាតិខ្មែរ (ប្រពន្ធ) ស្នាក់នៅភូមិ~ឃុំ កើតហេតុខាងលើ ត្រូវបានសមត្ថកិច្ចនគរបាលខេត្តត្បូងឃ្មុំឃាត់ខ្លួន កាលពីថ្ងៃទី១០ ខែ កក្កដា ឆ្នាំ ២០១៩ ពីបទ ដឹកនាំគ្រប់គ្រងគ្រឹះស្ថានសម្រាប់ធ្វើពេស្យាចារ (ជួញដូរផ្លូវភេទ)។ នគរបាលឲ្យដឹងថា ក្រោយចាប់ឃាត់ខ្លួនបញ្ជូនទៅតុលាការ ជនសង្ស័យទាំងប្តីប្រពន្ធពីរនាក់ត្រូវបានតុលាការតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៧០ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដោយចៅក្រមស៊ើបសួរ លោក ឈិត វិនា ៕ វណ្ណៈ

## រយៈពេលមួយសប្តាហ៍ គណៈបញ្ជាការឯកភាពខណ្ឌដូនពេញ ប្រមូលបានស្ត្រីរកស៊ីផ្លូវភេទជុំវិញរមណីយដ្ឋានវត្តភ្នំ ជិត៥០នាក់

https://mediakhmer.club/ July 15, 2019

(ភ្នំពេញ)៖ ដោយអនុវត្តន៍តាមបទបញ្ជាដ៏មុឺងម៉ាត់របស់លោក សុខ ពេញវុធ អភិបាលខណ្ឌដូនពេញ កម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌដូនពេញ សហការជាមួយកម្លាំងគណៈបញ្ជាការឯកភាពសង្កាត់វត្តភ្នំ បានបើកប្រតិបត្តិការ ចុះប្រមូលស្ត្រីរកស៊ីផ្លូវភេទ រួមទាំងអ្នកគួកជេរ (អ្នកចាប់ម៉ូយ) នៅជុំវិញរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រវត្តភ្នំ ដែលបានបង្កភាពអណាធិបតេយ្យ បណ្តាលឲ្យបាត់បង់សណ្តាប់ធ្នាប់ និងតម្លៃស្ត្រីខ្មែរ។

ជាលទ្ធផលរយៈពេល១សប្តាហ៍ នៃប្រតិបត្តិការបង្ក្រាបនេះ គណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌ បានធ្វើការប្រមូលស្ត្រីរកស៊ីផ្លូវភេទ រួមទាំងអ្នកគួកជេរ (អ្នកចាប់ម៉ូយ) សរុបចំនួន៤៩នាក់ ក្នុងនោះមានស្ត្រីចំនួន ៣៧នាក់ ប្រុស១២នាក់ បញ្ជូនមកនៅសាលាខណ្ឌដូនពេញ ដើម្បីរៀបចំឯកសារ បញ្ជូនបន្តទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ៕ ប្រភព៖ freshnews

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៤នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI July 13 at 4:32 PM

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៤នាក់ នាថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៩ ពីបទឆ្លងដែនទៅធ្វើការខុសច្បាប់ នៅប្រទេសថៃ ដែលចេញតាមច្រកទ្វារព្រំដែនអន្តរជាតិជាំ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០៤នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI July 13 at 11:18 AM

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០៤នាក់ នាវេលាម៉ោង ១៧ និង ៥០នាទី ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

# ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៩

## នគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន ឃាត់ខ្លួនបុរសម្នាក់ពាក់ព័ន្ធករណី ប៉ុនប៉ងរំលោភសេពសន្ថវៈ

http://bayontv.com.kh/ 15/07/2019

ភ្នំពេញ៖ បុរសម្នាក់ត្រូវបាននគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន ឃាត់ខ្លួនពាក់ព័ន្ធករណី ប៉ុនប៉ង រំលោភសេពសន្ថវៈមិនបានសម្រេច។ ប្រតិបត្តិការនេះដោយមានការសម្របសម្រួលពីលោក កែវ សុជា ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ និងដឹកនាំដោយលោក វរៈសេនីយ៍ទោ ផាត់ ផល្លា នាយរងការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ធ្វើការឃាត់ខ្លួនជនសង្ស័យ កាលពីវេលាម៉ោង ១៣ម៉០០នាទី រសៀលនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩ នៅចំណុចផ្ទះជួលលេខ ២៤DE2 ផ្លូវលេខ២៤៧ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក។

នគរបាលបានអោយដឹងថា ជនសង្ស័យពាក់ព័ន្ធករណី ប៉ុនប៉ងរំលោភសេពសន្ថវៈ មានឈ្មោះ ផន ខន ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរ អូសរទេះបន្លែ នៅចំណុចផ្ទះជួលលេខ ២៤DE2 ផ្លូវលេខ២៤៧ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។ចំណែកនារីរងគ្រោះឈ្មោះ ស– ភេទស្រី អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរនិស្សិត។ នគរបាលជំនាញបានអោយដឹងថា មុនឈានដល់ការឃាត់ខ្លួនជនសង្ស័យ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានសហការជាមួយអាជ្ញាធរមូលដ្ឋានខណ្ឌទួលគោក និងអាណាព្យាបាលជនរងគ្រោះ ធ្វើការស្រាវជ្រាវ បានចុះទៅឃាត់ខ្លួនជនសង្ស័យភ្លាមៗតែម្តង នាំមកការិយាល័យជំនាញដើម្បីធ្វើការសាកសួរ។

នារីរងគ្រោះបានរៀបរាប់អោយដឹងថា កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ១០និង៤៥នាទី ជនសង្ស័យដែលជួលបន្ទប់ខាងលើផ្ទះជនរងគ្រោះស្នាក់នៅ បានដើរទៅមកចុះឡើងមុខផ្ទះ ធ្វើឲ្យមានការសង្ស័យជនរងគ្រោះបានដេញចេញ ពេលនោះជនសង្ស័យមិនព្រមចេញ រួចក៏ស្ទុះទៅទាញដៃជនរងគ្រោះចូលក្នុងផ្ទះបាយដែលមានបន្ទប់ទឹក ជនរងគ្រោះភ័យពេកបានទាញយកអង្រែចូលទៅជាមួយ ដល់បន្ទប់ទឹកជនសង្ស័យបានទាញអាវជនរងគ្រោះរបូត និងស្ទាបអង្អែលដោះ នារីរងគ្រោះបានទាញយកអង្រែវៃក្បាលជនសង្ស័យចំនួនបីអង្រែ បន្ទាប់មកជនរងគ្រោះបានរត់ចេញពីបន្ទប់ទឹក និងបានទូរស័ព្ទទៅបងប្រុស ឲ្យប្តឹងសមត្ថកិច្ចជួយអន្តរាគមន៍។

បច្ចុប្បន្នជនសង្ស័យត្រូវបានកម្លាំងនគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជននាំមកសាកសួរ រួចឃុំខ្លួនបណ្តោះអាសន្នដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធី៕

## ពលរដ្ឋខ្មែរពីនាក់ចូលកាប់ឈើក្នុងទឹកដីថៃ ត្រូវប៉ូលីសថៃចាប់ខ្លួនដាក់ទោសតាមច្បាប់ថៃ

https://www.facebook.com/ ទឹកចិត្ត ពលករ ឆ្លងដែន 16-07-2019

ពលរដ្ឋខ្មែរពីនាក់ព្រោះតែគាត់ក្រគ្មានការងារធ្វើនៅក្នុងស្រុក ទើបគាត់សម្រាចចិត្តចូលកាប់ឈើនៅក្នុងទឹកដីថៃត្រូវ ប៉ូលីស នឹងទាហ៊ានថៃចាប់បានយកទៅដាក់ទោសតាមច្បាប់ថៃកាលពីម្សិលមិញនេះ 15-7-2019។

## ប្រធាននគរបាល អន្តោប្រវេសន៍ស្រះកែវ សន្យាជួយសម្រួល ការធ្វើដំណើរ របស់ពលករខ្មែរ នៅក្នុងទឹកដីរបស់ខ្លួន

https://www.dap-news.com/ ByID:117 Posted on 15 July 2019 | 16:57

**ភ្នំពេញ** ៖ លោក ហ៊ិន សារឿន អគ្គកុងស៊ុលខ្មែរប្រចាំខេត្តស្រះកែវ ប្រទេសថៃ បានសំណូមពរ លោកវរសេនីយ៍ឯក បិនចាផុន រ៉ែតសាវ៉ាត ប្រធាននគរបាលអន្តោប្រវេសន៍ ខេត្តស្រះកែវ ជួយសម្រួលដល់ការ ចេញ-ចូល ឆ្លងកាត់ព្រំដែន ក៏ដូចជាការស្នាក់នៅ និងធ្វើការក្នុងភូមិសាស្ត្រ របស់ខ្លួនរបស់នពលករ និងអាជីវករខ្មែរ។

ជាការឆ្លើយតបជាមួយនឹង អារម្មណ៍រំភើបសប្បាយរីករាយ លោកប្រធាននគរបាល អន្តោប្រវេសន៍ ខេត្តស្រះកែវ បានសន្យាថា នឹងខិតខំថែមទៀត ក្នុងការងារសម្រួល ដល់ដំណើរឆ្លងកាត់ របស់គណៈប្រតិភូកម្ពុជា ការឆ្លងកាត់ស្នាក់នៅ និងធ្វើការរបស់ពលរដ្ឋខ្មែរ នៅទូទាំងខេត្តស្រះកែវ ព្រមទាំងផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធ ជាមួយស្ថានអគ្គកុងស៊ុល កម្ពុជាប្រចាំខេត្តសាកែវ ដូចពេលកន្លងទៅផងដែរ។

នេះជាលើកឡើង របស់ភាគីទាំងពីរ នៅក្នុងចំពិធីប្រគល់លិខិត ថ្លែងអំណរគុណជូនលោក វរសេនីយ៍ឯក បិនចាផុន រ៉ែតសាវ៉ាត ពីសំណាក់ លោកអគ្គកុងស៊ុលខ្មែរ។ នេះបើតាមការផ្សព្វផ្សាយ របស់គេហទំព័រ អគ្គកុងស៊ុលខ្មែរនៅខេត្តស្រះកែវ ៕

## អាជ្ញាធរថៃបញ្ជូនពលរដ្ឋខ្មែរម្នាក់មកស្រុកវិញតាមច្រកអន្តរជាតិជាំស្រងាំ

http://www.rasmeinews.com/ July 15, 2019, 9:17 PM

ដោយបាយ័ន/ឧត្តរមានជ័យ: ពលរដ្ឋខ្មែរម្នាក់ត្រូវបានទាហានថៃចាប់ខ្លួនពីបទឆ្លងដែនដោយខុសច្បាប់ចូលទៅកាប់ឈើគ្រញូងក្នុងទឹកដីថៃ ហើយបញ្ជូនខ្លួនទៅដាក់ពន្ធនាគារនៅខេត្តស៊ីសាកេតត្រូវបានដោះលែងឱ្យមានសេរីភាពរួចបញ្ជូនត្រឡប់មកស្រុកកំណើតវិញ។ពិធីប្រគល់និងទទួលបានធ្វើឡើងស្ថិតនៅច្រកអន្តរជាតិជាំស្រងាំក្នុងទឹកដីស្រុកអន្លង់វែងខេត្តឧត្តរមានជ័យកាលពីរសៀលថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩នេះ ។

សមត្ថកិច្ចនគរបាលប្រចាំច្រកអន្តរជាតិជាំស្រងាំ បានិយាយថាពលរដ្ឋខ្មែរដែលត្រូវបានបញ្ជូនមកស្រុកវិញគឺមាន ឈ្មោះ លយ កន ភេទប្រុស អាយុ៣៩ឆ្នាំ រស់នៅភូមិថ្នល់ទទឹងឃុំអន្លង់វែងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ឈ្មោះលយកនត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧ កន្លងទៅនេះពីបទឆ្លងដែនកាប់ឈើ។ ចូលតាមច្រកអូរស្មាច់រួចបញ្ជូនទៅដាក់ពន្ធនាគារនៅខេត្តស៊ីសាកេតប្រទេសថៃចាប់តាំងពីពេលនោះមករហូតដល់ថ្ងៃទី១៥ខែកក្កដាឆ្នាំ២០១៩នេះទើបដោះលែងអោយមានសេរីភាពវិញរួចបញ្ជូនមកស្រុកកំណើតវិញ៕S/

## បុរសជនជាតិឥណ្ឌាបីនាក់ ត្រូវបានមេខ្យល់បោកយកមកធ្វើការនៅចំការដូងប្រេង ក្នុងទីក្រុងគូឡាឡាំពួ ត្រូវបានវ៉ៃធ្វើបាបនិងដាក់ច្រវ៉ាក់

https://www.khmerload.com/ Meas Chan Dara, Khmerload ១៨ ម៉ោងមុន 16:42 July 15, 2019

គូឡាឡាំពួ៖ បុរសជនជាតិឥណ្ឌាបីនាក់ ត្រូវបានមេខ្យល់នាំមកទីក្រុងគូឡាឡាំពួ ដោយសន្យាថានឹងផ្តល់ការងារឲ្យធ្វើនៅចំការប្រេងដូង។ ប៉ុន្តែពួកគេទាំងបី ត្រូវបានគេបង្ខំឲ្យធ្វើការ១២ម៉ោងក្នុងមួយថ្ងៃ ដោយមិនមានម៉ោងសម្រាកទាំងអស់ និងដាក់ច្រវ៉ាក់ពួកគេទៀតផង។

បុរសឥណ្ឌាទាំងបីបានប្រាប់ប្រភពថា ពួកគេបានធ្វើដំណើរមកដល់ទីក្រុងគូឡាឡាំពួតាំងពីខែកញ្ញា ឆ្នាំ ២០១៨ មកម្ល៉េះ ដោយប្រើប្រាស់សេវាកម្មមួយសម្រាប់រកការងារធ្វើ។ មេខ្យល់បានមកទទួលពួកគេនៅព្រលានយន្តហោះ រួចបន្តដំណើរមកកាន់ចំការដូងប្រេងនេះ។ បុរសឥណ្ឌាទាំងបីបានបន្តទៀតថា មេខ្យល់បានដកហូតលិខិតឆ្លងដែននិងទូរស័ព្ទរបស់ពួកគេភ្លាមៗនៅពេលមកដល់ចំការដូងប្រេងភ្លាម។ មេខ្យល់បានសន្យាផ្តល់ប្រាក់ខែចំនួន ១៤៦ដុល្លារក្នុងមួយខែ ប៉ុន្តែពួកគេមិនដែលបានទទួលប្រាក់ខែទេ។

ប៉ូលិសបានឲ្យដឹងថា ម្នាក់ក្នុងចំណោមជនរងគ្រោះ ត្រូវបានដាក់ច្រវ៉ាក់ និងវ៉ៃដៃជាច្រើនដង បណ្តាលឲ្យមានរបួសធ្ងន់។ ជនរងគ្រោះម្នាក់រត់គេចចេញរួច បានមកប្តឹងប៉ូលិសនៅតំបន់នោះ កាលពីថ្ងៃសៅរ៍សប្តាហ៍មុនកន្លងទៅនេះ។ បន្ទាប់មកប៉ូលិសក៏បានចុះទៅដល់កន្លែងកើតហេតុ ចាប់ឃាត់ខ្លួនបុរសជនសង្ស័យម្នាក់ នៅអាហារដ្ឋានមួយកន្លែងជិតចំការដូងប្រេង។ ប៉ូលិសសន្និដ្ឋានថា បុរសនោះជាអ្នកធ្វើបាបបុរសឥណ្ឌាទាំងបី ដោយប្រើទារុណកម្ម មិនផ្តល់អាហារ និងបង្ខំឲ្យធ្វើការលើសម៉ោង។ បុរសឥណ្ឌាទាំងបីត្រូវបានជួយសង្គ្រោះ និងជនសង្ស័យកំពុងឃុំខ្លួនដើម្បីដោះស្រាយ៕

## ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០១៩

## វៀតណាម ចាប់ស្ត្រីខ្មែរពពោះជំនួសចិន៣នាក់ បញ្ជូនមកកម្ពុជាវិញ

---

http://kampucheathmey.com/ 16/7/2019 5:34 Pm

ភ្នំពេញ ៖ ស្ត្រីខ្មែរ៣នាក់ ដែលពាក់ព័ន្ធបទល្មើសពពោះជំនួស ត្រូវបាននគរបាលវៀតណាមចាប់បញ្ជូនមកអោយនគរបាលកម្ពុជាវិញ បន្ទាប់ពីពួកគេឆ្លងដែនទៅសម្រាលកូននៅក្បែរព្រំដែនវៀតណាម ចិន។ សំណុំរឿងក្តីនេះត្រូវបាននគរបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃបញ្ជូនមកកាន់សាលាដំបូងរាជធានីភ្នំពេញកាលពីព្រឹកថ្ងៃទី ១៦កក្កដា ឆ្នាំ២០១៩នេះដើម្បីធ្វើការសាកសួរ។

លោកគុជ គឹមឡុង អ្នកនាំពាក្យអយ្យការអមសាលាដំបូងបានអោយដឹងថា ជនសង្ស័យដែលសមត្ថកិច្ចបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញមានឈ្មោះ ១/ សេង ចិន្តា ហៅដា អាយុ៣២ឆ្នាំ មានទីលំនៅភូមិគោល

ឃុំទួលពេជ្រ ស្រុកអង្គស្នួល ខេត្តកណ្តាល។ ២/ ឈ្មោះ ភូន ស៊ីនឿន អាយុ៣២ឆ្នាំ មានទីលំនៅភូមិឃុំជាមួយគ្នា។ ៣/ ឈ្មោះ សាត សារួន អាយុ៣១ឆ្នាំ។

ពាក់ព័ន្ធករណីពពោះជំនួសខាងលើនេះ បើតាមចម្លើយរបស់ឈ្មោះ សេង ចិន្តា បានអោយដឹងថា នៅក្នុងខែតុលា ឆ្នាំ២០១៨ នាងបានទៅផ្ទះរបស់ឈ្មោះ ភូន ស៊ីនឿន ដែលនៅក្នុងភូមិជាមួយគ្នានិយាយបញ្ចុះបញ្ចូលអោយទៅពពោះជំនួសជនជាតិចិននៅភ្នំពេញ ដោយទទួលបានប្រាក់ចំនួន៨ ០០០ដុល្លារក្នុងទារកមួយ ។ ក្រោយមកនៅថ្ងៃទី១១តុលា ឆ្នាំ២០១៨ ឈ្មោះភូន ស៊ីនឿន បានមកភ្នំពេញតាមការរៀបចំរបស់សេង ចិន្តា ដោយបានជួបបុរស ស្ត្រីជនជាតិចិន៧នាក់ ហើយការនិយាយគ្នាគឺមានអ្នកបកប្រែភាសាចិន។

លុះដល់ថ្ងៃទី ២៥តុលា ២០១៨ មានក្រុមគ្រូពេទ្យចិនបានពិនិត្យប្រដាប់បន្តពូជ ហើយក៏ដាក់បញ្ចូលមេជីវិតទៅក្នុងស្បូន ហើយពួកគេក៏អោយលុយកាក់មួយចំនួនសម្រាប់ហូបចុក ថែរក្សាសុខភាព និងពិនិត្យគភ៌ ក្រោយមកខ្លួនបានប្រាប់ថានាងមានផ្ទៃពោះហើយ ពេលនោះនៅថ្ងៃទី ១២មិថុនា ឆ្នាំ២០១៩ ពួកចិនបានអោយនាងឡើងមកភ្នំពេញដើម្បីធ្វើលិខិតឆ្លងដែន ហើយគេក៏អោយប្រាក់នាងថែម២ ០០០ដុល្លារទៀតដើម្បីចាយវាយបណ្តោះអាសន្ន។ បន្ទាប់មកនៅថ្ងៃទី ២៩ មិថុនា ឆ្នាំ២០១៩ អ្នកបកប្រែ ក៏បានទូរស័ព្ទអោយនាងមកភ្នំពេញដើម្បីរៀបចំសម្រាលកូន។ នៅពេលស្ថិតនៅក្នុងរថយន្តធ្វើដំណើរទៅប្រទេសវៀតណាម នាងឃើញមានស្ត្រីចិន២នាក់ ទារកម្នាក់ ស្ត្រីខ្មែរម្នាក់ទៀតឈ្មោះ សាត សារួន ដែលឈ្មោះដាបញ្ជូនមកអោយមើលថែទាំទារកនិងអ្នកពពោះ។ ពេលធ្វើដំណើរទៅដល់ច្រកទ្វារបាវិតមានបុរសជនជាតិចិនម្នាក់ជាអ្នករត់ការចេញលុយកាក់ទាំងអស់។ បន្ទាប់មកពួកគេបានបន្តដំណើរតាមរថយន្តតាក់ស៊ីរហូតដល់ចំណតរថភ្លើងក្រុងហូជីមិញ និងបន្តដំណើរ២ថ្ងៃ២យប់ទើបដល់ទៅក្រុងហាណូយ។ ដល់ទីនោះមានជនជាតិចិនផ្សេងទៀត រៀបចំអោយបន្តដំណើរទៅព្រំដែន ក៏ត្រូវសមត្ថកិច្ចវៀតណាមចាប់ទាំងអស់គ្នាតែម្តងដោយមានទាំងខ្មែរ ចិន វៀតណាមដែលរត់ការផង។ រហូតដល់ថ្ងៃទី ០៩កក្កដា ឆ្នាំ២០១៩ នៅពេលដែលវៀតណាមកំពុងឃុំខ្លួនបណ្តោះអាសន្នស្រាប់តែឈ្មោះ ភូន ស៊ីនឿនបាន ឈឺពោះសម្រាលបានកូនស្រីមួយ ហើយរហូតមកដល់ថ្ងៃទី ១៣កក្កដា ឆ្នាំ២០១៩ វៀតណាមសម្រេចបញ្ជូនស្រីៗមកប្រទេសកម្ពុជាវិញ ចំណែកជនជាតិចិន វៀតណាមនិងខ្មែរ ដែលជាអ្នករត់ការ ត្រូវបានសមត្ថកិច្ចវៀតណាមចាត់កាងតាមច្បាប់របស់វៀតណាមនៅក្រុងហាណូយ។

រឿងក្តីពពោះជំនួសដែលក្រុមឈ្មួញមានគោលដៅនាំយកទារកទៅក្រៅប្រទេសនេះ អយ្យការអមតុលាការកំពុងសាកសួរជនសង្ស័យនៅឡើយ ដោយមិនទាន់កំណត់នូវបទល្មើស ដែលត្រូវចោទប្រកាន់នៅឡើយ៕ **៖ មករា**

## នគរបាលបញ្ជូនខ្លួនស្ត្រីខ្មែរ ៣នាក់ ទៅតុលាការ ពាក់ព័ន្ធករណីពពោះជំនួសចិន

https://www.chnchannel.com/ អត្ថបទដោយ Asmatt កាលបរិច្ឆេទ ថ្ងៃទី 16 ខែ កក្កដា ឆ្នាំ 2019

**ភ្នំពេញ ៖** នគរបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ នៅព្រឹកថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៩ បានបញ្ជូនខ្លួនស្ត្រីខ្មែរ ៣នាក់ ទៅកាន់សាលាដំបូងរាជធានីភ្នំពេញពាក់ព័ន្ធករណីពពោះជំនួសចិន ដើម្បីធ្វើការសាកសួរ ។

ជនសង្ស័យ ដែលសមត្ថកិច្ចបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញមានឈ្មោះ៖

១.សេង ចិន្តា ហៅដា អាយុ៣២ឆ្នាំ មានទីលំនៅភូមិគោល ឃុំទួលពេជ្រ ស្រុកអង្គស្នួល ខេត្តកណ្តាល ។

២.ឈ្មោះ ភូន ស៊ីនួន អាយុ៣២ឆ្នាំ មានទីលំនៅភូមិឃុំជាមួយគ្នា ។

៣.ឈ្មោះ សាត សារួន អាយុ៣១ឆ្នាំ ។

សូមជម្រាបថា ស្ត្រីខ្មែរ៣នាក់ដែលពាក់ព័ន្ធបទល្មើសពពោះជំនួស ត្រូវបាននគរបាលវៀតណាមចាប់បញ្ជូនមកអោយនគរបាលកម្ពុជាវិញ បន្ទាប់ពីពួកគេឆ្លងដែនទៅសម្រាលកូននៅក្បែរព្រំដែនវៀតណាម.ចិន ។

ពាក់ព័ន្ធករណីពរពោះជំនួសខាងលើនេះ បើតាមចម្លើយរបស់ឈ្មោះ សេង ចិន្តា បានអោយដឹងថា នៅក្នុងខែតុលា ឆ្នាំ២០១៨ នាងបានទៅផ្ទះរបស់ឈ្មោះ កូន ស៊ីនឿន ដែលនៅក្នុងភូមិជាមួយគ្នានិយាយបញ្ចុះបញ្ចូលឲ្យទៅពរពោះជំនួសជនជាតិចិននៅភ្នំពេញដោយ ទទួលបានប្រាក់ចំនួន៨០០០ដុល្លារក្នុង ទារកមួយ ។ ក្រោយមកនៅថ្ងៃទី ១១តុលា ឆ្នាំ២០១៨ ឈ្មោះ កូន ស៊ីនឿន បានមកភ្នំពេញតាមការរៀបចំរបស់សេង ចិន្តា ដោយបានជួបបុរស ស្ត្រីជនជាតិចិន៧នាក់ ហើយការនិយាយគ្នាគឺមានអ្នកបកប្រែភាសាចិន ។ លុះដល់ថ្ងៃទី ២៥តុលា ២០១៨ មានក្រុមគ្រូពេទ្យចិនបានពិនិត្យប្រដាប់បន្តពូជ ហើយក៏ដាក់បញ្ចូលមេជីវិតទៅក្នុងស្បូន ហើយពួកគេក៏អោយលុយកាក់មួយចំនួនសម្រាប់ហូបចុក ថែរក្សាសុខភាព និងពិនិត្យគ៌ត ក្រោយមកខ្លួនបានប្រាប់ថានាងមានផ្ទៃពោះហើយ ពេលនោះនៅថ្ងៃទី ១២មិថុនា ឆ្នាំ២០១៩ ពួកចិនបានអោយនាងឡើងមកភ្នំពេញដើម្បីធ្វើលិខិតឆ្លងដែន ហើយគេក៏អោយប្រាក់នាងថែម២ ០០០ដុល្លារទៀតដើម្បីចាយវាយបណ្តោះអាសន្ន ។ បន្ទាប់មកនៅថ្ងៃទី ២៩ មិថុនា ឆ្នាំ២០១៩ អ្នកបកប្រែក៏បានទូរស័ព្ទអោយនាងមកភ្នំពេញដើម្បីរៀបរំសម្រាលកូន នៅពេលស្ថិតនៅក្នុងរថយន្តធ្វើដំណើរទៅប្រទេ សវៀតណាម នាងឃើញមានស្ត្រីចិន២ នាក់ ទារកម្នាក់ ស្ត្រីខ្មែរម្នាក់ទៀតឈ្មោះ សាត សារួន ដែលឈ្មោះដាបញ្ជូនមកអោយមើលថែទាំទារកនិងអ្នកពរពោះ ។

ពេលធ្វើដំណើរទៅដល់ច្រកទ្វារបាវិត មានបុរសជនជាតិចិនម្នាក់ជាអ្នករត់ការចេញលុយកាក់ទាំងអស់ ។ បន្ទាប់មកពួកគេបានបន្តដំណើរតាមរថយន្តតាក់ស៊ី រហូតដល់ចំណតរថភ្លើងក្រុងហូជីមិញ និងបន្តដំណើរ២ថ្ងៃ២យប់ទើបដល់ទៅក្រុងហាណូយ ដល់ទីនោះមានជនជាតិចិន ផ្សេងទៀតរៀបចំឲ្យបន្តដំណើរទៅព្រំដែន ក៏ត្រូវសមត្ថកិច្ចវៀតណាមចាប់ទាំងអស់គ្នាតែម្តងដោយមានទាំងខ្មែរ ចិន វៀតណាមដែលរត់ការផង ។ រហូតដល់ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ២០១៩ នៅពេលដែលវៀតណាមកំពង់ឃុំខ្លួនបណ្តោះអាសន្ន ស្រាប់តែឈ្មោះ កូន សុ៊ីនឿនបាន ឈឺពោះសម្រាលបានកូន ស្រីមួយ ហើយរហូតមកដល់ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០១៩ វៀតណាមសម្រេច បញ្ជូនស្រីៗមកប្រទេសកម្ពុជាវិញ ។

ចំណែកជនជាតិចិន វៀតណាម និងខ្មែរ ដែលជាអ្នករត់ការ ត្រូវបានសមត្ថកិច្ចវៀតណាម ចាត់កាងតាមច្បាប់របស់វៀតណាមនៅក្រុងហាណូយ ។ រឿងក្តីពរពោះជំនួសដែលក្រុមឈ្មួញមានគោលដៅនាំយកទារកទៅក្រៅប្រទេសនេះ អយ្យការអមតុលាការកំពុងសាកសួរជនសង្ស័យនៅឡើយ ដោយ មិនទាន់កំណត់នូវនទល្មើសដែលត្រូវ ចោទប្រកាន់នៅឡើយ ៕

## កម្ពុជា-ថៃ ត្រៀមលក្ខណៈរួចរាល់ហើយ ក្នុងការកសាងមជ្ឈមណ្ឌលសំចត សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រុងប៉ោយប៉ែត

https://www.chnchannel.com/ អត្ថបទដោយ Kongkea Leuk កាលបរិច្ឆេទ ថ្ងៃទី 16 ខែ កក្កដា ឆ្នាំ 2019

**ភ្នំពេញ៖** នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ ឯឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ តំណាងឯឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងភាគីថៃ ដឹកនាំដោយ លោក ភិឈិត ប៊ុនស៊ុទ អគ្គរាជទូត និងជាប្រធានបេសកកម្មនៃប្រទេសថៃ នាទីស្តីការក្រសួងសង្គមកិច្ច។

កម្ពុជា-ថៃ បានត្រៀមលក្ខណៈរួចរាល់ហើយ ក្នុងការកសាងមជ្ឈមណ្ឌលសំចត សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រុងប៉ោយប៉ែត នៅអំឡុងខែតុលា ឆ្នាំ២០១៩ ខាងមុខនេះ។ ភាគីទាំង២បានអះអាងបន្ថែមថា ការកសាងមជ្ឈមណ្ឌលនេះ មានលក្ខណៈជាប្រវត្តិសាស្ត្រ និងសម្រាប់ការប្រារព្ធពិធីគំរប់ខួប៧០ឆ្នាំ នៃសម្ព័ន្ធភាពថៃ-កម្ពុជាផងដែរ។ ការសម្រេចកសាងមជ្ឈមណ្ឌលសំចត សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រុងប៉ោយប៉ែត នាពេលនេះ គឺបានបង្ហាញពីចំណុចចាប់ផ្តើមជាវិជ្ជមាន របស់កម្ពុជា-ថៃ លើការពង្រឹង និងគ្រប់គ្រងករណី

នៃការធ្វើមាតុភូមិនិវត្តន៍ និង សមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស (SOP) នៅក្នុងប្រទេសថៃ ដែលកម្ពុជា និងថៃបានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩។

ភាគីកម្ពុជា និងភាគីថៃ បានចុះហត្ថលេខា (SOP) ដើម្បីបង្កើតគោលការណ៍ណែនាំរួមស្តីពី ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ក្នុងគោលបំណងពង្រឹងបទដ្ឋានប្រតិបត្តិអនុលោមទៅតាមការអនុវត្តជាលក្ខណៈអន្តរជាតិ, កំណត់តួនាទី និងការទទួលខុសត្រូវ នៃអាជ្ញាធរពាក់ព័ន្ធនៃរដ្ឋភាគីទាំង២ នៅក្នុងដំណើរការមាតុភូមិនិវត្តន៍ និងសមាហរណកម្ម, ប្រើប្រាស់ជាឯកសារយោងពាក់ព័ន្ធ និងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម និងជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស។ ការចុះហត្ថលេខាកាលនោះ គឺរដ្ឋភាគីទាំង២ ត្រូវផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងពេញលេញ ដើម្បីធានានូវការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជាប្រព័ន្ធប្រកបទៅដោយសុវត្ថិភាព និងនិរន្តរភាព ក្រោមវិសាលភាព នៃកិច្ចសហប្រតិបត្តិការរួមមាន៖

ទី១៖ ការផ្លាស់ប្តូរព័ត៌មានពីជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ក្នុងគោលបំណងធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

ទី២៖ ការសម្របសម្រួលក្នុងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

ទី៣៖ ការសម្របសម្រួលក្នុងកិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស។

ទី៤៖ ការតាមដានត្រួតពិនិត្យ និងការប៉ាន់ប្រមាណលទ្ធផល នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។ ក្រោយមានការចុះហត្ថលេខា ភាគីកម្ពុជា-ថៃ ក៏បានបង្ហាញជំហររួមគ្នាអនុវត្ត លើកិច្ចព្រមព្រៀងលុបបំបាត់ និងទប់ស្កាត់អំពើជួញដូរមនុស្ស ឲ្យនៅមានតិចតួចបំផុត ហើយជនរងគ្រោះដោយអំពើជួញដូរមនុស្ស នឹងត្រូវបានលើកតម្កើង និងឲ្យមានសមភាព កុំឲ្យមានភាពរើសអើង ហើយក៏ដើម្បីជួយឲ្យជីវិតរបស់ជនរងគ្រោះ មានភាពល្អប្រសើរជាងមុន៕

## សិស្សានុសិស្សខ្មែរឥស្លាម រៀននៅម៉ាឡេស៊ី ជាច្រើននាក់ ជាប់ឃុំឃាំងនៅថៃ ក្រោយចាញ់បោកមេខ្យល់ក្លែងបន្លំ ធ្វើលិខិតធ្វើដំណើរក្លែងក្លាយ ត្រឡប់មកផ្ទះវិញ

http://www.cen.com.kh/ July 17, 2019

ប្រទេសថៃ ៖ បើយោតាមការផ្សាយរបស់ផេកហ្វេសប៊ុក Cambodian Muslim Media Center-មជ្ឈមណ្ឌលព័ត៌មានមូស្លីមកម្ពុជា នៅថ្ងៃទី១៧ ខែកក្កដានេះថា ព័ត៌មានបឋម ដែលទទួលបានមានពីបងប្រុសម្នាក់ឈ្មោះ រំលី ដែលបានទៅសុើបសួរក្មួយរបស់គាត់ ដែលកំពុងជាប់ឃុំឃាំង នៅប្រទេសថៃ បានឲ្យដឹងថា ក្មួយរបស់គាត់ឈ្មោះ ទីន អារីហ្វីន មានកំណើតនៅភូមិរការពប្រាំថ្មី ខេត្តត្បូងឃ្មុំ ត្រូវបានអាជ្ញាធរថៃ ចាប់ឃុំឃាំងជាមួយនិងសិស្សខ្មែរឥស្លាមផ្សេងទៀត សរុបចំនួន១៥នាក់ ក្នុងនោះមានសិស្សប្រុស៧នាក់ ស្រី៥នាក់ និងក្មេងចំនួន៣នាក់ផងដែរ។ ប្រភពដដែលបន្តថា សិស្សទាំងអស់នោះ ត្រូវបានមេខ្យល់អះអាងថា ជាអ្នករត់ការបោះត្រា លើលិខិតឆ្លងដែនចាស់ អាចប្រើប្រាស់ធ្វើដំណើរត្រឡប់មកប្រទេសកម្ពុជាវិញបាន ដោយឆ្លងដែនកាត់តាមប្រទេសថៃ លុះពេលធ្វើមកដល់ព្រំដែនថៃ ក៏ត្រូវបានគេរកឃើញថា ជាត្រាក្លែងក្លាយ ហើយត្រូវបានគេចាប់ឃុំឃាំង អស់រយៈពេលជាងពីរសប្តាហ៍កន្លងមកហើយ ។ បងប្រុសបន្តថា តាមការអះអាងរបស់ក្មួយប្រុសរបស់គាត់ថា ម្នាក់ត្រូវគេប្រាប់ថា គេកាត់ឲ្យជាប់ឃុំឃាំង ២ឆ្នាំ ៦ខែ។ ទាក់ទងនឹងបញ្ហានេះ បងប្រុសជាពូ ក៏ដូចជា ក្រុមគ្រួសារបានអំពាវនាវ ឲ្យអាជ្ញាធរ និងថ្នាក់ដឹកនាំ ជួយពួកគាត់ផង ធ្វើយ៉ាងណា ឲ្យកូនៗរបស់គាត់ រួចទោស ដោយសារពួកគាត់ចាញ់បោកគេ ។ រហូតមកដល់ពេលនេះ មជ្ឈមណ្ឌលព័ត៌មានមូស្លីមកម្ពុជា មិនទាន់អាចទាក់ទង សុំការបញ្ជាក់ពីមន្ត្រីស្ថានទូត កម្ពុជាប្រចាំប្រទេសថៃ អំពីករណីនេះនៅឡើយទេ ។

គួររំលឹកផងដែរថា កាលពីពេលថ្មីៗនេះ ក៏មានករណីតម្រួតថៃ ចាប់ឃុំសិស្សខ្មែរឥស្លាមដែលរៀននៅថៃ ជាច្រើននាក់ផងដែរ ពីករណីមិនមានឯកសារធ្វើដំណើរ ឆ្លងដែនត្រឹមត្រូវតែក្រោយមកត្រូវបានដោះលែងវិញ ក្រោយមានដំណោះស្រាយ និងអន្តរាគមន៍ពីថ្នាក់ដឹកនាំពាក់ព័ន្ធ។ ដោយៈកូឡាប

## ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៩

## លោកស្រី ជូ ប៊ុនអេង៖ «ករណីពរពោះជំនួសនៅកម្ពុជា មិនទាន់ស្ងប់ស្ងាត់ទេ»

---

http://km.rfi.fr/cambodia/ ដោយ ញឹម សុផល ចុះផ្សាយនៅថ្ងៃ 18/07/2019

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ ផ្តើមចេញពីការឃាត់ខ្លួនដោយសមត្ថកិច្ចវៀតណាម ទៅលើស្ត្រីខ្មែរ៣នាក់ ជាប់ពាក់ព័ន្ធនឹងការពរពោះជំនួស ដែលបានឆ្លងចូលទៅក្នុងដីវៀតណាម ដើម្បីសម្រាលកូន បង្ហាញថា បញ្ហាស៊ីឈ្នួលពរពោះជំនួសនៅក្នុងប្រទេសកម្ពុជានៅមិនទាន់ស្ងប់ ឬកាត់បន្ថយនៅឡើយ។ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ថ្លែងថា បញ្ហាស៊ីឈ្នួលពរពោះជំនួសនេះ សមត្ថកិច្ចកម្ពុជាកំពុងប្រមូលព័ត៌មាន ដើម្បីកំណត់ឲ្យបានជាក់លាក់ ខណៈជនល្មើសបានព្យាយាមបន្លំភ្នែកសមត្ថកិច្ចគ្រប់រូបភាព។

## តុលាការឃុំខ្លួនស្ត្រីខ្មែរបីនាក់រកស៊ីពរពោះជំនួសដែលវៀតណាមចាប់បញ្ជូនមកកម្ពុជាវិញ

http://www.rasmeinews.com/ July 18, 2019, 2:59 PM *ដោយ: សរិទ្ធ*

*ភ្នំពេញ:* ស្ត្រីខ្មែរ៣នាក់ជាប់ពាក់ព័ន្ធបទល្មើសពរពោះជំនួស ដែលនគបាលវៀតណាមចាប់បញ្ជូនមកឲ្យនគរបាលកម្ពុជាវិញ បន្ទាប់ពីពួកគេឆ្លងដែនទៅសម្រាលកូននៅក្បែរព្រំដែនវៀតណាម ចិន នោះបានត្រូវលោក វ៉ាន់ សែនវិសុទ្ធ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ សម្រេចឃុំខ្លួនដាក់ពន្ធនាគារកាលពីរសៀលថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩។

លោក គុជ គឹមឡុង អ្នកនាំពាក្យអយ្យការអមសាលាដំបូងបានអោយដឹងថា ស្ត្រី៣នាក់នេះឈ្មោះ សេង ចិន្តាហៅដា អាយុ៣២ឆ្នាំ មានទីលំនៅភូមិគោល ឃុំទួលពេជ្រ ស្រុកអង្គស្នួល ខេត្តកណ្តាល ឈ្មោះ ភួន ស៊ីនួន អាយុ៣២ឆ្នាំ និងឈ្មោះ សាត សារួន អាយុ៣១ឆ្នាំ។

ពាក់ព័ន្ធករណីពពោះជំនួសខាងលើនេះបើតាមចម្លើយរបស់ឈ្មោះ សេង ចិន្តា បានអោយដឹងថា នៅក្នុងខែតុលា ឆ្នាំ២០១៨ នាងបានទៅផ្ទះរបស់ឈ្មោះ ភួន ស៊ីនឿន ដែលនៅក្នុងភូមិជាមួយគ្នានិយាយបញ្ចុះបញ្ចូលឲ្យទៅពរពោះជំនួសជនជាតិចិននៅភ្នំពេញ ដោយទទួលបានប្រាក់ចំនួន៨ ០០០ដុល្លារក្នុងទារកមួយ។ ក្រោយមកនៅថ្ងៃទី១១តុលា ឆ្នាំ២០១៨ ឈ្មោះភួន ស៊ីនឿនបានមកភ្នំពេញតាមការរៀបចំរបស់សេង ចិន្តា ដោយបានជួបបុរស ស្ត្រីជនជាតិចិន៧នាក់ ហើយការនិយាយគ្នាគឺមានអ្នកបកប្រែភាសាចិន។

លុះដល់ថ្ងៃទី ២៥តុលា ២០១៨ មានក្រុមគ្រូពេទ្យចិនបានពិនិត្យប្រដាប់បន្តពូជ ហើយក៏ដាក់បញ្ចូលមេជីវិតទៅក្នុងស្បូន ហើយពួកគេក៏អោយលុយកាក់មួយចំនួនសម្រាប់ហូបចុក ថែរក្សាសុខភាព និងពិនិត្យគ៌ភ។ ក្រោយមកខ្លួនបានប្រាប់ថានាងមានផ្ទៃពោះហើយ។ ពេលនោះនៅថ្ងៃទី ១២ខែមិថុនា ឆ្នាំ២០១៩ ពួកចិនបានអោយនាងឡើងមកភ្នំពេញដើម្បីធ្វើលិខិតឆ្លងដែន ហើយគេក៏ឲ្យប្រាក់នាងថែម២,០០០ដុល្លារទៀត ដើម្បីចាយវាយបណ្តោះអាសន្ន។ បន្ទាប់មកនៅថ្ងៃទី ២៩ខែមិថុនា ឆ្នាំ២០១៩ អ្នកបកប្រែក៏បានទូរស័ព្ទឲ្យនាងមកភ្នំពេញ ដើម្បីរៀបចំសម្រាលកូន។ នៅពេលស្ថិតនៅក្នុងរថយន្តធ្វើដំណើរទៅប្រទេសវៀតណាមនាងឃើញមានស្ត្រីចិន២នាក់ ទារកម្នាក់ ស្ត្រីខ្មែរម្នាក់ទៀតឈ្មោះ សាត សារួន ដែលឈ្មោះដាបញ្ជូនមកអោយមើលថែទាំទារកនិងអ្នកពពោះ។ ពេលធ្វើដំណើរទៅដល់ច្រក

ទ្វារបារិតមានបុរសជនជាតិចិនម្នាក់ជាអ្នករត់ការចេញលុយកាក់ទាំងអស់ ។ បន្ទាប់មកពួកគេបានបន្តដំណើរតាមរថយន្តតាក់ស៊ីរហូតដល់ចំណតរថភ្លើងក្រុងហូជីមិញ និងបន្តដំណើរ២ថ្ងៃ២យប់ទើបដល់ទៅក្រុងហាណូយ។ ដល់ទីនោះមានជនជាតិចិនផ្សេងទៀត រៀបចំអោយបន្តដំណើរទៅព្រំដែន ក៏ត្រូវសមត្ថកិច្ចវៀតណាមចាប់ទាំងអស់គ្នាតែម្តងដោយមានទាំងខ្មែរ ចិន វៀតណាមដែលរត់ការផងៗ

រហូតដល់ថ្ងៃទី ៩ខែកក្កដា ឆ្នាំ២០១៩ នៅពេលដែលវៀតណាមកំពុងឃុំខ្លួនបណ្តោះអាសន្នស្រាប់តែឈ្មោះកូន ស៊ីនឿនបាន ឈឺពោះសម្រាលបានកូនស្រីមួយ ហើយរហូតមកដល់ថ្ងៃទី ១៣ខែកក្កដា ឆ្នាំ២០១៩ វៀតណាមសម្រេចបញ្ជូនស្រីៗមកប្រទេសកម្ពុជាវិញ ។ចំណែកជនជាតិចិន វៀតណាម និងខ្មែរ ដែលជាអ្នករត់ការ ត្រូវបានសមត្ថកិច្ចវៀតណាមចាត់ការតាមច្បាប់របស់វៀតណាមនៅក្រុងហាណូយ៕

## តុលាការសម្រេចឃុំខ្លួនស្ត្រី ៣ នាក់ ករណីស៊ីឈ្នួលពពោះ

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 19 July 2019 | 12:00 ICT

**ភ្នំពេញៈ** សាលាដំបូងរាជធានីភ្នំពេញ កាលពីម្សិលមិញបានសម្រេចឃុំខ្លួនស្ត្រី ៣ នាក់ បណ្តោះអាសន្ននៅពន្ធនាគារព្រៃស ពាក់ព័ន្ធករណីស៊ីឈ្នួលពពោះជំនួស ដើម្បីសម្រាលកូនឲ្យជនជាតិចិន បន្ទាប់ពីកម្លាំងនគរបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនក្រសួងមហាផ្ទៃ បានបញ្ជូនពួកគេទៅតុលាការ ក្រោយពីឃាត់ខ្លួនបាននៅប្រទេស វៀតណាម។ ស្ត្រីទាំង ៣ នាក់នេះ ត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌចំនួន ២ករណី ដែលអាចប្រឈមមុខជាប់ពន្ធនាគារជិត ២០ ឆ្នាំ ប្រសិនបើរកឃើញថា ពិតជាបានប្រព្រឹត្តបទល្មើស ដូចការចោទប្រកាន់មែននោះ។

លោក អ៊ី រិទ្ធ បានបញ្ជាក់ប្រាប់ភ្នំពេញប៉ុស្តិ៍ពីម្សិលមិញថាៈ «ត្រូវបានចៅក្រមស៊ើបសួរសាលាដំបូង សម្រេចឃុំខ្លួនបណ្តោះអាសន្ននៅ ម ២ ទាំង ៣ នាក់ តាមមាត្រា ១៦ នៃច្បាប់ជួញដូរមនុស្ស និងមាត្រា ៣៣២ ទាក់ទងនឹងក្រមព្រហ្មទណ្ឌ។ អ៊ីចឹងយើងចោទប្រកាន់ពីបទអំពើជួញដូរមនុស្សឆ្លងដែន និងបទអន្តរកាលរវាងអ្នកសុំកូននិងស្ត្រីពពោះ»។ យោងតាមមាត្រា ៣៣២ នៃក្រមព្រហ្មទណ្ឌ ចែងថា អំពើប្រព្រឹត្តនៅក្នុងគោលបំណងចង់បានកម្រៃ ធ្វើជាអន្តរការីរវាងបុគ្គលម្នាក់ ឬច្រើននាក់ ឬប្តី ប្រពន្ធ ដែលចង់សុំកូនយកមកចិញ្ចឹម និងស្ត្រីម្នាក់ យល់ព្រមពពោះ ដើម្បីនឹងប្រគល់កូននោះឲ្យទៅអ្នកសុំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ ខែ ទៅ ៦ ខែ ខណៈមាត្រា ១៦ នៃច្បាប់ស្តីពីការជួញដូរមនុស្ស បានចែងថា ជនណាដែលលក់ដូរជនដទៃក្នុងគោលដៅប្រគល់ ឬនាំយកទៅក្រៅប្រទេស និងក្នុងករណីដែលជនរងគ្រោះ ជាអនីតិជន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ទៅ ២០ ឆ្នាំ។

កាលពីថ្ងៃទី ១៦ ខែ កក្កដា កម្លាំងនគរបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនក្រសួងមហាផ្ទៃ បានសម្រេចបញ្ជូនស្ត្រី ៣ នាក់ ទៅតុលាការ ដោយពួកគេទាំងនោះ មានឈ្មោះ សេង ចិន្តា ហៅ ដា អាយុ ៣២ ឆ្នាំ, ឈ្មោះ ភួន ស៊ីនួន អាយុ ៣២ ឆ្នាំ និងឈ្មោះ សាត សារួន អាយុ ៣១ ឆ្នាំ ដែលមានលំនៅឋានក្នុងភូមិគោលឃុំទួលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល។

លោក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនៃក្រសួងមហាផ្ទៃ ធ្លាប់បានថ្លែងថា ក្រុមជនសង្ស័យទាំង ៣ នេះត្រូវបានកម្លាំងនគរបាលប្រទេសវៀតណាម ចាប់ឃាត់ខ្លួននៅក្នុងប្រទេស វៀតណាម រួចបញ្ជូនមកកម្ពុជា បន្ទាប់ពីពួកគេបានឆ្លងដែនខុសច្បាប់ ចូលទៅវៀតណាមដើម្បីសម្រាលកូនលក់ឲ្យជនជាតិចិនក្នុងតម្លៃ ៨ ០០០ ដុល្លារ ក្នុងកូនម្នាក់។

លោក អំ សំអាត ប្រធានគ្រប់គ្រងផ្នែកស៊ើបអង្កេតអង្គការលីកាដូ បានប្រាប់ភ្នំពេញប៉ុស្តិ៍ពីម្សិលមិញដោយបង្ហាញការសោកស្តាយដែលតុលាការសម្រេចចោទប្រកាន់លើពួកគេពាក់ព័ន្ធ នឹងបទល្មើសទាំងនេះ ព្រោះស្ត្រីទាំងនេះ អាចជាជនរងគ្រោះនៅក្នុងបទល្មើស ព្រោះតែកត្តាខ្វះការយល់ដឹង និងកត្តាជីវភាព។ លោកថ្លែងថាៈ «អ្វីដែល

សំខាន់គឺរដ្ឋាភិបាល គួរតែផ្សព្វផ្សាយឲ្យបានទូលំទូលាយ ហើយការអនុម័តច្បាប់ ឬការធ្វើច្បាប់នានាជុំវិញបញ្ហានេះ គួរមានការពិគ្រោះយោបល់ជាសាធារណៈឲ្យប្រជាពលរដ្ឋបានយល់ បានដឹង និងបានឮ អំពីបទល្មើសហ្នឹង ហើយរំពឹងថា តុលាការនឹងពិចារណា ទាក់ទងបទល្មើសសម្រាប់ពួកគាត់ និងស៊ើបអង្កេតស្វែងរកអ្នកពាក់ព័ន្ធ ព្រោះមិនដែលសុខៗ គាត់អាចទៅប្រព្រឹត្តបទល្មើសដោយខ្លួនគាត់ទេគឺត្រូវតែមានមេខ្យល់ និងមានអ្នកឲ្យគាត់ប្រព្រឹត្ត»។

គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានឲ្យដឹងថា រហូតមកទល់ពេលនេះ កម្ពុជាបង្ក្រាបបានបទល្មើសពពោះជំនួស ដោយស្ត្រីខ្មែរចំនួន ៤៣ ករណីមកហើយ ដោយភាគច្រើនបទល្មើសនៃការពពោះទាំងនេះ ត្រូវបានរកឃើញថា បញ្ជូនទៅប្រទេសចិន ស្របពេលករណីមួយចំនួន កំពុងបន្តនីតិវិធីនៅតុលាការ ខណៈករណីបញ្ជូនស្ត្រី ៣ នាក់ ទៅឃុំខ្លួនពីម្សិលមិញ គឺជាករណីថ្មីបន្ថែមទៀត ដែលទើបបង្ក្រាបបាន ស្របពេលដែលកម្ពុជានឹងមានការពិភាក្សាគ្នា នៅសប្តាហ៍ទី ៣ ក្នុងខែនេះ លើសេចក្តីព្រាងច្បាប់សម្រាប់ដាក់ទោសទណ្ឌ និងការគ្រប់គ្រងបទល្មើសនៃការពពោះជំនួសដែលជាបទល្មើសថ្មីទើបនឹងកើតមាននៅកម្ពុជានាប៉ុន្មានឆ្នាំចុងក្រោយ៕

## បន្តឃាត់ខ្លួនស្ត្រីរកស៊ីផ្លូវភេទ បាន៣នាក់ទៀតហើយ នៅរង្វង់មូលរមណីយដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំ

http://nokorwatnews.com/ 18-07-2019

ភ្នំពេញ៖ បច្ចុប្បន្ននេះ គេសង្កេតឃើញថា កម្លាំងអធិការដ្ឋាននគរបាលខណ្ឌដូនពេញ បានបន្តចុះប្រមូលស្ត្រីរកស៊ីផ្លូវភេទជាប្រចាំថ្ងៃ នៅក្នុងមូលដ្ឋានរបស់ខ្លួន ជាពិសេសគឺនៅចំណុចរង្វង់មូលរមណីយដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំ គឺជាកន្លែងដែលស្ត្រីទាំងនោះ តែងតែនាំគ្នាឈរទាក់ម៉ូយ ដើម្បីរកសេវាបម្រើផ្លូវភេទ ។

មន្ត្រីនគរបាលខណ្ឌដូនពេញ បានឲ្យដឹងថា ដោយអនុវត្តន៍តាមបទបញ្ជាដឹកនាំដ៏ខ្ពង់ខ្ពស់របស់ លោកឧត្តមសេនិយ៍ឯក ស ថេត អគ្គស្នងការរង និងជាស្នងការនគរបាលរាជធានីភ្នំពេញ និងលោកសុខ ពេញវុធ អភិបាលនៃគណៈអភិបាលខណ្ឌដូនពេញ នៅថ្ងៃអង្គារ ១៥កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង១០យប់ កម្លាំងជំនាញខណ្ឌ និងប៉ុស្តិ៍នគរបាលវត្តភ្នំ បានបន្តចុះបង្ក្រាបករណីស្ត្រីរកស៊ីផ្លូវភេទ និងអ្នកគួកជេរ(អ្នកចាប់ម៉ូយ) ស្ថិតនៅចំណុចផ្លូវលេខ ៩២. ៩៤. ៩៦ និងជុំវិញរង្វង់មូលវត្តភ្នំ ។

ជាលទ្ធផលនៃកិច្ចប្រតិបត្តិការនេះ បានបញ្ចប់នៅវេលាម៉ោង២រំលងអធ្រាត្រ ចូលថ្ងៃទី១៧ ខែកក្កដានេះ សមត្ថកិច្ចបានប្រមូលស្ត្រីរកស៊ីផ្លូវភេទសរុបរួមចំនួន៣នាក់ ក្នុងនោះស្រីទាំងអស់ ។ ក្រោយឃាត់ខ្លួនស្ត្រីរកស៊ីផ្លូវភេទខាងលើនេះ ត្រូវបានបញ្ជូនទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ដើម្បីអប់រំ ហើយកិច្ចប្រតិបត្តិការនេះសមត្ថកិច្ចនឹងបន្តអនុវត្តន៍ជាប់ជាប្រចាំ ៕ ស វេស្នា

## មន្ត្រីនៃអគ្គនាយកដ្ឋានការងារ បានធ្វើការណែនាំតម្រង់ទិសដល់កម្មសិក្សាការី ដែលត្រូវចេញទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន និងសឹង្ហបុរី

https://www.facebook.com/ General Department of Labour 18-07-2019

នាថ្ងៃពហស្បតិ៍ ២រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ នៅសាលប្រជុំB នៃទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ត្រីនៃអគ្គនាយកដ្ឋានការងារ បានធ្វើការណែនាំតម្រង់ទិសដល់កម្មសិក្សាការី ដែលត្រូវចេញទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន និងសឹង្ហបុរី សរុបចំនួន ១០២នាក់ (ស្រី ១៧នាក់)។ វគ្គសិក្សានេះរៀបចំឡើងក្នុងគោលបំណងផ្តល់ចំណេះដឹងដល់កម្មសិក្សាការី ឱ្យមានការយល់ដឹងអំពី៖

១-ការរៀបចំខ្លួន ដើម្បីធ្វើការនៅបរទេស

២-ភូមិសាស្ត្រ បរិស្ថាន និងវប្បធម៌នៅបរទេស
៣-ការធ្វើដំណើរតាមផ្លូវ និងការមកដល់បរទេស
៤-ការធ្វើការងារ និងការរស់នៅក្នុងបរទេស
៥-ការគ្រប់គ្រងប្រាក់
៦-សុខភាព និងអនាម័យ
៧-ការធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ
៨-សុវត្ថិភាព និងសេវាគាំទ្រ។

ក្រុមហ៊ុនដែលបានបញ្ជូនកម្មសិក្សាការី ទទួលការបណ្តុះបណ្តាលក្នុងវគ្គនេះមានចំនួន១១ គឺ

| | | |
|---|---|---|
| ១. Ung Rithy | ២. Agri Farmer | ៣. Asia Recruit Staffing |
| ៤. Bridge JC | ៥. CJTT | ៦. Kampusun |
| ៧. Kizuna | ៨. Limina | ៩. Master Cam |
| ១០. Takayama | ១១. Yakushinkai | |

## អន្តរក្រសួង និងអង្គការ សហការគ្នាការពារកុមារពីអំពើហិង្សា

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 18 July 2019 | 16:11 ICT

**ភ្នំពេញៈ** អន្តរក្រសួង និងអង្គការក្រៅរដ្ឋាភិបាលធ្វើការងារលើកុមារនៅកម្ពុជា បានរួមគ្នាបង្កើត «គណៈកម្មាធិការដឹកនាំការអនុវត្តផែនការសកម្មភាព ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះ អំពើហិង្សាលើកុមារ» ដើម្បីទប់ស្កាត់អំពើហិង្សាលើកុមារនៅកម្ពុជា។ នេះបើតាមលោក តូច ចាន់នី អ្នកនាំពាក្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាថ្លែងប្រាប់ភ្នំពេញប៉ុស្ដិ៍ម្សិលមិញ។

លោក តូច ចាន់នី បានថ្លែងថា គណៈកម្មាធិការនេះមាន លោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាប្រធាន និងមានសមាជិកចំនួន ២២ រូប ក្នុងនោះ ១៥ រូប មកពីក្រសួងស្ថាប័ន និង ៧ រូប មកពីតំណាងអង្គការដែលធ្វើការទាក់ទង នឹងកុមារ។ លោកបានបន្តថា៖ «យើងបានប្រជុំអន្តរក្រសួងជាលើកដំបូង ដើម្បីប្រកាសសមាសភាពនៃគណៈកម្មាធិការនេះ សម្រាប់អនុវត្ត ផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ»។ លោក ចាន់នី បានឲ្យដឹងថា គណៈកម្មាធិការនេះ មានអន្តរក្រសួងពាក់ព័ន្ធមួយចំនួនចូលរួមជាសមាជិក រួមមាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ និងក្រសួងព័ត៌មានជាដើម។ ដោយឡែកសមាជិកគណៈកម្មាធិការមកពីអង្គការដែលធ្វើការងារលើកុមារនេះ រួមមាន អង្គការ Plan International អង្គការ Save The Children និងអង្គការ ChildFund ជាដើម។ លោកបន្ថែមថា៖ «ទម្រាំយើងសម្រេចប្រកាសសមាសភាព សមាជិក គណៈកម្មាធិការនេះ យើងបានសិក្សាស្រាវជ្រាវ និងពិនិត្យមើលផែនការនៃការបង្កើតគណៈកម្មាធិការនេះ នៅអំឡុងឆ្នាំ ២០១៦-២០១៧។ ប៉ុន្តែផែនការនេះ កន្លងមកវាមានតែនៅក្រដាស វាចេញអត់រួច ទើបក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មើលឃើញការងារនេះជាការងារសំខាន់ ដែលគួរតែមានគណៈកម្មាធិការអន្តរក្រសួងដើម្បីជំរុញប្រសិទ្ធភាពការងារនេះ»។ លោក ចាន់នី លើកឡើងថា ការអនុវត្តផែនការសកម្មភាព ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ មិនមែនធ្វើតែក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអ្នកអនុវត្តទេ។ ប៉ុន្តែក្រសួងពាក់ព័ន្ធក៏ត្រូវចូលរួម អនុវត្តផងដែរ ក្នុងការទប់ស្កាត់អំពើហិង្សាលើកុមារនៅកម្ពុជា។ លោក ចាន់នី បានបញ្ជាក់ថា ការអនុវត្តចំពោះការទប់ស្កាត់អំពើហិង្សាលើកុមារនេះ តាមក្រសួងនីមួយៗគាត់មានកាតព្វកិច្ចក្នុងការអនុវត្តរៀងៗខ្លួន ទៅតាមជំនាញរបស់ក្រសួង។ ចំណែកអង្គការសង្គមស៊ីវិល ពួកគាត់ក៏ធ្វើការងារទៅតាមផ្នែករបស់ខ្លួនដែរទៅតាមគម្រោងនៃការការពារ និងទប់ស្កាត់អំពើហិង្សលើកុមាររបស់ពួកគេ ដូចជាផ្នែកសុខភាព សង្គមកិច្ចដោយគាំទ្រទៅដល់ក្រសួងជំនាញ។ លោក តូច ចាន់នី បានបញ្ជាក់ថា៖ «នៅកម្ពុជាយើងនៅ

មានការរំលោភបំពាន និងអំពើហិង្សាជាច្រើនលើកុមារ។ ដូច្នេះបានជាក្រសួង រួមជាមួយនឹងអង្គការដៃគូធំៗមួយចំនួន នេះសហការគ្នារៀបចំផែនការជាតិមួយសម្រាប់ទប់ស្កាត់ ប្រឆាំងអំពើហិង្សាលើកុមារនេះ»។

លោក វង សូត បានថ្លែងនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការអនុវត្តផែនការសកម្មភាព ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារនេះនៅក្រសួងសង្គមកិច្ច កាលពីថ្ងៃអង្គារ ទី ១៦ ខែ កក្កដា ថា ជារឿងចាំបាច់ ទាមទារឲ្យមានការចូលរួមពីគ្រប់ក្រសួងស្ថាប័ន អង្គការជាតិ អន្តរជាតិ និងដៃគូពាក់ព័ន្ធទាំងអស់ ដើម្បីដោះស្រាយ អំពើហិង្សា ការរើសអើង និងការរំលោភបំពានកុមារគ្រប់រូបភាពស្របតាមបទដ្ឋានច្បាប់ជាតិដែលមាន និងកំពុងអនុវត្ត រួមទាំងអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីកុមារឲ្យកាន់តែប្រសើរ។ លោកបានថ្លែងថា៖ «អំពើហិង្សាលើកុមារ ជាសកម្មភាពដែលមិនអាចអត់ឱនអនុគ្រោះឲ្យបានទេ ទោះក្នុងរូបភាពណាក៏ដោយ ព្រោះវាធ្វើឲ្យប៉ះពាល់ដល់ការអភិវឌ្ឍរបស់កុមារ សីលធម៌សង្គម សេចក្តីថ្លៃថ្នូរ និងការអភិវឌ្ឍធនធានមនុស្សនាពេលអនាគតរបស់កម្ពុជា»។ បើតាមលោករដ្ឋមន្ត្រី គណៈកម្មាធិការនេះ ក៏មានក្រុមការងារបច្ចេកទេសចំនួន ៣ គឺក្រុមការងារលើកកម្ពស់ការយល់ដឹង និងទប់ស្កាត់អំពើហិង្សាលើកុមារ ក្រុមការងារផ្តល់សេវា និងអនុវត្តច្បាប់ និង ក្រុមការងារសិក្សាលើបទដ្ឋានគតិយុត្ត ពិនិត្យតាមដាន និងធ្វើរបាយការណ៍។

លោក ឈឹម ផាន់ណា អ្នកឯកទេសកិច្ចការពារកុមារនៃអង្គការភ្លែនអន្តរជាតិ ជាអង្គការសមាជិកគណៈកម្មាធិការនេះ បានថ្លែងប្រាប់ភ្នំពេញប៉ុស្តិ៍ម្សិលមិញថា ក្នុងនាមជាសមាជិកគណៈកម្មាធិការ អង្គការភ្លែនអន្តរជាតិ មានតួនាទីសំខាន់ៗមួយចំនួន ដែលមានចែងនៅក្នុងសេចក្តីប្រកាសអំពីការបង្កើតគណៈកម្មាធិការនេះ រួមមានការដឹកនាំ សម្របសម្រួល ជំរុញសកម្ម ភាពនៃការអនុវត្តផែនការទប់ស្កាត់ ឆ្លើយតបអំពើហិង្សាលើកុមារនេះ។ លោកបានថ្លែងថា ៖ «យើងក៏មានតួនាទីប្រមូល វិភាគ ធ្វើរបាយការណ៍ពីស្ថានភាពអំពើហិង្សាលើកុមារនៅកម្ពុជា។ ពិនិត្យតាមដាន និងផ្តល់យោបល់ លើរបាយការណ៍ផ្តល់យោបល់លើផែនការសកម្មភាពនេះដើម្បីទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារជាដើម»។ លោក ផាន់ណា បានលើកឡើងថា ក្នុងនាមជាសមាជិកនេះ អង្គការភ្លែនអន្តរជាតិក៏បានដើរតួនាទីដើម្បីធ្វើទំនាក់ទំនងទៅសហគមន៍ជាតិ និងអន្តរជាតិ ដើម្បីស្វែងរកជំនួយឧបត្ថម្ភ ក៏ដូចជាការផ្លាស់ប្តូរព័ត៌មាន និងបទពិសោធ ក្នុងការបញ្ចប់អំពើហិង្សាលើកុមារផងដែរ។ លោកបានបន្តថា៖ «យន្តការនេះ បានជំរុញក្នុងការជួយនៃការអនុវត្តផែនការទប់ស្កាត់ និងឆ្លើយតបពីអំពើហិង្សាលើកុមារ។ ខ្ញុំមានជំនឿថា បើសិនយើងអនុវត្តនូវផែនការនេះបានល្អ យើងអាចទប់ស្កាត់ និងបង្ការ អំពើហិង្សាលើកុមារបានច្រើន»។ លោក ឈឹម ផាន់ណា បានឲ្យដឹងថា តាមរយៈអង្គការភ្លែនអន្តរជាតិដែលបានធ្វើការងារជាមួយកុមារជាច្រើនឆ្នាំនៅកម្ពុជានោះ បានសង្កេតឃើញថា ករណីអំពើហិង្សាលើកុមារនៅកម្ពុជា នៅមិនទាន់មានការថមថយចុះនៅឡើយ ខណៈករណីរំលោភ និងហិង្សាលើកុមារហាក់មានភាពកាចសាហាវនៅឡើយ។ លោក ផាន់ណា បានថ្លែងឲ្យដឹងទៀតថា៖ «យោងការសិក្សាស្រាវជ្រាវស្តីអំពីអំពើហិង្សាលើកុមារឆ្នាំ ២០១៣ របស់ក្រសួងកិច្ចការនារី និងវិទ្យាស្ថានស្ថិតិជាតិ បានបង្ហាញថា ក្នុងនោះមាន ៦០ ភាគរយ នៃកុមារយ៉ាងហោចណាស់ ៦០ ភាគរយ បានទទួលរងនូវការរំលោភបំពានផ្នែករាងកាយ ផ្លូវចិត្ត និងផ្នែកផ្លូវភេទផងដែរ។ អ៊ីចឹងបើយើងមើលទៅសម្ទុះនៃអំពើហិង្សាលើកុមារហាក់បីដូចជាអត់ទាន់មានការថមថយទេ គឺនៅថេរ ហើយទិន្នន័យក៏មានការកើតឡើងផ្សេងៗគ្នាទៅតាមតំបន់ដែរ គ្រាន់តែថា ប្រព័ន្ធនៃការកត់ត្រាទិន្នន័យនេះនៅមានការខ្វះខាត ដែលនាំឲ្យយើងពិបាកក្នុងការរាយការណ៍»៕

## ឃុំខ្លួនមេស្ត្រីខ្យល់ម្នាក់នាំក្មេងស្រីទៅយកប្តីនៅចិន

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៩ ម៉ោង ១៣:៤០ ប៊ុន លីនណា

ខេត្តក្រចេះ ៖ ស្ត្រីជាមេខ្យល់ក្នុងជំនួញជួញដូរក្មេងស្រីឲ្យទៅយកប្តីខុសច្បាប់នៅប្រទេសចិនម្នាក់ ត្រូវបានតុលាការខេត្តក្រចេះ សម្រេចធ្វើការឃុំខ្លួននៅពន្ធនាគារខេត្តនៅថ្ងៃទី១៨ កក្កដា បន្ទាប់ពីស្ត្រីម្នាក់នេះ ត្រូវបាននគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតជនខេត្តក្រចេះ ស្រាវជ្រាវចាប់ខ្លួនបាននៅខេត្តត្បូងឃ្មុំ។

នគរបាលបានរកឃើញថា ស្ត្រីម្នាក់នេះ បានជាប់សង្ស័យក្នុងអំពើជួញដូរមនុស្ស។ ក្នុងនោះមានក្មេងស្រីរងគ្រោះ ៣នាក់នៅខេត្តក្រចេះដែលមិនទាន់គ្រប់អាយុនិង២នាក់ទៀត គ្រប់អាយុរស់នៅខេត្តត្បូងឃ្មុំ ឲ្យទៅយកប្តីខុសច្បាប់នៅប្រទេសចិនកាលពី២ឆ្នាំមុន។ស្នងការរងប្រឆាំងការជួញដូរមនុស្ស និងការពារអនីតជននៃស្នងការដ្ឋាននគរបាលខេត្ត ក្រចេះ លោកស្រីវរសេនីយ៍ឯក នៅ រតនា បានប្រាប់ឲ្យដឹងថា ស្ត្រីមេខ្យល់ដែលកម្លាំងនគរ បាលរបស់លោកស្រីស្រាវជ្រាបចាប់ខ្លួនបាននេះឈ្មោះជឹម ចាន់ថា អាយុ ៥៥ឆ្នាំ មានទីលំនៅ ភូមិពងទឹក ឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

លោកស្រីស្នងការរងបញ្ជាក់ថា កាលពីដើមខែកុម្ភៈ ឆ្នាំ២០១៨ ស្ត្រីរូបនេះនិងដៃគូម្នាក់ ទៀតដែលកំពុងតែគេចខ្លួន បានល្បួងក្មេងស្រីចំនួន៥នាក់មានខ្លះគ្រប់អាយុ ខ្លះមិនទាន់គ្រប់ អាយុឲ្យទៅយកប្តីខុសច្បាប់នៅប្រទេសចិន ក្រោមរូបភាពធបោកថា ទៅធ្វើការងារស្របច្បាប់ ជំនាញផ្នែកសិកម្ម។លោកស្រីស្នងការរងបញ្ជាក់ឲ្យដឹងទៀតថា ក្មេងស្រីទាំង៥នាក់ ដែលចាញ់ការធបោក ស្ត្រីម្នាក់នេះ និងបក្សពួកម្នាក់ទៀត សព្វថ្ងៃមានខ្លះបានបាត់ដំណឹង និងខ្លះនៅមានដំណឹង ពួកគេកំពុងតែរស់នៅប្រទេសចិន។ ហើយអាជ្ញាធរកំពុងតែទំនាក់ទំនងដើម្បីនាំនារីរងគ្រោះ ទាំងនោះមកស្រុកកំណើតវិញ។ លោកស្រីអះអាងថា បក្សពួករបស់ស្ត្រីរូបនេះម្នាក់ទៀតដែលកំពុងគេចខ្លួន ពាក់ព័ន្ធនិង ករណីជួដូរមនុស្សនេះ ត្រូវបាននគរបាលជំនាញកំពុងតែស្រាវជ្រាវ ស្វែករកចាប់ខ្លួនផងដែរ។ (សម្រួលដោយ៖ ស្រីណា)

# ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៩

## បណ្តុះបណ្តាលគ្រូបង្គោលស្តីពី "កិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត និងសុវត្ថិភាពក្នុងការប្រើប្រាស់អ៊ីនធឺណិត"

http://kampucheathmey.com/ 19/7/2019 2:49 Pm

ភ្នំពេញ ៖ គ្រូបង្គោល និងបុគ្គលិកសំខាន់ៗចំនួន៣៦នាក់មកពីអង្គការចំនួន១៤ ដែលជាសមាជិកគម្រោងថែទាំកុមារក្នុងគ្រួសារជាអាទិភាពចម្បង (FCF) និងស្ថាប័នដៃគូនានា បានចូលរួមវគ្គបណ្តុះបណ្តាលស្តីអំពី "កិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត និងសុវត្ថិភាពក្នុងការប្រើប្រាស់អ៊ីនធឺណិត" កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩នៅមជ្ឈមណ្ឌល CJCC រាជធានីភ្នំពេញ។

វគ្គបណ្តុះបណ្តាលនេះ រៀបចំដោយអង្គការសកម្មភាពដើម្បីកុមារ (APLE) ក្រោមការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីសហភាពអឺរ៉ុប ទីភ្នាក់ងារជំនួយអាមេរិក (USAID) និង អង្គការ Save the Children ហុងកុង តាមរយៈគម្រោងថែទាំកុមារក្នុងគ្រួសារជាអាទិភាពចម្បងFCF និង REACT។

មន្ត្រីអង្គការសកម្មភាពដើម្បីកុមារ(APLE)បានបញ្ជាក់ឲ្យដឹងថា គោលបំណងសំខាន់នៃវគ្គនេះគឺដើម្បីលើកកម្ពស់ការយល់ដឹងអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត និងពង្រឹងសមត្ថភាពរបស់បុគ្គលិកនៃបណ្តាញការពារកុមារក្នុងការការពារ តាមដាន និងរាយការណ៍ពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត។

អ្នកចូលរួមបានសំដែងការប្តេជ្ញាចិត្តខ្ពស់ក្នុងការចែករំលែកចំណេះដឹង ដែលបានទទួលពីវគ្គបណ្តុះបណ្តាលនេះទៅដល់សមាជិកគ្រួសារ សហការី និងអ្នកដទៃផ្សេងៗទៀត ដើម្បីធានាសុវត្ថិភាពក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត។

គួររំលឹកថាកំណើននៃការប្រើប្រាស់អ៊ីនធឺណិតមានការកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា។ អ្នកប្រើប្រាស់អ៊ីនធឺណិតមានប្រមាណ៤.១លាននាក់ ឬ២៥% នៃចំនួនប្រជាជនសរុប និងតំណភ្ជាប់ទូរស័ព្ទដៃមាន ២៥.៨លាននាក់ ឬ១៦៥% នៃប្រជាជនសរុប។ បើទោះបីជាប្រទេសកម្ពុជាទទួលបានប្រយោជន៍ជាច្រើនពីប្រព័ន្ធបច្ចេកវិទ្យានេះ ក៏មានសកម្មភាពល្មើសមួយចំនួនដែលបាន និងកំពុងកើតឡើងនៅលើប្រព័ន្ធអ៊ីនធឺណិត និងប្រព័ន្ធបច្ចេកវិទ្យា ជាពិសេសគឺការចូលទៅកាន់ និងការចែកចាយរូបភាព និងសម្ភារៈអាសអាភាស។ កត្តានេះបានជំរុញឲ្យមានការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត។

ដើម្បីឆ្លើយតបនឹងការព្រួយបារម្ភពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត អង្គការសង្គ្រោះកុមារហុងកុង (SCHK) បានគាំទ្រលើការសិក្សាស្រាវជ្រាវមួយដែលអាចជួយឲ្យកម្ពុជាដោះស្រាយបញ្ហានេះ។ អ្វីដែលគួរឲ្យបារម្ភ ទិន្នន័យរបស់ National Center for Missing and Exploited Children (NCMEC) បង្ហាញពីកំណើនជិត៤ដងនៃសម្ភារៈអាសអាភាសកុមារក្នុងឆ្នាំ២០១៨ គិតត្រឹមខែកញ្ញា បើប្រៀបធៀបនឹងឆ្នាំ២០១៧។ ក្នុងឆ្នាំ២០១៧ ចំនួនមានត្រឹម២៥ ៣៣២ ដោយឡែកត្រឹម ខែកញ្ញា ឆ្នាំ២០១៨ ចំនួនកើនឡើងដល់៩៣ ៣១៨។ ការសិក្សាស្រាវជ្រាវដដែលបានបង្ហាញថា កុមារប្រើប្រាស់អ៊ីនធឺណិតច្រើនជាងការរំពឹងទុក។ ក្នុងចំណោមបណ្តាញទំនាក់ទំនងសង្គម Facebook គឺកំពុងត្រូវបានប្រើប្រាស់ច្រើន ដែលកុមារ និងយុវជនវ័យជំទង់ផ្ញើ និងទទួលសម្ភារៈអាសអាភាស។

ដោយមើលឃើញពីហានិភ័យ និងភាពងាយរងគ្រោះដល់កុមារ និងយុវជនវ័យជំទង់ និងដោយមានការផ្តល់ការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីសហភាពអឺរ៉ុប ទីភ្នាក់ងារជំនួយអាមេរិក (USAID) និង អង្គការ Save the Children ហុងកុងតាមរយៈគម្រោងថែទាំកុមារក្នុងគ្រួសារជាអាទិភាពចម្បងនិង REACT ដល់អង្គការសកម្មភាពដើម្បីកុមារ (APLE) ក្នុងការអនុវត្តគម្រោងរយៈពេលមួយឆ្នាំដើម្បីលើកកម្ពស់ការយល់ដឹង ក្នុងចំណោមអ្នកចូលរួមគោលដៅដែលបានជ្រើសរើសតាមរយៈការកសាងចំណេះដឹងដែលមានការចូលរួម និងដើម្បីផ្តល់សិទ្ធិអំណាចដល់ពួកគេក្នុងការឆ្លើយតបនឹងហានិភ័យ និងការតស៊ូមតិដើម្បីពង្រឹងនូវការឆ្លើយតបដ៏រឹងមាំជាមួយភ្នាក់ងារមានសមត្ថកិច្ច៕ **ដោយ៖ វត្តី**

## UNODC: **ការជួញដូរគ្រឿងញៀន និងការរត់ពន្ធពលករក្នុងតំបន់កើន**

https://www.postkhmer.com/ នៀម ឆេង | Publication date 19 July 2019 | 14:10 ICT

**ភ្នំពេញ៖** ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកគ្រឿងញៀននិងឧក្រិដ្ឋកម្ម(UNODC)បានចេញរបាយការណ៍មួយ កាលពីថ្ងៃព្រហស្បតិ៍ម្សិលមិញ ដោយរៀបរាប់លម្អិតអំពីទម្រង់ថ្មីនៃឧក្រិដ្ឋកម្មដែលមានលក្ខណៈរៀបចំ នៅតំបន់អាស៊ីអាគ្នេយ៍ក្នុងនោះការជួញដូរគ្រឿងញៀន និងការរត់ពន្ធពលករចំណាកស្រុកមានការកើនឡើង។ ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា ការអនុវត្តច្បាប់ និងកិច្ចខិតខំប្រឹងប្រែងបង្ក្រាបនាពេលថ្មីៗនៅក្នុងតំបន់ខ្លះនៃតំបន់អាស៊ីអាគ្នេយ៍ និងតំបន់ជិតខាងបានផ្លាស់ប្តូរទម្រង់ជួញដូរ ខណៈនៅពេលជាមួយគ្នានេះផងដែរ ក្រុមឧក្រិដ្ឋជនធំៗ បានបង្កើននិងបង្វែរប្រតិបត្តិការរបស់ខ្លួនទៅតំបន់ដែលមានការគ្រប់គ្រងខ្សោយ ជាពិសេសនៅតំបន់ព្រំដែន។

របាយការណ៍ដែលមានចំណងជើងថា ឧក្រិដ្ឋកម្មឆ្លងដែនដោយមានការរៀបចំនៅតំបន់អាស៊ីអាគ្នេយ៍៖ វិវត្តន៍ កំណើន និងផលប៉ះពាល់ឆ្នាំ ២០១៩ ដែលចេញ ដោយ UNODC បានពិនិត្យមើលទៅលើឧក្រិដ្ឋកម្មឆ្លងដែនដោយមានការរៀបចំដែលមានលក្ខណៈសកម្មរួមមានគ្រឿងញៀន សារធាតុគីមីផលិតគ្រឿងញៀន (មេតំហ្វេតាមីន និងហេរ៉ូអ៊ីន) ការជួញដូរមនុស្ស និងការរត់ពន្ធពលករចំណាកស្រុក ឧក្រិដ្ឋកម្មបរិស្ថាន ដូចជា ការជួញដូរសត្វព្រៃ និងព្រៃឈើ និងទំនិញក្លែងក្លាយ និងឱសថក្លែងក្លាយ។ របាយការណ៍នេះនិយាយថា គ្រឿងញៀនសំយោគបានក្លាយជាអាជីវកម្មខុសច្បាប់ដែលទទួលបានប្រាក់ចំណេញបំផុត នៅក្នុងតំបន់ ខណៈក្រុមឧក្រិដ្ឋកម្មដែលមានលក្ខណៈរៀបចំ បាន

ថ្លៃប្រឹតទម្រង់អាជីវកម្មរបស់ពួកគេ និងពង្រីកទីផ្សារមេតំហ្វេតាមីនរបស់ពួកគេ។ របាយការណ៍នេះបន្តថា ការជួញដូរគ្រឿងញៀន និងការរត់ពន្ធពលករចំណាកស្រុកក៏កើនឡើងផងដែរ ដោយសារតម្រូវការ និងការផ្គត់ផ្គង់ពលកម្មតម្លៃទាប នៅក្នុងតំបន់។ តំបន់អាស៊ីអាគ្នេយ៍ក៏ជាតំបន់សម្រាប់ទំនិញនិងឱសថក្លែងក្លាយផងដែរ។

លោក Jeremy Douglas តំណាងប្រចាំតំបន់ UNODC កត់សម្គាល់ថា៖ «ក្រុមឧក្រិដ្ឋកម្មដែលមានការរៀបចំកំពុងទទួលបានចំណូលរាប់សិបពាន់ពាន់លានដុល្លារនៅតំបន់អាស៊ីអាគ្នេយ៍ ពីការជួញដូរឆ្លងដែន និងការរត់ពន្ធគ្រឿងញៀនខុសច្បាប់និងសារធាតុគ្រឿងញៀន មនុស្ស សត្វព្រៃឈើ និងទំនិញក្លែងក្លាយ»។ លោកថា លុយខុសច្បាប់កំពុងចលនាខ្លាំងឡើងតាមរយៈឧស្សាហកម្ម កាស៊ីណូក្នុងតំបន់និងអាជីវកម្មដទៃទៀតដែលមានលំហូរសាច់ប្រាក់ច្រើន។

របាយការណ៍នេះបន្ថែមថា ពលករចំណាកស្រុក ប្រហែលកន្លះលាននាក់ ដែលភាគច្រើនមកពីប្រទេសមីយ៉ាន់ម៉ា កម្ពុជា និងឡាវ ត្រូវបានប៉ាន់ប្រមាណថា ត្រូវបានរត់ពន្ធចូលទៅក្នុងប្រទេសថៃ ក្នុងមួយឆ្នាំ ហើយបង្កើតចំណូលខុសច្បាប់ចន្លោះពី ១៣២ លានទៅ ១៩៦ លានដុល្លារអាមេរិក។ «អភិបាលកិច្ចខ្សោយ ទៅលើធនធានព្រៃឈើ អំពើពុករលួយ ក្នុងចង្វាក់ផ្គត់ផ្គង់ឈើ និងភាពនៅជិតទីផ្សាររបស់តំបន់នេះ និងឧស្សាហកម្មកែច្នៃឈើ ក្នុងប្រទេស ចិន បន្តធ្វើឲ្យប្រភេទព្រៃឈើរបស់តំបន់អាស៊ីអាគ្នេយ៍ ក្លាយជាទិសដៅសម្រាប់បណ្តាញឧក្រិដ្ឋកម្ម»។ UNODC ថា ប្រទេស វៀតណាម ត្រូវបានរាយការណ៍ថា ជាអ្នកនាំចេញឈើធំមួយ ព្រមទាំងជាប្រទេសផលិតគ្រឿងសង្ហារិមឈើសំខាន់មួយ។ ប្រទេសនេះ មានការជាប់ពាក់ព័ន្ធខ្លាំងទៅនឹងទីផ្សារឈើស្របច្បាប់ និងខុសច្បាប់ នៅក្នុងប្រទេសជិតខាង ចិន កម្ពុជា និងឡាវ។ ការហាមប្រាមក្នុងប្រទេស ឡាវ ដែលត្រូវបានអនុវត្តកាលពីខែ ឧសភា ឆ្នាំ ២០១៦ ជំរុញឲ្យអ្នកជួញដូរស្វែងរកការផ្គត់ផ្គង់ និងនាំចេញពីប្រទេស កម្ពុជា។ «កន្លែងកាស៊ីណូធំៗនៅតាមតំបន់ព្រំដែនកម្ពុជា និងនៅភ្នំពេញ ក៏ត្រូវបានកំណត់អត្តសញ្ញាណជាទីតាំងសម្រាប់ការរត់ពន្ធសាច់ប្រាក់ក្នុងចំនួនធំ និងការលាងលុយរបស់ឧក្រិដ្ឋកម្ម ដែលមានលក្ខណៈរៀបចំ»។

UNODCថា ត្រឹមខែមករាឆ្នាំ ២០១៩ មានកាស៊ីណូ ដែលមានអាជ្ញាប័ណ្ណចំនួន ២៣០ នៅតំបន់អាស៊ីអាគ្នេយ៍ រួមទាំងកាស៊ីណូចំនួន ១៥០ ក្នុងប្រទេស កម្ពុជា និងកាស៊ីណូ ៦៧ នៅប្រទេស ហ្វីលីពីន និង ៥ នៅប្រទេស ឡាវ និងមីយ៉ាន់មា។ ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៧ អាជ្ញាធរកម្ពុជាបានរកឃើញជនរងគ្រោះសរុបចំនួន ៤១៥ នាក់ ដែលត្រូវបានជួញដូរទៅក្នុងប្រទេស ថៃ។ UNODC បានផ្តល់អនុសាសន៍ ឲ្យបណ្តាប្រទេសនៅក្នុងតំបន់នេះអភិវឌ្ឍយុទ្ធសាស្ត្រដែលមានលក្ខណៈទូលំទូលាយ និងមានប្រសិទ្ធភាពដើម្បីដោះស្រាយឧក្រិដ្ឋកម្មឆ្លងដែន ពង្រឹងសមត្ថភាពប្រមូលទិន្នន័យថ្នាក់ជាតិនិងថ្នាក់តំបន់ និងការរាយការណ៍ និងកាត់បន្ថយជាអតិបរមាចំពោះគម្លាតសមត្ថភាព និងកែលម្អកិច្ចសហប្រតិបត្តិការឆ្លងព្រំដែន៕

## ឯកឧត្តម គួច ចំរើន ស្នើឱ្យមានការដកខ្លួនចេញជាបន្ទាន់ ចំពោះមន្ត្រីណាដែល មានការពាក់ព័ន្ធក្នុងរឿងវិវាទដីធ្លី, បញ្ហាលាងលុយខ្មៅ, ការជួញដូរមនុស្សជាដើម

http://pressnews.today/ July 20, 2019

ខេត្តព្រះសីហនុ៖ លោក គួច ចំរើន អតីតអភិបាលខេត្តកំពង់ចាម បានចូលកាន់តំណែងអភិបាលខេត្តព្រះសីហនុ ជាផ្លូវការ នៅព្រឹកថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩នេះ។ ពិធីប្រកាសចូលកាន់តំណែងរបស់ លោក គួច ចំរើន បានធ្វើឡើងក្រោមអធិបតីភាព សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅរដ្ឋបាលខេត្តព្រះសីហនុ។

សូមបញ្ជាក់ថា ក្រោយរលំបាក់អគារកម្ពស់៧ជាន់មួយដែលសាងសង់គ្មានច្បាប់ នៅក្រុងព្រះសីហនុ បណ្តាលឱ្យមានមនុស្ស២៨នាក់ស្លាប់ និង២៦នាក់របួសនោះ អភិបាលខេត្តនេះ បានចេញមុខសុំទោសសាធារណជន ព្រម

ទាំងបានលាលែងចេញពីតំណែង។ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចផ្ទេរ លោក គួច ចំរើន ពីអភិបាលខេត្តកំពង់ចាម មកជាអភិបាលខេត្តព្រះសីហនុ ចំណែក លោក អ៊ុន ចាន់ដា អភិបាលខេត្តព្រះវិហារ ត្រូវបានផ្ទេរមកជាអភិបាលខេត្តកំពង់ចាម។

ទន្ទឹមនឹងនេះផងដែរ ឯកឧត្តម គួច ចំរើន នៅក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្ត នារសៀលថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ បានមានប្រសាសន៍ថា៖ "ស្នើឱ្យមានការដកខ្លួនចេញជាបន្ទាន់ ចំពោះមន្ត្រីណាដែល មានការពាក់ព័ន្ធក្នុងរឿងវិវាទដីធ្លី, បញ្ហាលាងលុយខ្មៅ, ការជួញដូរមនុស្សជាដើម"។

## កូរ៉េនឹងបន្តបង្កើនកូតាសម្រាប់ពលករកម្ពុជាបន្ថែមទៀត នៅឆ្នាំបន្តបន្ទាប់

http://www.mlvt.gov.kh/ Monday, 22 July 2019 12:59 Written by MLVT

(ភ្នំពេញ)៖ ដោយមើលឃើញពីអត្តចរិតស្លូតបូត ឧស្សាហ៍ព្យាយាមរបស់ពលករកម្ពុជា ដែលកំពុងបម្រើការងារនៅ សាធារណរដ្ឋកូរ៉េ និងកិច្ចសហការល្អរវាងប្រទេសទាំងពីរ កម្ពុជា-កូរ៉េ សាធារណកូរ៉េ នឹងបន្តបង្កើនកូតាសម្រាប់ពលករកម្ពុជាបន្ថែមទៀត។ នេះជាការលើកឡើងរបស់ឯកឧត្តមបណ្ឌិត KIM DONG MAN ប្រធានអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ អញ្ជើញជួបពិភាក្សាការងារជាមួយ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាព្រឹកថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៩ ស្តីពីប្រព័ន្ធអនុគ្រោះការងារ (EPS) នៅទីស្តីការក្រសួង នាឱកាសដែលឯកឧត្តមដឹកនាំគណប្រតិភូអញ្ជើញមកទស្សនកិច្ចនៅកម្ពុជា។ ឯកឧត្តម អ៊ិត សំហេង បានថ្លែងអំណរគុណចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ HRD-KOREA ដែលបន្តជួយជ្រើសរើសកម្លាំងពលកម្មបរទេស ជាពិសេសបងប្អូនពលករ-ពលការិនីកម្ពុជា។

ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រីសង្ឃឹមថា ក្នុងអាណត្តិការងាររបស់ ឯកឧត្តមបណ្ឌិត KIM DONG MAN ប្រធានអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ រយៈពេល ៣ឆ្នាំនេះ នឹងកាន់តែធ្វើ កិច្ចសហប្រតិបត្តិការរវាង គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូលពលករទៅបរទេស នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(MTOSB) និង អង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងមុខរបរ និងការងារនៃសាធារណរដ្ឋកូរ៉េ (HRD-KOREA) នឹងកាន់តែប្រសើរឡើងបន្តទៀត។

ទន្ទឹមនឹងនេះដែរ ឯកឧត្តមប្រធានអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ ប្តេជ្ញាជម្រុញនូវកិច្ចសហប្រតិបត្តិការលើវិស័យនៃការបញ្ជូនពលករនេះ ឲ្យកាន់តែរឹងមាំបន្ថែមទៀត ដើម្បីបម្រើផលប្រយោជន៍ទៅវិញទៅមករវាងប្រទេសយើងទាំងពីរ។ ក្នុងឱកាសនោះដែរភាគីកូរ៉េនឹងផ្តល់ជូនអ្នកបច្ចេកទេស ដើម្បីបណ្តុះបណ្តាលផ្នែកបច្ចេកវិទ្យាដល់ពលករកម្ពុជាដែលកំពុងបម្រើការងារនៅសាធារណរដ្ឋកូរ៉េ ឲ្យទទួលបាននូវជំនាញខាងបច្ចេកវិទ្យានេះ កាន់តែប្រសើរ ខណៈពួកគេត្រឡប់មកស្រុកកំណើតវិញ នឹងមានជំនាញមួយច្បាស់លាស់បន្ថែមទៀត។

សូមបញ្ជាក់ថា កម្ពុជាជាប់ចំណាត់ថ្នាក់លេខ៤ សម្រាប់រយៈពេលនៃការបញ្ជូននេះ តែបើធៀបជាមួយប្រទេសធំៗវិញ កម្ពុជាទទួលបានចំណាត់ថ្នាក់លេខ១។ កម្ពុជាទទួលបានចំណាត់ថ្នាក់លេខ១ ដែលបានបញ្ជូនពលករច្រើនជាងគេក្នុងចំណោម ១៦ប្រទេស ក្នុងឆ្នាំ២០១៩នេះ (លេខ២ នេប៉ាល់, លេខ៣ វៀតណាម, លេខ៤ ឥណ្ឌូនេស៊ី, លេខ៥ ថៃ) ចាប់ពីឆ្នាំ២០១៨មក ការជ្រើសរើសបេក្ខជនដើម្បីដាក់ពាក្យសុំស្វែងរកការងារធ្វើ នៅសាធារណរដ្ឋកូរ៉េក្រោមប្រព័ន្ធ EPS ដោយផ្អែកលើកត្តា៣យ៉ាងជាចាំបាច់៖ ទី១-តេស្តភាសាកូរ៉េ EPS-TOPIK តាមប្រព័ន្ធកុំព្យូទ័រ ទី២-តេស្តជំនាញ និងទី៣-ការវាយតម្លៃសមត្ថភាព។ មានន័យថា បេក្ខជនដែលប្រឡងជាប់តេស្តសមត្ថភាពកូរ៉េ ត្រូវប្រឡងជាប់តេស្តជំនាញ និងការវាយតម្លៃសមត្ថភាព ទើបក្លាយជាបេក្ខជនជាប់ជាស្ថាពរ មានសិទ្ធិដាក់ពាក្យសុំស្វែងរកការងារធ្វើនៅសាធារណរដ្ឋកូរ៉េ(ដែលកន្លងមក បេក្ខជនប្រឡងជាប់តេស្តសមត្ថភាពកូរ៉េ គឺអាចដាក់ពាក្យសុំស្វែងរកការងារធ្វើនៅសាធារណរដ្ឋកូរ៉េបានតែម្តង) ចាប់ពីឆ្នាំ២០០៧មក ការប្រឡងតេស្តសមត្ថភាពកូរ៉េ(EPS-TOPIK)

រៀបចំបានចំនួន ១៦លើកមកហើយ(លើកទី១៦ កំពុងអនុវត្ត) ដែលអនុវត្តដោយអង្គភាពអភិវឌ្ឍន៍ធនធានមនុស្ស នៃក្រសួងមុខរបរ និងការងារនៃសាធារណរដ្ឋកូរ៉េ (HRD-Korea) រួមសហការជាមួយគណៈកម្មាធិការបណ្ដុះបណ្ដាល និងបញ្ជូនពលករទៅបរទេស(MTOSB) ដែលមានបេក្ខជនដាក់ពាក្យសុំសិទ្ធិប្រឡងសរុបចំនួន ៤៣៤ ០៥៤នាក់ ហើយបេក្ខជនប្រឡងជាប់សរុបចំនួន ៨៩ ៣៩៣នាក់៕

## អគ្គកុងស៊ុល ចុះស្វែងយល់អំពីនីតិវិធីផ្ដល់បណ្ណអនុញ្ញាតឱ្យធ្វើការនិងការអប់រំអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ពលករ និងថៅកែថៃ ដល់បងប្អូនពលករខ្មែរ នៅការិយាល័យច្រកចេញចូលតែមួយទទួលនិងបញ្ជូនពលករខ្មែរទៅធ្វើការនៅតាមបណ្ដាខេត្តនានាក្នុងប្រទេសថៃ

https://www.facebook.com/consulatesakaeo/ Consulate General in Sa Kaeo July 19 at 5:05 PM

អារញ្ញប្រាថេត, ថ្ងៃសុក្រ ៣រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ២០១៩ លោកអគ្គកុងស៊ុល ហ៊ិន សារឿន បានដឹកនាំសហការី ចុះស្វែងយល់អំពីនីតិវិធី និងដំណើរការផ្ដល់បណ្ណអនុញ្ញាតឱ្យធ្វើការដោយមន្ត្រីការិយាល័យច្រកចេញចូលតែមួយទទួ លនិងបញ្ជូនពលករខ្មែរទៅធ្វើការនៅតាមបណ្ដាខេត្តនានាក្នុងប្រទេសថៃ នៃមន្ទីរស្វែងរកការងារខេត្តសាកែវ ជូនពលករខ្មែរដែលមកធ្វើការនៅប្រទេសថៃដោយស្របច្បាប់។ លោកអគ្គកុងស៊ុលបានថ្លែងអំណរគុណលោកប្រធានមន្ទីរស្វែងរកការងារខេត្តសាកែវ ដែលបានរៀបចំកន្លែងរង់ចាំស្អាតសមរម្យ បន្ទប់ទឹកមានអនាម័យ ពន្លឿននីតិវិធីផ្ដល់បណ្ណអនុញ្ញាតឱ្យធ្វើការ ក៏ដូចជាការពិនិត្យសុខភាពជូនបងប្អូនពលករយ៉ាងលឿនរហ័ស មិនឱ្យបងប្អូនរង់ចាំយូរ និងពិនិត្យគុណភាពរថយន្តដឹកបងប្អូនពលករទៅកាន់គោលដៅដោយសុវត្ថិភាព។

ទន្ទឹមនេះ លោកអគ្គកុងស៊ុលនិងសហការី ក៏បានស្វែងយល់អំពីការអប់រំពលករខ្មែរដែលមកធ្វើការនៅប្រទេសថៃ អំពីសិទ្ធិនិងកាតព្វកិច្ចរបស់បងប្អូនពលករក៏ដូចជាសិទ្ធិនិងកាតព្វកិច្ចរបស់ថៅកែថៃ ព្រមទាំងរបៀបរបបរស់នៅក្នុងប្រទេសថៃ ជូនបងប្អូនពលករខ្មែរ។ ឆ្លៀតឱកាសនេះដែរ លោកអគ្គកុងស៊ុលក៏បានជួបសំណេះសំណាល ផ្ដល់ព័ត៌មានសំខាន់ៗ ដូចជា លេខទូរស័ព្ទមន្ត្រីស្ថានអគ្គកុងស៊ុល មន្ត្រីទីប្រឹក្សាទទួលបន្ទុកពលករអមស្ថានទូតកម្ពុជានៅទីក្រុងបាងកក ទំព័រហ្វេសប៊ុកស្ថានអគ្គកុងស៊ុល-ស្ថានទូត ជូនបងប្អូនពលករទុកសម្រាប់ទាក់ទងពេលជួបបញ្ហាលំបាក ឬចង់ប្រឹក្សាយោបល់ទាក់ទងនឹងការងារ។

លោកអគ្គកុងស៊ុលក៏បានណែនាំឱ្យបងប្អូនពលករចេះស្រឡាញ់សាមគ្គីគ្នា ក្នុងនាមជាខ្មែរដូចគ្នា ដូចពាក្យស្លោកខ្មែរថា "នៅផ្ទះម្ដាយទីទៃ ទៅព្រៃម្ដាយតែមួយ" ព្រមទាំងពាំនាំការសួរសុខទុក្ខពីសំណាក់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុនសែន និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងលោកជំទាវ ជូនបងប្អូនពលករទាំងអស់។ ជានិច្ចកាលថ្នាក់ដឹកនាំរាជរដ្ឋាភិបាលតែងយកចិត្តទុកដាក់ចំពោះបងប្អូនពលករនិងពលរដ្ឋខ្មែរនៅគ្រប់ទិសទី។ លោកអគ្គកុងស៊ុលក៏បានជូនពរបងប្អូនពលករមានសុខភាពល្អ ធ្វើការបានជោគជ័យនិងទទួលបានប្រាក់ខែឡើងខ្ពស់ជាលំដាប់៕

## ស្លាប់ទៀតហើយ ស្ត្រីពលករខ្មែរម្នាក់ ធ្វើការសំណង់ ស្លាប់យ៉ាងអាណោចអាធ័មដោយសារបាក់ជីសង្កត់លើ

https://khmernews.news/article/ ស៊ីហៀង 22-07-2019

យោងទៅតាមគណនីហ្វេសប៊ុកមួយដែលមានឈ្មោះថា កូន ខ្លាតូច បានធ្វើការលើកឡើងឲ្យដឹងនៅលើបណ្ដាញសង្គមហ្វេសប៊ុកថា " ហឹម..ជីវិតកម្មករខ្មែរយើងហេតុអីក៏អភព្វ័យ៉ាងនេះ បាក់ជីសង្កត់ស្លាប់នៅស្រុកគេទៀតហើយ 20.07.2019 មានករណីជីបាក់សង្កត់ស្ត្រីពលករខ្មែរ ធ្វើការសំណង់ ស្លាប់យ៉ាងអាណោចអាធ័ម។ ជនរងគ្រោះ

មានឈ្មោះ កេត សារិន អាយុ40ឆ្នាំ ហេតុការណ៍នេះកើតឡើងនៅវេលាម៉ោង12ថ្ងៃត្រង់ ស្ថិតនៅលើផ្លូវជាតិលេខ344 ឈុនបុរី -ក្រែង នៃស្រុកស៊ីរាធា ខេត្តឈុនបុរី។

## អគ្គកុងស៊ុលជួបពិភាក្សាការងារជាមួយប្រធានមន្ទីរគាំពារពលករខេត្តសាកែវ

https://www.facebook.com/consulatesakaeo/ Consulate General in Sa Kaeo July 18 at 12:59 PM •

អារញ្ញប្រាថេត, ថ្ងៃ ព្រហស្បតិ៍ ០២រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី 18 ខែកក្កដា ឆ្នាំ2019 អគ្គកុងស៊ុល ហ៊ុន សារឿន បានទទួលជួបលោក កាន់តាភីត ប្រាក់ដាប់កាន ប្រធានមន្ទីរគាំពារពលករខេត្តសាកែវ (ស្រះកែវ) ពិភាក្សាការងារពាក់ព័ន្ធនឹងកិច្ចគាំពារបងប្អូនពលករខ្មែរដែលបាន និងកំពុងស្នាក់នៅនិងធ្វើការនៅក្នុងភូមិសាស្ត្រខេត្តសាកែវនិងខេត្តចំនួន 7 ផ្សេងទៀតដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ស្ថានអគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំខេត្តសាកែវ។

លោកប្រធានមន្ទីរគាំពារពលករបានជម្រាបលោកអគ្គកុងស៊ុលថា តបតាមសំណើរបស់ស្ថានអគ្គកុងស៊ុលកន្លងមក មន្ទីរគាំពារពលករខេត្តសាកែវបានជម្រុញសំណុំរឿងទាមទារសំណងជូនពលករខ្មែរដែលរងគ្រោះការងារបានជាច្រើនករណី និងបាននិងកំពុងដំណើរការលើករណីមួយចំនួនទៀត។

លោកអគ្គកុងស៊ុលបានថ្លែងអំណរគុណចំពោះមន្ទីរគាំពារពលករខេត្តសាកែវ ដែលតែងបានផ្តល់កិច្ចសហការល្អជាមួយស្ថានអគ្គកុងស៊ុល និងសំណូមពរឲ្យបន្តពង្រឹងកិច្ចសហប្រតិបត្តិការនេះកាន់តែប្រសើរថែមទៀត ដើម្បីគាំពារនិងការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់បងប្អូនពលករខ្មែរ។

លោកប្រធានមន្ទីរគាំពារពលករខេត្តសាកែវ បានសន្យាថា នឹងបន្តកិច្ចសហប្រតិបត្តិការល្អជាមួយស្ថានអគ្គកុងស៊ុលក្នុងការគាំពារសិទ្ធិនិងផលប្រយោជន៍ស្របច្បាប់របស់បងប្អូនពលករខ្មែរដែលស្នាក់នៅនឹងធ្វើការក្នុងខេត្តសាកែវ៕

## ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០១៩

## សម្តេចក្រឡាហោម ស ខេង ដឹកនាំកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ស្ថាប័ន ចំនួន៦ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆមាសទី១ ឆ្នាំ២០១៩

https://www.chnchannel.com/ អត្ថបទដោយ Kongkea Leuk កាលបរិច្ឆេទ ថ្ងៃទី 23 ខែ កក្កដា ឆ្នាំ 2019

**ភ្នំពេញ៖** នៅព្រឹកថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដឹកនាំកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ស្ថាប័ន ចំនួន៦ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆមាសទី១ ឆ្នាំ២០១៩។ កិច្ចប្រជុំនេះ ត្រូវបានធ្វើឡើងនៅទីស្តីការក្រសួងមហាផ្ទៃ។

របាយការណ៍អំពីការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ សម្រាប់ឆមាសទី១ ឆ្នាំ២០១៩ បានបង្ហាញថា អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត១៩ បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន៧៨ករណី លើ៦២ករណី (កើនឡើង១៦ករណី ស្មើនឹង២៥%)។ ក្នុងនោះ ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូង ចំនួន៩៧នាក់/៨៥នាក់ (កើន១២នាក់ ស្មើនឹង១៤%) ក្នុងនោះស្រី២២នាក់ អនីតិជន០៩នាក់ ជាជនបរទេស ១៤នាក់សញ្ជាតិចិន ១២នាក់ និងអាមេរិក០២នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន២៦៣នាក់ (លើ១០៦នាក់) កើន១៥៧នាក់ ស្មើនឹង១៤៨% ក្នុងនោះមាន អាយុក្រោម១៥ឆ្នាំ ៧០នាក់ អាយុ១៥-១៧ឆ្នាំ ៣១នាក់ និងពី១៨ឆ្នាំឡើង ១៦២នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច៧២នាក់ និងប្រគល់ទៅគ្រួសារ១៩១នាក់)។

ដោយឡែក ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរូបភាពអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ក្នុងឆមាសទី១ ឆ្នាំ២០១៩នេះ ក្រសួងការបរទេស និងច្រកចេញចូលតែមួយ របស់ក្រសួងមហាផ្ទៃ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានទទួលពាក្យ និងធ្វើសម្ភាសន៍ពលរដ្ឋខ្មែរនិងជនបរទេស សរុបចំនួន១,០០៩គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។

ជាមួយគ្នានេះ ជំនាញនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទំនាក់ទំនងសាកសួរព័ត៌មានអំពីនារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីនៅក្រៅប្រទេស បានចំនួន៧៤នាក់ ដើម្បីតាមដានស្ថានភាព ដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្ស តាមរយៈការរៀបអាពាហ៍ពិពាហ៍៕

## កម្ពុជាប្រាប់អាមេរិក កុំឲ្យយករឿងនយោបាយមកវាយតម្លៃ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

http://www.freshnewsasia.com/ 2019-07-23

**(ភ្នំពេញ)៖** រាជរដ្ឋាភិបាលកម្ពុជា តាមរយៈគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកម្ពុជា បានផ្ដាំទៅកាន់សហរដ្ឋអាមេរិកថា កុំព្យាយាមយករឿងនយោបាយ ពិសេសពាក់ព័ន្ធជាមួយអតីតគណបក្សប្រឆាំង មកវាយតម្លៃលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ខណៈការងារនេះកម្ពុជា កំពុងតែខិតខំបង្ការទប់ស្កាត់ និងសង្គ្រោះជាប់ជាប្រចាំ។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានអះអាងថា រហូតមកដល់ពេលនេះ សហរដ្ឋអាមេរិក បានបន្តផ្ដល់ចំណាត់ថ្នាក់លេខ២ ដល់ប្រទេសកម្ពុជា ដែលជាប្រទេសស្ថិតក្នុងការឃ្លាំមើល លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ការឲ្យដឹងរបស់លោកស្រី ជូ ប៊ុនអេង ត្រូវបានធ្វើឡើង នៅព្រឹកថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩នេះ ក្រោយបញ្ចប់កិច្ចប្រជុំក្រុមការងារអន្តរក្រសួង ស្ថាប័ន ចំនួន៦ ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆមាសទី១ ឆ្នាំ២០១៩ ក្រោមអធិបតីភាព សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ កិច្ចប្រជុំនេះ ត្រូវបានធ្វើឡើងនៅទីស្ដីការក្រសួងមហាផ្ទៃ។

មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃរូបនេះ បានអះអាងថា គ្រប់ប្រទេសដែលជាហត្ថលេខី នៃអនុសញ្ញាអន្តរជាតិ ស្ដីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដែលក្នុងនោះ មានអំពើជួញដូរមនុស្សដែរនោះ បាននិងកំពុងខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់ទាក់ទងការបង្ការ ទប់ស្កាត់ ការជួយជនរងគ្រោះ ការអនុវត្តច្បាប់ ដែលមានទាំងការបង្ក្រាប មានសង្គ្រោះ មានផ្ដន្ទាទោស ឬមួយទាក់ទងការជួយជនរងគ្រោះ នៃអំពើនេះជាដើម។ លោកស្រី ជូ ប៊ុនអេង បានថ្លែងយ៉ាងដូច្នេះថា «អ្វីដែលយើងខំប្រឹងធ្វើ គឺធ្វើតាមហ្នឹងហើយ ប៉ុន្តែយើងចង់និយាយថា មានរឿងខ្លះដែលគាត់(អាមេរិក) ដាក់សម្ពាធ បន្ថែមទៀតថា ឲ្យយើងធ្វើនេះធ្វើនោះ រហូតដល់គាត់កាយបញ្ចូលទៅក្នុងការងារនយោបាយ ដែលគាត់យកករណីបក្សប្រឆាំងអីមកនិយាយចូលក្នុងនេះ វាមិនមែនជារឿងដែលគួរនិយាយ បានន័យថា វាជារឿងបច្ចេកទេសក្នុងការប្រយុទ្ធប្រឆាំងអំពើញជួញដូរមនុស្ស មិនគួរយករឿងនយោបាយមកវាយតម្លៃកម្ពុជាទាបបែបនេះទេ»។

គួរជម្រាបថា សហរដ្ឋអាមេរិក បានផ្ដល់ចំណាត់ថ្នាក់លេខ២ ដល់ប្រទេសកម្ពុជា ដែលជាប្រទេសឃ្លាំមើលលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះ រយៈពេល៣ឆ្នាំជាប់គ្នា ខណៈការវាយតម្លៃនេះ មានការប៉ះពាល់ដល់ឥទ្ធិពលនយោបាយ ពិសេសនយោបាយអន្តរជាតិ ដែលបរទេសមិនបានឃើញកម្ពុជា នឹងជឿលើការវាយតម្លៃនេះ ហើយគេគិតថា កម្ពុជាមិនយកចិត្តទុកដាក់លើការងារនេះឡើយ។ នេះជាអ្វីដែលលោកស្រី ជូ ប៊ុនអេង បានគូសបញ្ជាក់។

ឆ្លើយតបនឹងបញ្ហានេះ លោកស្រី ជួន ប៊ុនអេង បានឲ្យដឹងថា សម្ដេចក្រឡាហោម ស ខេង ក្នុងកិច្ចប្រជុំជិត៣ម៉ោងនាព្រឹកមិញនេះ ក៏បានណែនាំដល់អន្តរក្រសួងទាំងអស់ ត្រូវតែជំរុញបន្ថែមទៀតលើការងារនេះ ដើម្បីធ្វើយ៉ាងណាឲ្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះ អាចស្តារពីលេខ២ ជាប្រទេសក្នុងការឃ្លាំមើលវិញមក។

សម្តេចក្រឡាហោម ស ខេង ក៏បានគូសបញ្ជាក់ទៀតថា រាល់ចំណុចណាដែលខ្វះខាតត្រូវតែកែលម្អឡើងវិញ ហើយត្រូវជំរុញឲ្យចេញឲ្យបានឆាប់ ពាក់ព័ន្ធច្បាប់ស្តីពីគោលនយោបាយ ឬវិធានការផ្សេងៗ។

សូមបញ្ជាក់ថា របាយការណ៍អំពីការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ សម្រាប់ឆមាសទី១ ឆ្នាំ២០១៩ បានបង្ហាញថា អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ១៩ បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន៧៨ករណី លើ៦២ករណី (កើនឡើង១៦ករណី ស្មើនឹង២៥%)។ ក្នុងនោះ ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូង ចំនួន៩៧នាក់/៨៥នាក់ (កើន១២នាក់ ស្មើនឹង១៤%) ក្នុងនោះស្រី២២នាក់ អនីតិជន០៩នាក់ ជាជនបរទេស ១៤នាក់សញ្ជាតិចិន ១២នាក់ និងអាមេរិក០២នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន២៦៣នាក់ (លើ១០៦នាក់) កើន១៥៧នាក់ ស្មើនឹង១៤៨% ក្នុងនោះមាន អាយុក្រោម១៥ឆ្នាំ ៧០នាក់ អាយុ១៥-១៧ឆ្នាំ ៣១នាក់ និងពី១៨ឆ្នាំឡើង ១៦២នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច៧២នាក់ និងប្រគល់ទៅគ្រួសារ១៩១នាក់)៕

## ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៩

## ៦ ខែ សមត្ថកិច្ចបង្ក្រាបអំពើជួញដូរមនុស្ស និង ជួញដូរផ្លូវភេទ បាន ៧៨ ករណីកើន ២៥% សង្គ្រោះជនរងគ្រោះបាន ២៦៣ នាក់

https://www.postkhmer.com/ ម៉ិច ដារ៉ា | Publication date 24 July 2019 | 14:07 ICT

**ភ្នំពេញៈ** នៅក្នុងរយៈពេល ៦ ខែដើមឆ្នាំ ២០១៩ នេះ សមត្ថកិច្ចបានធ្វើការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើជួញដូរផ្លូវភេទបានចំនួន ៧៨ ករណីគឺមានការកើនឡើង ២៥ ភាគរយ និងបានជួយសង្គ្រោះជនរងគ្រោះបានចំនួន ២៦៣ នាក់ គឺកើនឡើង ១៤៨ ភាគរយ បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានចេញរបាយការណ៍បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើជួញដូរផ្លូវភេទ កាលពីម្សិលមិញនៅក្នុងកិច្ចប្រជុំ ក្រុមការងារអន្តរក្រសួង ស្ថាប័នចំនួន ៦ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងឆមាសទី១ ឆ្នាំ ២០១៩ ដែលកិច្ចប្រជុំនេះ ដឹកនាំដោយលោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ។ របាយការណ៍នេះ បានកត់ត្រាថា អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្តចំនួន ១៩ បានតាមដានស្រាវជ្រាវបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបានចំនួន ៧៨ ករណី ខណៈដែលរយៈពេលដូចគ្នាកាលពីឆ្នាំមុនមាន ៦២ ករណី (កើនឡើង ១៦ ករណី ស្មើនឹង ២៥ ភាគរយ)។ របាយការណ៍ដដែលបន្តថា ក្នុងនោះឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅតុលាការបានចំនួន ៩៧ នាក់ ខណៈរយៈពេលដូចគ្នាកាលពីឆ្នាំមុនមាន ៨៥ នាក់ (កើន ១២ នាក់ ស្មើនឹង ១៤%) ក្នុងនោះស្ត្រី ២២ នាក់អនីតិជន ៩ នាក់ជាជនបរទេស ១៤ នាក់ សញ្ជាតិចិន ១២ នាក់និងអាមេរិក ២ នាក់ ហើយបានសង្គ្រោះជនរងគ្រោះចំនួន ២៦៣ នាក់ ខណៈកាលពីឆ្នាំមុនសង្គ្រោះបាន ១០៦ នាក់ គឺកើន ១៥៧ នាក់ ស្មើនឹង ១៤៨% ក្នុងនោះមានអាយុក្រោម ១៥ ឆ្នាំ ៧០ នាក់ អាយុ ១៥ ដល់ ១៧ ឆ្នាំ ៣១ នាក់ និងពី ១៨ ឆ្នាំឡើង ១៦២ នាក់ ហើយបានប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន ៧២ នាក់ និងប្រគល់ទៅគ្រួសារពួកគេវិញ ១៩១ នាក់។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានថ្លែងប្រាប់អ្នកសារព័ត៌មាន ក្រោយពីបញ្ចប់កិច្ចប្រជុំបិទទ្វារថា របាយការណ៍នេះគឺបង្ហាញថា សមត្ថកិច្ច និងអាជ្ញាធរពាក់ព័ន្ធ បានខិតខំធ្វើការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើជួញដូរផ្លូវភេទ។ លោកស្រីបញ្ជាក់ថា៖ «យើងអាចនិយាយបានថា យើងបានធ្វើការស៊ើបអង្កេតស្រាវជ្រាវ និងបង្ក្រាបបានច្រើនជាងឆ្នាំមុន សង្គ្រោះជនរងគ្រោះបានច្រើនជាងឆ្នាំមុន ហើយការផ្តន្ទាទោសបានច្រើនជាងឆ្នាំមុននៅក្នុងរយៈពេលដូចគ្នាដូច្នេះយើងវាយតម្លៃថា អ្វីដែលយើងធ្វើបានក្នុងដើមឆមាសនេះគឺល្អប្រសើរបើប្រៀបធៀបទៅនឹងឆ្នាំមុន»។ ទន្ទឹមនឹងនេះលោកស្រីក៏បានសម្តែងការសោកស្តាយ ដែលលោកស្រីថាអាមេរិកបានលើកយកអតីតគណបក្សសង្គ្រោះជាតិមកវាយតម្លៃឲ្យកម្ពុជាជាប់ចំណាត់ថ្នាក់លេខ ២ លើការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដែលបញ្ហានេះ ជារឿង ២ ដាច់ដោយឡែកពីគ្នា។ លោកស្រីបន្តថា៖ «មានរឿងខ្លះដែលគាត់ដាក់សម្ពាធបន្ថែមទៀតឲ្យយើងធ្វើនេះធ្វើនោះរហូត គាត់ដាក់បញ្ចូលទៅក្នុងការងារនយោបាយដែលគាត់យកករណីបក្សប្រឆាំងនិយាយចូលនៅក្នុងនេះវាជារឿងមិនគួរនិយាយបានន័យថា វាជារឿងបច្ចេកទេស ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សមិនគួរយករឿងនយោបាយមកវាយតម្លៃកម្ពុជា ទាបបែបនេះទេ»។ បើតាមលោកស្រី ប៊ុនអេង នៅក្នុងកិច្ចប្រជុំនេះ លោក ស ខេង បានជំរុញឲ្យភាគីពាក់ព័ន្ធទាំងអស់ត្រូវបន្តប្រឹងប្រែងជួយទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើជួញដូរផ្លូវភេទ ដោយលោកលើកឡើងថា បើសិនកម្ពុជាមិនខំប្រឹងប្រែងទេនោះ កម្ពុជានឹងធ្លាក់ទៅលេខ ៣ ជាមិនខាន។

លោកស្រី រស់ សុភាព នាយិកាប្រតិបត្តិនៃអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជាបានសម្តែងការអបអរសាទរចំពោះលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់សមត្ថកិច្ច និងអាជ្ញាធរពាក់ព័ន្ធ ក្នុងការបង្ក្រាបការជួញដូរមនុស្សទទួលបានលទ្ធផលល្អបែបនេះ។ ទោះយ៉ាងណាលោកស្រីថ្លែងថា ស្ត្រីនៅតែប្រឈម និងអំពើជួញដូរមនុស្ស និងអំពើជួញដូរផ្លូវភេទ នៅតាមកន្លែងកម្សាន្តមួយចំនួន និងការជួញដូរមនុស្ស តាមរូបភាពអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។ លោកស្រីបញ្ជាក់ថា៖ «ពួកគាត់នៅតែប្រឈមមុខទៅនឹងការកេងប្រវ័ញ្ចក្រោមស្លាក KTV និងក្លិបហើយពេលស្ត្រីត្រូវបានភ្ញៀវរំលោភឬវាយដំ អ្នកដែលផ្តល់សេវាហ្នឹងមិនមានវិធានការអីដែលអាចជួយស្ត្រីនោះឲ្យមានសុវត្ថិភាព និងការពារសិទ្ធិនោះទេ»។

បើតាម គ.ជ.ប.ជ ការបង្ការទប់ស្កាត់ ការជួញដូរមនុស្សតាមរូបភាពអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ក្នុងឆមាសទី ១ ឆ្នាំ ២០១៩ ក្រសួងការបរទេស និងប្រកចេញចូលតែមួយរបស់ក្រសួងមហាផ្ទៃទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានទទួលពាក្យ និងធ្វើសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសសរុបចំនួន ១០០៩ គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់៕

## ជនជាតិអាមេរិកម្នាក់ចោទប្រកាន់ពីបទរំលោភផ្លូវភេទលើកុមារកម្ពុជាអាយុ ១៦ឆ្នាំនៅក្នុងខេត្តសៀមរាប

https://www.rfa.org/khmer/news/law/ ដោយ ហេង រស្មី 2019-07-23

តុលាការខេត្តសៀមរាបថ្មីៗនេះ បានចោទប្រកាន់បុរសជនជាតិអាមេរិកកាំងម្នាក់អាយុ ៥៦ឆ្នាំ មកពីរដ្ឋ Massachusetts ពីបទទិញពេស្យាចារកុមារ រូបអាសអាភាសកុមារ និងចាប់រំលោភ បំពានច្បាប់ការជួញដូរមនុស្ស និងកេងប្រវ័ញ្ចផ្លូវភេទ។

សេចក្តីថ្លែងការណ៍របស់អង្គការសកម្មភាព ដើម្បីកុមារ ដែលហៅកាត់ថា APLE ចេញផ្សាយនៅថ្ងៃទី២០ កក្កដា ឱ្យដឹងថា ការចោទប្រកាន់នេះបានធ្វើឡើងក្រោយពីប៉ូលិសប្រឆាំងនឹងការជួញដូរមនុស្ស និងអតិជននៅក្នុងខេត្តសៀមរាប បាននាំយកបុរសជនជាតិអាមេរិកម្នាក់មកសារសួរនៅក្នុងទីស្នាក់ការប៉ូលិសពាក់ព័ន្ធនឹងការរំលោភផ្លូវភេទ

លើកុមារអាយុ ១៦ឆ្នាំ។ ជនសង្ស័យត្រូវបាននាំខ្លួនចេញពីផ្ទះជួលរបស់លោកមានទីតាំងនៅភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ខេត្តសៀមរាប។

ការស៊ើបអង្កេតដែលនាំទៅដល់ការចាប់ខ្លួននេះបន្ទាប់ពីអង្គការ APLE ទទួលពាក្យបណ្ដឹងពីអង្គការសង្គមស៊ីវិលក្នុងស្រុកជំរុញអោយមានការស៊ើបអង្កេតទៅលើជនសង្ស័យដែលបានរស់នៅជាមួយក្មេងប្រុសកម្ពុជារហូតដល់អ្នកទាំងពីរមានទំនាក់ទំនងស្និទ្ធស្នាលជាមួយគ្នា។

ប៉ូលិសបានរកឃើញថា មានឧបករណ៍មួយចំនួន ដែលរួមមាន ទូរស័ព្ទដៃ ឧបករណ៍សម្រាប់ជួយរំញ័រ ថ្នាំសម្រើបប្រភេទ Viagra ហើយនិងទឹករំអិល Vaselin ដែលវត្ថុទាំងនោះបានរកឃើញនៅផ្ទះរបស់ជនសង្ស័យ ក្រៅពីនោះប៉ូលិសក៏បានរកឃើញរូបថតអាក្រាតរបស់កុមារាកម្ពុជាជាច្រើនសន្លឹក ដែលសមត្ថកិច្ចបានរឹបអូសទុកជាវត្ថុ តាងទៀតផង។ ការចាប់ខ្លួនបុរសជនជាតិអាមេរិកនេះបានកើតមានឡើងជាលើកទី១២ ហើយទាក់ទិននិងករណីរំលោភផ្លូវភេទលើកុមារកម្ពុជាដែលបានរកឃើញដោយអង្គការសេកម្មភាព ដើម្បីកុមារដែលហៅកាត់ថា APLE ក្នុងរយៈពេល ៧ ខែ ឆ្នាំ២០១៩នេះ៕

## កងកម្លាំងការពារព្រំដែនកម្ពុជា-ថៃចំនួន២៥នាក់ បានចុះល្បាតតាមបន្ទាត់ព្រំដែន រួមគ្នាទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់ និងត្រួតពិនិត្យបង្គោលសីម៉ាព្រំដែនលេខ៣៧

http://cambodiapolice.com/policekh/ 8:06 pm 24 កក្កដា 2019 289

បន្ទាយមានជ័យ៖ កងកម្លាំងការពារព្រំដែនកម្ពុជា-ថៃសរុប២៥នាក់ បានសហការចុះល្បាតតាមបន្ទាត់ព្រំដែនរួមគ្នាដើម្បីទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់គ្រប់ប្រភេទ ការការពារថែរក្សាសន្តិសុខសុវត្ថិភាពតាមបន្ទាត់ព្រំដែននិងបានចុះទៅត្រួតពិនិត្យស្ថានភាព បង្គោលសីម៉ាព្រំដែនលេខ២៧ ដែលស្ថិតនៅភូមិក្តិបថ្ម ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ឈមនិងទឹកដីថៃភូមិខៅលូកឆាង ឃុំទ័ពសៀម ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ ប្រទេសថៃ។

ការចុះល្បាតតាមបន្ទាត់ព្រំដែន រវាងកងកម្លាំងការពារព្រំដែនទាំង២ភាគី ធ្វើឡើងនៅព្រឹកថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ ត្រូវគេមើលឃើញថាស្របតាម ខ្លឹមសារក្នុងកិច្ចប្រជុំ គណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគ(១)ថៃ-ភូមិភាគ៥(កម្ពុជា)(RBC) លើកទី២៧ កាលពីថ្ងៃទី២ដល់ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៩ នៅទី ក្រុងបាងកក នៃព្រះរាជាណាចក្រថៃ។ កិច្ចសហប្រតិបត្តិការចុះល្បាតតាមព្រំដែន ដើម្បីទប់ស្កាត់ការលបលួចកាប់ឈើខុសច្បាប់,ការប្រយុទ្ធប្រឆាំងការជួញដូរគ្រឿងញៀន,ការជួញដូរមនុស្សនិងឧក្រិដ្ឋកម្មឆ្លងដែនខុសច្បាប់។ កិច្ចប្រជុំនោះផងដែរភាគីទាំង២ក៏បាន ស្នើឲ្យមានការទំនាក់ទំនង និងផ្តល់ព័ត៌មានគ្នាទៅវិញទៅមកឱ្យដឹងជាមុនបើសិន មានការអនុវត្តហោះហើរលើដែនអាកាសល្បាតតាមព្រំដែន។

សេចក្តីរាយការណ៍ បានឲ្យដឹងថា កងកម្លាំងការពារព្រំដែនទាំង២ភាគីកម្ពុជា-ថៃ ដែលចុះល្បាតតាមបន្ទាត់ព្រំដែននោះ ភាគីកម្ពុជាមានការចូលរួម ដោយកម្លាំងនគរបាលការពារព្រំដែនគោកនៃវរៈសេនាតូច៨០៧ កងការពារព្រំដែនលេខ៥០៣ កម្លាំងទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ ប្រចាំនៅបឹងត្រកួន សរុប១៥នាក់ ដែលដឹកនាំដោយលោកវរសេនីយ៍ត្រី ព្រីម ផុន នាយរងការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ ប្រចាំច្រកទ្វារព្រំដែនបឹងត្រកួន។ ចំណែកកម្លាំងតម្រួត(ត ធ ដ)ភាគីថៃមានចំនួន១០នាក់ដឹកនាំដោយអនុសេនីយ៍ឯក សាន់ឆៃ យូធាលឹម មេបញ្ជាការរងកងរយ១២៥ ។ សេចក្តីរាយការណ៍បន្ត បានឲ្យដឹងថា ការចុះបំពេញភារកិច្ចល្បាតព្រំដែនរួមគ្នានោះផងដែរ ភាគីកងកម្លាំងការពារព្រំដែនទាំង២ក៏បានលើកឡើង ត្រូវមានកិច្ចសហប្រតិបត្តិការគ្នាឱ្យកាន់តែរឹងមាំ បង្កើនមិត្តភាព សាមគ្គីភាព ឱ្យកាន់ប្រសើរឡើង ឈរលើស្មារតីយោគយល់គ្នាទៅវិញទៅមកក្នុងនាមប្រទេសជាតិខាងនិងគ្នានោះ។

សូមបញ្ជាក់ថា ខេត្តបន្ទាយមានជ័យមានខ្សែបន្ទាត់ព្រំដែនរវាងកម្ពុជា-ថៃប្រវែង១៥៣គីឡូម៉ែត្រ ដែលមានបង្គោលសីម៉ា២៥បង្គោល ចាប់ពីបង្គោលសីម៉ាលេខ២៧រហូតដល់បង្គោលលេខ៥១។ ក្នុងនោះបង្គោលដែលមានការ

ឯកភាពគ្នាចំនួន១៤បង្គោល និងមិនឯកភាពគ្នាចំនួន១១បង្គោល និងបាត់រូបរាងចំនួន៤បង្គោលសីម៉ាផងដែរ។
*សម្រួលដោយ៖ លោកស្រី វ.ទោ ជា សារ៉ាត់*

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០១នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 24-07-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០១នាក់ នាវេលាម៉ោង ១៧និង៤០នាទី ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ។

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០២នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 24-07-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០២នាក់ នាថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកចាក់ប្រែង ខេត្តព្រះវិហារ។

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០២នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI July 23 at 5:21 PM

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០២នាក់ នាវេលាម៉ោង ១៦និង៥០នាទី ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ។

## ពលករខ្មែរទៅធ្វើការនៅប្រទេសថៃម្នាក់ បានភ្លាត់ជើងផុងធ្លាក់ ពីលើដំបូលផ្ទះមកក្រោម បណ្តាលឲ្យស្លាប់ភ្លាមៗក្រោយពីបញ្ជូនទៅដល់មន្ទីរពេទ្យ

https://khmernews.news/article/archives/ ស៊ីហៀង 25-07-2019

កាលពីថ្ងៃម្សិលមិញនេះ មានគណនីហ្វេសប៊ុកមួយដែលមានឈ្មោះថា Phorn Phana បានបង្ហោះសារ អមជាមួយនិង រូបភាពរបស់ជីវិតពលករខ្មែរយើងម្នាក់ បានស្លាប់បាត់បង់ជីវិត ដោយរអិលជើងធ្លាក់ ខណៈពេលកំពុងឡើងប្រក់ដំបូលផ្ទះ។ ម្ចាស់គណនីហ្វេសប៊ុកបានរៀបរាប់ថា "ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៩ ប្រទេសថៃ ជីវិតពលករចំណាកស្រុកនៅប្រទេសថៃ! ពលករ លោក ហៀង សុខឿន គ្រោះថ្នាក់ពេលកំពុងធ្វើការ ឡើងប្រក់ដំបូលផ្ទះ ហើយបានភ្លាត់ជើងផុងធ្លាក់មកក្រោម នៅខេត្ត ឆាក់ឈើងសៅ ប្រទេសថៃ។ លោក ហៀង សុខឿន មានស្រុកកំណើត នៅភូមិ រឿក្រោម ឃុំ ជីក្រែង ខេត្ត ត្បូងឃ្មុំ។ ហេតុការណ៍នេះបានកើតឡើង នៅវេលាម៉ោង ២.២៥នាទី

សៀល ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៩ ហើយថៅកែបានដឹកយកទៅសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យ ដោយសារសភាព គាត់ធ្ងន់ធ្ងរពេទ្យខំជួយដែរតែក៏ជួយសង្គ្រោះមិនបានគាត់បានស្លាប់នៅវេលាម៉ោង ៣.០០នាទីរសៀល នៅថ្ងៃដដែល។

## ពលករខ្មែរ២នាក់ក្នុងចំណោម៤នាក់ ត្រូវតម្រួតថៃចាប់ខ្លួន ពីបទរំលោភក្មេងស្រី និងថត វីដេអូ ទុកដើម្បី គំរាមទារប្រាក់

http://khmer.peoplenews.asia/ ដោយ ៖ រិទ្ធី ថ្ងៃទី24 ខែ07 ឆ្នាំ2019 ម៉ោង 10:37 AM

ប្រទេសថៃ ៖ យុវតីជនជាតិថៃអាយុ១៣ឆ្នាំម្នាក់ ត្រូវបានក្រុមស្ទាវជាពលករខ្មែរទៅរកស៊ីធ្វើការនៅទីនោះ ល្បួងចាប់រំលោភបូករហូតដល់ទៅ៤នាក់បានសម្រេចម្តងម្នាក់ៗតាមលេខរៀង ហើយថែមទាំងបានថតវីដេអូនគម្រាម ទារប្រាក់ពីនាងចំនួន៣ពាន់បាតទៀតផង ។ ដោយទ្រាំនឹងទង្វើថោកទាបនេះមិនបានទើបនាងស្រេចចិត្តដាក់ពាក្យ បណ្ដឹងឲ្យសមត្ថកិច្ចចាប់ខ្លួន បាន២នាក់កាលពី កាលពីវេលាម៉ោង៩និង៣០នាទីយប់ ថ្ងៃទី២២ ខែកក្កដាឆ្នាំ ២០១៩ នៅចំណុចបន្ទប់ជួល ស្ថិតក្នុងតំបន់ភ្នំសាមមុខ ឃុំសែនសុខស្រុកមឿង ខេត្តឈុនបុរី ប្រទេសថៃ ។

បើតាមសមត្ថកិច្ចបានឲ្យដឹងថា ជនសង្ស័យទាំង២នាក់ដែលត្រូវឃាត់ខ្លួន ទី ១ឈ្មោះ ផាត់ ភេទប្រុស អាយុ ២៩ឆ្នាំ២ឈ្មោះ ឡឹត ភេទប្រុស អាយុ១៨ឆ្នាំ អ្នកទាំង២ ជាជនជាតិខ្មែរទៅបម្រើការងារនៅក្នុងប្រទេសថៃ ដោយ ឡែក២នាក់ទៀត កំពុងរត់គេចខ្លួន ។

បើយោងតាមពាក្យបណ្តឹងរបស់ក្មេងស្រីរងគ្រោះអាយុ១៣ឆ្នាំ រស់នៅក្នុងតំបន់ខាងលើ បាន ប្រាប់សមត្ថកិច្ច ថា ជនសង្ស័យបានធ្វើការល្បួងលោមនាងយកទៅរំលោភនៅក្នុងបន្ទប់ជួល តាំងពីថ្ងៃទី២ ខែកក្កដា មកម្ល៉េះ ដោយ ជនសង្ស័យមានគ្នា៤នាក់ ហើយការរំលោភនេះ បានសម្រេចម្នាក់ម្តងៗ ព្រមទាំងថតវីដេអូ ទុកគំរាមថែមទៀតផង ដោយពួកគេតម្រូវអោយនាងយកលុយទៅប្រគល់អោយពួកគេចំនួន៣០០០បាត ទើបគេព្រមបញ្ចប់បញ្ហា។ ក្មេងស្រី រងគ្រោះ បានបន្តថា ដោយសារអត់ទ្រាំនឹងទង្វើនេះមិនបាន នាងក៏សម្រេចចិត្ត ដាក់ពាក្យប្តឹងទៅសមត្ថកិច្ចតែម្តង បើ ទោះបីជាមានការប្រឈមនឹងគ្រោះថ្នាក់ក៏ដោយ ទើបឈានដល់ការចាប់ខ្លួនបាន២នាក់ ចំណែក២នាក់ទៀត កំពុងរត់ គេចខ្លួននៅឡើយ ។

ក្នុងការឃាត់ជ នសង្ស័យ២នាក់ខាងលើ សមត្ថកិច្ចដកហូតវត្ថុតាងមួយចំនួនដូចជាសម្លៀកបំពាក់ ក្នុងថ្ងៃ ប្រព្រឹត្តបទល្មើស និងខ្នោះដៃ១គូ ដែលគេបានដាក់ជាប់នឹងដៃនាងបត់ទៅខាងក្រោយ ក្នុងពេលធ្វើសកម្មភាពនោះ ។ បច្ចុប្បន្នជនសង្ស័យ ជាពលរដ្ឋខ្មែរទាំង២រូបនេះ ត្រូវបានសមត្ថកិច្ចជំនាញបញ្ជូនទៅកាន់តុលាការហើយ ដើម្បី អនុវត្ត តាមផ្លូវច្បាប់៕

## អគ្គរាជទូតកម្ពុជាចុះសួរសុខទុក្ខបងប្អូនពលករខ្មែរដែលកំពុងបម្រើការងារនៅក្រុមហ៊ុន, HANMI COLOR PACK នាទីក្រុងអានសាន ខេត្តខ្យុងគី

http://www.rasmeinews.com/ July 24, 2019, 4:06 PM *ដោយ: រ៉ាម៉ន*

*ភ្នំពេញ:* អគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសកូរ៉េខាងត្បូង លោកឡុង ឌីម៉ង់ អមដោយទីប្រឹក្សាការងារ កាលពី រសៀលថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩នេះ បានចុះសួរសុខទុក្ខបងប្អូនពលករខ្មែរចំនួន ១២នាក់ ដែលកំពុងបម្រើ ការងារនៅក្រុមហ៊ុន HANMI COLOR PACK Co.,Ltd នា ទីក្រុងអានសាន ខេត្តខ្យុងគី ដើម្បីចង់ដឹងពីសុខទុក្ខ និងការ រស់នៅរបស់បងប្អូនពលករខ្មែរទាំងនេះ។

ក្នុងឱកាសនោះ លោក Tae Ro Ahn ប្រធានក្រុមហ៊ុន HANMI COLOR PACK Co.,Ltd បានថ្លែងអំណរគុណ ដល់លោកឯកអគ្គរាជទូតដែលបានអញ្ជើញមកទស្សនៈកិច្ចនៅរោងចក្រ និងកោតសរសើរដល់ពលករកម្ពុជា ដែល

បានយកចិត្តទុកដាក់បំពេញការងារ ប្រកបដោយទំនួលខុសត្រូវខ្ពស់ និងមានអត្តចរិកស្លូតបូតសាមគ្គីភាព ហើយពលករភាគច្រើននៃរោងចក្រគឺជាពលករកម្ពុជា។ ឆ្លៀតក្នុងឱកាសនេះស្ថានទូតកម្ពុជា លោកឡុង ឌីម៉ង់ បានថ្លែងអំណរគុណដល់ លោក Gi Yong Lee អគ្គនាយកទីស្នាក់ការកណ្តាលគាំពារជនបរទេស មន្រ្តីសាលាក្រុងអានសាន ស្ថាប័នប៉ូលីស និងអ្នកពាក់ព័ន្ធ ដែលបានរៀបចំកម្មវិធីចុះសួរសុខទុក្ខនេះប្រកបដោយភាពរីករាយ និងស្និតស្នាល៕

## ស្ត្រីដែលត្រូវគេបោកយកទៅលក់នៅចិន រយៈពេល២៤ឆ្នាំ បានជួបជុំគ្រួសារវិញ ដោយសារហ្វេសប៊ុក

https://www.khmerload.com/ Meas Chan Dara, Khmerload 14:41 July 23, 2019

វៀតណាម៖ ស្ត្រីជនជាតិវៀតណាម ដែលត្រូវបានគេបោកយកទៅលក់នៅប្រទេសចិនអស់រយៈពេល២៤ឆ្នាំ បានវិលត្រលប់មកដល់ប្រទេសកំណើតរបស់ខ្លួនវិញហើយ។ ប្រភពបានឲ្យដឹងថា ស្ត្រីរងគ្រោះមានឈ្មោះ Lan កាលពីនាងមានអាយុ១៩ឆ្នាំ ក្នុងនាមជាកូនស្រីច្បងនៅក្នុងគ្រួសារ នាងត្រូវធ្វើការជាពលករនៅភូមិ Nghĩa Đàn ឆ្ងាយពីតំបន់ដែលនាងរស់នៅ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ បន្ទាប់មកនាងក៏ត្រូវបានគេបោកយកទៅប្រទេសចិនដើម្បីលក់ឲ្យបុរសចិនវ័យ៦៥ឆ្នាំម្នាក់ក្នុងតម្លៃ៣០០ដុល្លារអាមេរិក។ ក្រោយពីរស់នៅជាមួយបុរសវ័យចំណាស់ជាលក្ខណៈប្តីប្រពន្ធអស់រយៈពេល១៣ឆ្នាំមក នាងក៏មានកូនចំនួន៤នាក់។ ប្រភពបានបន្តថា អំឡុងពេលរស់នៅជាមួយប្តីជនជាតិចិននោះ នាងទទួលរងអំពើហិង្សាយ៉ាងខ្លាំង។ ពេលខ្លះនាងត្រូវបានប្តីឃុំទុកក្នុងបន្ទប់ងងឹត និងបង្ខំឲ្យប្រើប្រាស់គ្រឿងញៀនដល់ថ្នាក់បាត់បង់ការចងចាំបន្តិចបន្តួចទៀតផង។ ក្រោយមក នាងត្រូវបានប្តីលក់ទៅឲ្យបុរសមួយទៀតដែលសព្វថ្ងៃនេះកំពុងរស់នៅជាមួយគ្នា។ ប្តីក្រោយរបស់នាងមានអាយុ៤៣ឆ្នាំ និងមើលថែនាងបានយ៉ាងល្អ។ នៅដើមខែកក្កដា ឆ្នាំ២០១៩ នាងបានស្គាល់ស្ត្រីជនជាតិវៀតណាមម្នាក់ដែលរស់នៅប្រទេសចិនដូចគ្នា។ នាងបានពឹងពាក់ឲ្យស្ត្រីនោះជួយថតវីដេអូបង្ហោះលើបណ្តាញសង្គមហ្វេសប៊ុកដើម្បីស្វែងរកគ្រួសារ។ នាងបានរៀបរាប់អាស័យដ្ឋានផ្ទះ និងឈ្មោះក្រុមគ្រួសារនៅក្នុងវីដេអូនោះ។ វីដេអូមួយនោះក៏ត្រូវបានក្រុមគ្រួសាររបស់នាងឃើញ ហើយសន្និដ្ឋានថាពិតជានាងប្រាកដមែន។ ក្រុមគ្រួសាររបស់នាងក៏បានប្តឹងប៉ូលិសដើម្បីស្វែងរកនាងឲ្យវិលត្រលប់មកប្រទេសវៀតណាមវិញ។ គួររម្លឹកដែរថា នៅពេលដែលនាងត្រូវបានគេបោកយកទៅលក់នៅប្រទេសចិន ក្រុមគ្រួសាររបស់នាងព្យាយាមស្វែងរកនាងយ៉ាងណា ក៏គ្មានទទួលបានព័ត៌មានអ្វីទាក់ទងនឹងនាងសោះឡើយ។

លោក Nguyen Thanh Hai ជាអនុប្រធានផ្នែកប៉ូលិសព្រហ្មទណ្ឌបាននិយាយថា «ក្នុងការស្វែងរកនាងគឺមិនមែនជាការងាយស្រួលនោះទេ ព្រោះនាងត្រូវបានគេយកទៅលក់ពីមនុស្សមួយទៅមនុស្សមួយទៀត។ ពួកយើងបានព្យាយាមប្រមូលឯកសារជាច្រើនដែលទាក់ទងនឹងនាងក្នុងការស៊ើបអង្កេតករណីនេះ។»ប៉ុន្មានថ្ងៃកន្លងទៅនេះ ក្រោយពីដោះស្រាយចប់រួចមក នាងក៏ត្រូវបានគេបញ្ជូនត្រឡប់មកទឹកដីប្រទេសវៀតណាតវិញដើម្បីជួបជុំក្រុមគ្រួសារ។ ម្តាយរបស់នាងសប្បាយចិត្តដល់ថ្នាក់ហូរទឹកភ្នែកក្រោយបែកកូនអស់២៤ឆ្នាំមកហើយ ព្រោះគាត់គិតថាកូនស្រីរបស់គាត់បានស្លាប់បាត់ទៅហើយ៕

# ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១៩

## ស៊ុយអ៊ែត សរសើរកម្ពុជាចំពោះប្រតិបត្តិការប្រឆាំងការជួញដូរមនុស្ស

https://www.information.gov.kh/detailnews/ ចេញផ្សាយថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៩ ជួន បូណា

ឯកអគ្គរដ្ឋទូតស៊ុយអ៊ែត សរសើរកម្ពុជាចំពោះប្រតិបត្តិការប្រឆាំងការជួញដូរមនុស្ស បន្ទាប់ពីកម្លាំងសមត្ថកិច្ចបានបង្ក្រាបអំពើជួញដូរមនុស្ស និងផ្លូវភេទ សរុបចំនួន ៧៨ករណី លើ ៦២ករណី។ លោកជំទាវ Maria Sargren ឯកអគ្គរដ្ឋទូតស៊ុយអ៊ែតប្រចាំកម្ពុជា បានលើកឡើងថា ការអនុវត្តការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្សរបស់រាជរដ្ឋាភិ

បាលកម្ពុជានាពេលកន្លងមកនេះ មានភាពប្រសើរដោយបានចាប់អ្នកដែលប្រព្រឹត្តអំពើជួញដូរមនុស្សមកដាក់ទោសតាមផ្លូវច្បាប់។

ការលើកឡើងនេះ ធ្វើឡើងក្នុងពេលលោកជំទាវចូលជួបជម្រាបលាសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កាលពីរសៀលថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៩ ក្នុងឱកាសលោកជំទាវត្រូវចប់អាណត្តិបេសកកម្មការទូតនៅកម្ពុជា។

ឯកឧត្តម ផាត សុផានិត អ្នកនាំពាក្យក្រសួងមហាផ្ទៃ បានប្រាប់អ្នកយកព័ត៌មាន ក្រោយជំនួបនេះ ដោយលើឡើងពីប្រសាន៍របស់សម្តេចក្រឡាហោម ស ខេង ដែលបានថ្លែងទៅលោកជំទាវ Maria Sargren ចំពោះកិច្ចខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចសហការជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងក្នុងប្រទេស និងក្រៅប្រទេស ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស។ ឯកឧត្ត ផាត សុផានិត អ្នកនាំពាក្យក្រសួងមហាផ្ទៃ បានឲ្យដឹងទៀតថា សម្តេចក្រឡាហោម ស ខេង បានបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងខិតខំបង្ក្រាបការជួញដូរមនុស្សនេះឲ្យកាន់តែល្អប្រសើរបន្ថែមទៀតដោយបានដក់ចេញគោលការណ៍តាមស្វែងរក និងចាប់ខ្លួនអ្នកដែលប្រព្រឹត្តអំពើជួញដូរមនុស្សយកមកដាក់ទោសតាមច្បាប់ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

យោងតាមរបាយការណ៍របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកម្ពុជា អំពីការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះបានបង្ហាញថា ក្នុងឆមាសទី១ ឆ្នាំ២០១៩ កម្លាំងសមត្ថកិច្ច បានបង្ក្រាបអំពើជួញដូរមនុស្ស និងផ្លូវភេទ សរុបចំនួន ៧៨ករណី លើ៦២ករណី ក្នុងនោះឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ៩៧នាក់ មានសញ្ជាតិចិន ១២នាក់ អាមេរិក ០២នាក់។ ជាមួយគ្នានេះ ក៏បានជួយសង្គ្រោះជនរងគ្រោះបានចំនួន ២៦៣នាក់ ក្នុងនោះមានអ្នកអាយុក្រោម១៥ឆ្នាំ ៧០នាក់ អាយុ១៥ ដល់ ១៧ឆ្នាំ ចំនួន ៣១នាក់ និងពីអាយុ១៨ឆ្នាំឡើងចំនួន ១៦២នាក់ ដោយប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន ៧២នាក់ និងប្រគល់ទៅគ្រួសារចំនួន ១៩១នាក់។

## កិច្ចពង្រឹងសម្ព័ន្ធមេត្រីភាពរវាងស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង និងប៉ៃលិន ជាមួយភាគីថៃ

https://news.kohsantepheapdaily.com.kh/ By mony koh July 25, 2019

ខេត្តបាត់ដំបង ៖ នៅទីបញ្ជាការដ្ឋានស្នងការដ្ឋាននគរបាលខេត្តច័ន្ទបុរី នៃព្រះរាជាណាចក្រថៃ វេលាព្រឹកថ្ងៃពុធទី២៤ ខែកក្កដា ឆ្នាំ២០១៩ ដែលភាគីកម្ពុជាដឹកនាំដោយ លោកឧត្តម ឧត្តមសេនីយ៍ទោ អ៊ុច សុខុន ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង និងប្រតិភូស្នងការរងនគរបាលខេត្ត រួមជាមួយនេះ ប្រតិភូស្នងការដ្ឋាននគរបាលខេត្តប៉ៃលិន ដឹកនាំដោយលោកឧត្តម ឧត្តមសេនីយ៍ទោ សេង សុគន្ធ ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តប៉ៃលិន លោក សាន ហាក់ សមាជិកក្រុមប្រឹក្សាខេត្តបាត់ដំបង លោកឧត្តមសេនីយ៍ត្រី ទី សុខា នាយរងសេនាធិការយោធភូមិភាគទី៥ និងជាប្រធានទំនាក់ទំនង ព្រំដែនកម្ពុជា ថៃ ប្រចាំខេត្តប៉ៃលិន និងលោក លោកស្រី ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ខេត្តប៉ៃលិន នាយការិយាល័យជំនាញ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក អធិការនៃអធិការដ្ឋាន នគរបាលស្រុកពាក់ព័ន្ធជាប់ព្រំដែននៃខេត្តទាំងពីរ ដែលបានធ្វើនៅស្នងការដ្ឋាននគរបាល ខេត្តច័ន្ទបុរី នៃព្រះរាជាណាចក្រថៃ ដែលសរុបរួមទាំងអស់ប្រមាណ៦០នាក់ ទាំងពីរភាគី បានចូលរួមដើម្បីបំពេញភារកិច្ចរួមសហការប្រជុំពង្រឹងសម្ព័ន្ធមេត្រីភាពជាមួយភាគីថៃ ដឹកនាំ និងរៀបចំដោយលោកឧត្តមសេនីយ៍ត្រី វឌ្ឍនា យីជិន ស្នងការនគរបាលខេត្តច័ន្ទបូរី ។

ភាគីទាំងពីរ បានលើកយកចំណុចសំខាន់ៗមករួមគ្នាពង្រឹងកិច្ចសហប្រតិបត្តការបន្ថែមទៀតមាន៦ចំណុចគឺ៖

១- បញ្ហាពលករចេញចូលឆ្លងដែនខុសច្បាប់ ដោយចៀសវាងមិនប្រើអំពើហិង្សាចំពោះអ្នកខុសច្បាប់ឡើយ ហើយរួមសហការគ្នាស្រាវជ្រាវរកមេខ្យល់ដែលនាំពលករចូល ហើយគ្មានការងារធ្វើ និងចាប់មេខ្យល់ឲ្យ មកទទួលខុស

ត្រូវការខូចខាតរបស់ពលករ និងជួយរៀបចំពលករកំពុងមានខុសច្បាប់នៅក្នុងស្រុកថៃ ឲ្យត្រឹមត្រូវស្របច្បាប់បន្ថែមទៀត ។

២-ទប់ស្កាត់ការជួញដូរគ្រឿងញៀន និងអាវុធជាតិផ្ទុះ បានរួមសហការកម្រិតខេត្ត ជំរុញការជួបផ្លាស់ប្តូរព័ត៌មានរវាងអធិការនៅជាប់ព្រំដែនគ្នាឲ្យបានញឹកញាប់ បន្ថែមទៀត។

៣-បន្តរួមសហការបង្ការ បង្រ្កាបឧក្រិដ្ឋកម្មឆ្លងដែន និងរូបីយប័ណ្ណ ក្លែងក្លាយ គ្រប់រូបភាពកុំឲ្យកើតមាន ។

៤-ការល្បាតតាមខ្សែបន្ទាត់ព្រំដែន ដើម្បីបង្ការ បង្រ្កាបទំនិញគេចពន្ធ និងទង្វើខុសច្បាប់ផ្សេងៗ។

៥-បញ្ហាចោរកម្មរថយន្ត និងទោចក្រយានយន្ត រួមសហការ និងទទួលព័ត៌មានពីប្រជាពលរដ្ឋទាំងសងខាងស៊ើបអង្កេតឲ្យច្បាស់លាស់តាមចាប់ក្រុមប្រព្រឹត្តបទល្មើស ក្នុងខេត្តជាប់ព្រំដែនរួមគ្នាមកផ្តន្ទាទោសតាមច្បាប់ ។

៦-ការលបលួចកាប់ឈើតាមព្រំដែន នៃខេត្តទាំងបី បាត់ដំបង ប៉ៃលិន និងច័ន្ទបុរី តាមដានរកមេខ្យល់ជំរុញមក ពេលចាប់បានចៀសវាងការប្រើអំពើហិង្សា បាញ់សម្លាប់ជាដើម។

អង្គពិធីបានឯកភាពរៀបចំបន្ថែមក្រុមលេខាដ្ឋាន ត្រូវបង្កើតមជ្ឈមណ្ឌលផ្លាស់ប្តូរ ព័ត៌មានបន្ថែមទៀត តាមគោលដៅសំខាន់ៗ ដើម្បីផ្លាស់ប្តូរព័ត៌មានឲ្យបានកាន់តែលឿន ឆាប់រហ័ស រក្សាសុខសន្តិភាពជូនប្រជាពលរដ្ឋទាំងសងខាងកុំឲ្យជួបការភ័យខ្លាច៕ ដោយ ៖ ហួត សុងហាក់

## ប្រពន្ធឈឺ ប្តីចេញរកប្រាក់ព្យាបាល ត្រូវមេខ្យល់បោះចោលក្នុងព្រៃ វិលមកវិញ ប្រពន្ធស្លាប់

http://nokorwatnews.com/archives/ 25-07-2019

ប៉ោយប៉ែត៖ ពិតជាសង្វេគ បុរសកម្សត់ម្នាក់ដាច់ចិត្តទុកកូនស្រី និងប្រពន្ធមានជំងឺប្រចាំកាយនៅនឹងផ្ទះដើម្បីចេញទៅប្រទេសថៃ តាមរយៈមេខ្យល់ ស្វែងរកប្រាក់មកព្យាបាលប្រពន្ធ តែអកុសលវិលត្រឡប់មកវិញឃើញតែធាតុនៅនឹងវត្ត ។

តាមការបេកស្រាយបុរសជាប្តីឈ្មោះឌី ចិន អាយុ៣៥ឆ្នាំ រស់នៅក្នុងភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ប្រាប់តាមទូរសព្ទ័នៅព្រឹកថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩នេះថា ប្រពន្ធរបស់គាត់មានឈ្មោះ ថា អាយុ២៧ឆ្នាំ មានស្រុកកំណើតនៅក្នុងខេត្តព្រៃវែង ។ បុរសកម្សត់រៀបរាប់ថា បានប្រពន្ធគាត់ គឺនៅទីក្រុងប៉ោយប៉ែតស្រឡាញ់គ្នាចិត្ត និងចិត្ត មិនបានរៀបការអ្វីនោះឡើយ ហើយការស្រឡាញ់គ្នាអស់រយៈជាយូរឆ្នាំមកដែរ សូម្បីតែស្រុកកំណើតខាងប្រពន្ធក៏មិនបានស្គាល់ ព្រោះតែជីវភាពប្រចាំថ្ងៃ នៅក្នុងសង្គមគ្រួសារមួយនេះ បានជាប់ចំណងនិស្ស័យកូនស្រីមួយ អាយុជាង២ខួប ឈ្មោះ ចិន ស្រីនោ ។ តែអ្វីធ្វើឲ្យមានការក្តុកក្តួលនោះ បុរសកម្សត់ខាងលើពេលប្រពន្ធធ្លាក់ខ្លួនមានជំងឺប្រចាំកាយដាច់ចិត្តទុកប្រពន្ធ និងកូនស្រីផ្ញើអ្នកស្រុក ហើយចងការប្រាក់គេចំនួន២០០០បាត ប្រាក់ថៃ ឲ្យមេខ្យល់ចេញទៅប្រទេសថៃ និងរកប្រាក់មកព្យាបាលជំងឺប្រពន្ធ ។ បន្ទាប់ពីចេញដំណើរមិនបានប៉ុន្មានថ្ងៃផង មេខ្យល់បំបរបង់ចោលក្នុងព្រៃពីរយប់ បីថ្ងៃដាច់បាយ ដាច់ទឹកវង្វេងផ្លូវ ។ ចំណែកប្រពន្ធនៅឯផ្ទះ ក៏ឈឺកាន់តែធ្ងន់ធ្ងរ ត្រូវអ្នកស្រុកដឹកយកទៅសង្គ្រោះនៅ និងមន្ទីរពេទ្យរដ្ឋមួយក្នុងក្រុងប៉ោយបែត ដោយពុំមានអ្នកមើលថែ ប្រពន្ធ ក៏ដាច់ខ្យល់ស្លាប់ចោលកូនស្រីនៅសល់តែធាតុ ។

បុរសខាងលើបន្ថែមថា ក្រោយពីមេខ្យដាក់ចោល រូបគេ និងមិត្តភក្តិ ក៏បានសម្រេចចិត្តវិលមកផ្ទះវិញ ទាំងប្រថុយប្រថាន ដើរតាមផ្លូវរថភ្លើងរហូតមកដល់ផ្សាររោងក្លើ ប្រទេសថៃ ឈមច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែតធ្វើជាកម្មកររុញរទេះមកផ្ទះវិញ មកដល់ពាក់កណ្តាលផ្លូវ ត្រូវអ្នកស្គាល់គ្នា ប្រាប់ថា ប្រពន្ធស្លាប់ ពេលនោះរន្ធត់ចិត្ត ហើយអ្នកដែលស្គាល់ប្រាប់ថា ឲ្យទៅទាក់ទងកន្លែងមូលដ្ឋានអាវុធហត្ថក្រុងទើបដឹងថា ប្រពន្ធស្លាប់មែន ដោយតាមរយៈលោក នួន នីគីដា ប្រគល់ធាតុប្រពន្ធឲ្យខ្លួនវិញ នៅព្រឹកថ្ងៃទី២៥ ខែកក្កដានេះ ដើម្បីយកទៅធ្វើបុនណ្យ ។ បុរសខាង

លើអំពាវនាវដល់ប្រជាជនមួយចំនួនផងដែរ មុនសម្រេចចិត្តទៅធ្វើការនៅប្រទេសណាមួយ ត្រូវគិតឲ្យបានល្អិតល្អន់មុនសម្រេចចិត្ត ក្រែងដូចរូបគាត់ ដែលមេខ្យល់បំបរបង់ចោលក្នុងព្រៃ ៕ នីមវណ្ណា

## មន្ត្រីទូតឃ្លាំមើលករណីពលករខ្មែរ ដែលថៃចាប់រឿងរំលោភក្មេងស្រីថៃ

https://www.postkhmer.com/ ឃុត សុភចរិយា | Publication date 25 July 2019 | 16:17 ICT

**ថៃៈ** អគ្គកុងស៊ុលកម្ពុជាប្រចាំប្រទេស ថៃ កាលពីថ្ងៃពុធ បានចាត់មន្ត្រីរបស់ខ្លួនចុះទៅខេត្តឈុនបុរី (Chon Buri) ដើម្បីជួយអន្តរាគមន៍ឃ្លាំមើលអំពីករណីពលករខ្មែរ ២ នាក់ ដែលក្រុមអាជ្ញាធរថៃនៅក្នុងខេត្តនោះចាប់ឃុំខ្លួនពាក់ព័ន្ធករណីរំលោភសេពសន្ថវៈលើកូនស្រីអ្នកជិតខាងរបស់ខ្លួនដែលជាអនីតិជអាយុ ១៣ ឆ្នាំ។

យោងតាមសេចក្ដីរាយការណ៍របស់កាសែត The Nation កម្លាំងតម្រួតថៃនៃខេត្តឈុនបុរី កាលពីថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៩ បានចាប់ខ្លួនបុរសខ្មែរ ២ នាក់ និងក្មេងប្រុសជនជាតិថៃ ២ នាក់ តាមបណ្ដឹងកុមារីរងគ្រោះ ដែលបានចោទប្រកាន់ពួកគេពីបទចាប់រំលោភនាងបានសម្រេចជាច្រើនដង និងថតជាឃ្លីបវីដេអូ យកទៅជំរិតទារប្រាក់ពីក្រុមគ្រួសាររបស់នាងចំនួន ៣ ០០០ បាត ជាថ្នូរមិនបង្ហោះឃ្លីបវីដេអូនោះ។

នាយស្នងការតម្រួតខេត្តឈុនបុរី លោក Nanthachat Supamongkol ត្រូវបានកាសែត The Nation ដកស្រង់សម្ដីថា បុរសខ្មែរដែលត្រូវបានចាប់ឃាត់ខ្លួននោះរួមមានឈ្មោះ ណាតាផាត់ នីវង្ស (Natthapat Neewong) អាយុ ២៩ ឆ្នាំ និងម្នាក់ទៀត ឈ្មោះ ឡឺត (Lert) អាយុ ១៨ ឆ្នាំ ពួកគេត្រូវបានជួលមកធ្វើការនៅក្នុងក្រុមហ៊ុនដែលមិនល្បីឈ្មោះមួយនៅក្នុងខេត្តនោះ។ ចំណែកក្មេងប្រុសជនជាតិថៃ ២ នាក់ទៀត ដែលមានអាយុ ១៦ ឆ្នាំម្នាក់ និង ១៤ ឆ្នាំម្នាក់ រួមទាំងកុមារីរងគ្រោះ មិនត្រូវបានប្រាប់អំពីអត្តសញ្ញាណនោះឡើយ ដោយសារតែអាយុរបស់ពួកគេ។ លោក Supamongkol បានបញ្ជាក់ថា៖ «ពួកគេបានសារភាពចំពោះបទល្មើសនេះហើយ នឹងត្រូវបានចោទប្រកាន់ពីបទល្មើសជាច្រើនរួមទាំងការចាប់រំលោភអនីតិជន។ ប៉ុន្តែសមត្ថកិច្ចនៅមិនទាន់បានរកឃើញវីដេអូដែលត្រូវបានគេចោទប្រកាន់ថាបានប្រើនៅក្នុងការប៉ុនប៉ងជំរិតឪពុកម្ដាយរបស់កុមារីរងគ្រោះទេ»។

យោងតាមពាក្យបណ្ដឹងរបស់កុមារីរងគ្រោះ កាលពីថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៩ ក្រុមជនសង្ស័យបានចាប់កុមារីរងគ្រោះទៅឃុំទុកនៅក្នុងបន្ទប់ជួលរបស់ពួកគេ ដោយបានដាក់ខ្នោះដៃរបស់នាង ហើយបាននាំគ្នាចាប់រំលោភលើរាងកាយនាងម្នាក់ម្ដងៗ ដោយម្នាក់ៗបានសម្រេចជាច្រើនដង។ មិនតែប៉ុណ្ណោះពួកគេបានថតជាវីដេអូឃ្លីប ដើម្បីទុកជំរិតយកប្រាក់ពីឪពុកម្ដាយរបស់នាងថែមទៀត។ ក្រុមអ្នកភូមិដែលបានតាមឃ្លាំមើលអំពីហេតុការណ៍នោះ បានទាមទារឲ្យសមត្ថកិច្ចផ្ដន្ទាទោសពួកគេដាក់ពន្ធនាគារឲ្យច្រើនឆ្នាំ។

ជុំវិញករណីនេះ អ្នកនាំពាក្យក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា លោក កេត សោផាន់ បានប្រាប់ភ្នំពេញប៉ុស្ដិ៍នៅថ្ងៃម្សិលមិញថា អគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងបាងកក បានចាត់ឲ្យមន្ត្រីទូតមួយចំនួនចុះទៅខេត្តឈុនបុរីដើម្បីឃ្លាំមើល និងជួយអន្តរាគមន៍ផ្នែកច្បាប់ដល់ពលករខ្មែរទាំង ២នោះ។ លោកថ្លែងថា៖ «រហូតមកទល់ពេលនេះ សមត្ថកិច្ចយើងនៅមិនទាន់ទទួលបានរបាយការណ៍លម្អិតជុំវិញករណីនោះនៅឡើយទេ។ អគ្គកុងស៊ុលយើងប្រចាំទីក្រុងបាងកក បានចាត់ឲ្យមន្ត្រីរបស់យើងចុះទៅកាន់ទីនោះហើយ ដើម្បីទាក់ទងស្នើសុំព័ត៌មានលម្អិតពីអាជ្ញាធរមូលដ្ឋានក្នុងតំបន់នោះ និងដើម្បីជួយអន្តរាគមន៍ផ្នែកច្បាប់ដល់ពួកគេ»៕

# ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៩

## នគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន ឃាត់ខ្លួន ស្ត្រីមេខ្យល់ ២នាក់ពាក់ព័ន្ធករណី ជួញដូរមនុស្សឆ្លងដែន

http://bayontv.com.kh/ 26/07/2019

ភ្នំពេញ៖ កម្លាំងនគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ចុះប្រតិបត្តិការស្រាវជ្រាវ សហការជាមួយអាជ្ញាធរមូលដ្ឋានខណ្ឌបឹងកេងកង បានឃាត់ខ្លួនស្ត្រីសង្ស័យ៦នាក់ ក្នុងនោះ ស្ត្រីមេខ្យល់ចំនួន២នាក់ នារីរងគ្រោះ ចំនួន០៤ នាក់(អនីតិជន០២នាក់) ពាក់ព័ន្ធករណីការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន។

ប្រតិបត្តិការនេះ ដោយមានការចង្អុលបង្ហាញពីឯកឧត្តម ឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការរងនិងជាស្នងការនគរបាលរាជធានីភ្នំពេញ សម្របសម្រួលពីលោក គុជ គឹមឡុង ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ និងដឹកនាំផ្ទាល់ដោយលោក វរៈសេនីយ៍ទោ ហួត សុភ័ក្រ្ត នាយរងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ធ្វើការឃាត់ខ្លួនស្ត្រីសង្ស័យចំនួន៦នាក់ កាលពីវេលាម៉ោង ៨:០០នាទី ព្រឹកថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ នៅចំណុចបេងវត្តមហាមន្ត្រី ផ្លូវលេខ១៧៣ សង្កាត់អូឡាំពិក ខណ្ឌបឹងកេងកង។

នគរបាលបានអោយដឹងថា ស្ត្រីសង្ស័យ០២ពាក់ព័ន្ធករណី ជួញដូរមនុស្សឆ្លងដែន ទី១. ឈ្មោះ សុខា រដ្ឋធានី ហៅ នីយ៉ា ភេទស្រី អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ លក់គ្រឿងក្រអូប និងទី២. ឈ្មោះ ថាច់ ដារី ភេទស្រី អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ មុខរបរ លក់ដូរ។ ចំណែកនារីរងគ្រោះចំនួន០៤នាក់ ក្នុងនោះ ជាអនីតិជន ចំនួន០២នាក់។ នគរបាលជំនាញ បានអោយដឹងថា មុនឈានដល់ការឃាត់ខ្លួនជនសង្ស័យ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនធ្វើការស្រាវជ្រាវ ជាច្រើនថ្ងៃ រហូតដល់ស៊ីជម្រៅ បានចុះទៅឃាត់ខ្លួនស្ត្រីសង្ស័យភ្លាមៗតែម្តង នាំមកការិយាល័យជំនាញដើម្បីធ្វើការសាកសួរ។ នគរបាលជំនាញបានបន្តអោយដឹងថា យោងតាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ ក្នុង មាត្រា ១១ បានចែងថា ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែនជនណាដែលនាំយកជន ដទៃបេញដោយមិនស្របច្បាប់ ក្នុងគោលដៅប្រគល់ ឬ នៅយកទៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំដល់១៥ (ដប់ប្រាំ) ឆ្នាំ។ ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅប្រគល់ ឬ នជននោះទៅប្រទេសផ្សេងទៀត ត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខណ្ឌ ១ ខាងលើ។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ២០ (ម្ភៃឆ្នាំ ក្នុងករណីដែល -ជនរងគ្រោះជាអនីតិជន។

– អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ។

– អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង។

យោងតាមនារីរងគ្រោះបានរៀបរាប់អោយដឹងថា មុនពេលពួកនារីរងគ្រោះសម្រេចចិត្តទៅប្រទេសចិន គឺមានស្ត្រីម្នាក់ដែលជាមេខ្យល់បានទាក់ទង និងលួងលោមថា បើប្អូនៗព្រមទៅប្រទេសចិន ពេលទៅដល់ភ្លាមនិងទទួលបានក្នុងម្នាក់៣០០០ដុល្លារអាមេរិក ហើយរាល់ការធ្វើឯកសារនិងធ្វើដំណើរ គឺមានអ្នករាប់រងទាំងអស់តែម្តង។ នារីរងគ្រោះបានបន្តទៀតថា ពេលនោះពួកនាងបានសួរថា គាត់ពុំមានលិខិតឆ្លងដែនទេ នារីមេខ្យល់ក៏បានប្រាប់ថា ពុំចាំបាច់មានលិខិតឆ្លងដែនទេគឺត្រូវធ្វើដំណើរទៅតាមច្រកព្រំដែនអន្តរជាតិបាវិត នៅពេលទៅដល់បាវិត គឺមានមេខ្យល់ម្នាក់ទៀតជាជនជាតិវៀតណាម ចាំទទួល ដើម្បីនាំឆ្លងដែនទៅប្រទេសចិន តែម្តង។

បច្ចុប្បន្នស្ត្រីមេខ្យល់ ទាំង២នាក់ ត្រូវបានកម្លាំងនគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជននាំមកសាកសួរ រួចឃុំខ្លួនបណ្ដោះអាសន្នដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធី។ចំណែកនារីរងគ្រោះទាំង០៤នាក់ ក្នុងនោះ អនីតិជនចំនួន០២នាក់ ត្រូវបាននគរបាលប្រគល់ជូនមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ៕

## ពលរដ្ឋខ្មែរម្នាក់ត្រូវទាហានថៃបាញ់ធ្លាយភ្លៅខណៈឆ្លងចូលទៅរកស្លាយឈើនៅទឹកដីថៃ

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្ដិ៍ ចេញផ្សាយ ថ្ងៃទី 26 July, 2019

ព្រះវិហារ ៖ ប្រជាពលរដ្ឋចំណាកស្រុកម្នាក់ លួចឡើងឆ្លងដែនចូលទឹកដីថៃខុសច្បាប់ ទៅរកស្លាយ ឈើប្រណិតចេញពីទឹកដីថៃ មកកម្ពុជាតែត្រូវទាហានថៃ បាញ់បណ្ដាលឲ្យរងរបួស។ ហេតុការណ៍នេះ បានកើតឡើងកាលពីវេលាម៉ោង ៣.០០នាទី យប់ទាបភ្លឺថ្ងៃសុក្រ ទី២៦ ខែកក្កដា ឆ្នាំ២០១៩ ត្រង់ចំណុចភ្នំដាច់ ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ យោងតាមប្រភពព័ត៌មានមួយដែលភ្ជាក់ងារទូទស្សន៍អាស៊ីអាគ្នេយ៍ ប្រចាំខេត្តព្រះវិហារទទួលបាន បានឲ្យដឹងថា ជនរងគ្រោះ មានឈ្មោះ ជឹម យូឡុង ភេទប្រុស អាយុ២៦ឆ្នាំ រងរបួស ដោយសារ សមត្ថកិច្ចថៃបាញ់ ត្រូវចំនួន ១គ្រាប់ចំគូទ ធ្លុះមកភ្លៅខាងឆ្វេង។ ប្រភពបន្តថា បច្ចុប្បន្នជនរងគ្រោះ ត្រូវបានក្រុមគ្រួសារសាច់ញាតិដឹកនាំយកទៅជួយសង្គ្រោះជីវិត យ៉ាងស្វាត់ៗផងដែរ៕

## ពលករខ្មែរ៩នាក់ ត្រូវសមត្ថកិច្ចថៃ ចាប់ពីបទឆ្លងដែន ខុសច្បាប់ ដោះលែងនិងបញ្ជូនមកវិញដោយ សុវត្ថិភាព

https://www.dap-news.com/archives/ ByID:117 Posted on 28 July 2019 | 09:45

**ភ្នំពេញ៖** បន្ទាប់ពីមានការសម្របសម្រួល រវាងភាគីពាក់ព័ន្ធ ពលរដ្ឋខ្មែរទាំង៩នាក់ ដែលត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួន ពីបទឆ្លងដែនខុសច្បាប់ ពុំមានលិខិត ស្នាមអ្វីទាំងអស់ ត្រូវបានដោះលែង និងជូនត្រឡប់ទៅកម្ពុជាវិញដោយសុវត្ថិភាព នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ តាមច្រកអន្តរជាតិ ប៉ោយប៉ែត។ នេះបើតាមហ្វេសប៊ុក របស់អគ្គកុងស៊ុលខ្មែរ ប្រចាំខេត្តសាកែវ។ តាមការឲ្យដឹង ពីពលករ គឺពួកគាត់បានចាញ់បោក មេខ្យល់ល្បួងឲ្យមកធ្វើការ នៅថៃដោយពុំស្របច្បាប់ ហើយក៏ត្រូវបានសមត្ថកិច្ចថៃ ចាប់ខ្លួននៅល្ងាចថ្ងៃទី២៥ កក្កដានៅស្រុកមឿង ខេត្តសាកែវ ។ ក្នុងការចាប់ខ្លួននេះ ពួកគេក៏ត្រូវបាន មន្ត្រីស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំខេត្តសាកែវ រួមមានលោកកុងស៊ុល ណុប រដ្ឋា និងលោក យន់ យ៉េន បានចុះជួយអន្តរាគមន៍ ឲ្យពួកគេមកស្រុកកំណើតវិញ ៕

## ប៉ូលីសបញ្ជូនមេខ្យល់ព្យុះនាំស្ត្រីខ្មែរឆ្លងដែនទៅបរទេសឡើងតុលាការ

http://khmer.peoplenews.asia/ ដោយ ៖ រិទ្ធី ថ្ងៃទី29 ខែ07 ឆ្នាំ2019 ម៉ោង 10:49 AM

ភ្នំពេញ៖ លោកខៀវ ផល្លា ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃអាទិត្យទី២៨ កក្កដា ឆ្នាំ២០១៩នេះ បានចាប់ផ្ដើមសាកសួរស្ត្រីខ្មែរ២នាក់ ដែលពាក់ព័ន្ធបទល្មើសនាំស្ត្រីខ្មែរឆ្លងដែនទៅប្រទេសចិន ។ យោងតាមរបាយកសរណ៍របស់នគរបាល នៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយអាជ្ញាធរមូលដ្ឋានខណ្ឌបឹងកេងកង បានឃាត់ខ្លួនស្ត្រីសង្ស័យ៦នាក់ ក្នុងនោះស្ត្រីមេខ្យល់ ចំនួន២នាក់ នារីរងគ្រោះចំនួន៤នាក់ ( អនីតិជន២នាក់ ) ពាក់ព័ន្ធករណីការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ត្រូវបានឃាត់ខ្លួន កាលពីវេលាម៉ោង៨៖០០នាទីព្រឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ នៅចំណុចរបងវត្តមហាមន្ត្រី ផ្លូវលេខ ១៧៣ សង្កាត់អូឡាំពិក ខណ្ឌបឹងកេងកង។ របាយកសរណ៍បញ្ជាក់ថា ស្ត្រីជាជនសង្ស័យ២នាក់ ពាក់ព័ន្ធករណីជួញ

ជួរមនុស្សឆ្លងដែនដែលបញ្ជូនមកតុលាការ ទី១. ឈ្មោះ សុខា វឌ្ឍនី ( ហៅ នីយ៉ា ) អាយុ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់គ្រឿងក្រអូប និងទី២. ឈ្មោះ ថាច់ ដាវី អាយុ៣០ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ដូរ។

ចំណែកនារីរងគ្រោះចំនួន៤នាក់ ក្នុងនោះ ជាអនីតិជន ចំនួន២នាក់ ត្រូវបានបញ្ជូនអោយមន្ទីរសង្គមកិច្ចគ្រប់គ្រងបណ្តោះអាសន្ន២នាក់ និង២នាក់ប្រគល់អោយគ្រួសារនាំយកទៅស្រុកកំណើតវិញ ។ មុនឈានដល់ការឃាត់ខ្លួនជនសង្ស័យ២នាក់ខាងលើ គឺកម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានធ្វើការស្រាវជ្រាវជាច្រើនថ្ងៃ ទើបឈានទៅឃាត់ខ្លួនស្ត្រីជាជនសង្ស័យភ្លាមៗតែម្តង នាំមកការិយាល័យជំនាញ ដើម្បីធ្វើការសាកសួរនាំ។

យោងតាមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ ក្នុងមាត្រា១១ បានចែងថា ការនាំយកចេញដោយមិនស្របច្បាប់ សម្រាប់នាំឆ្លងដែន ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងគោលដៅប្រគល់ ឬនាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ (ប្រាំពីរ) ឆ្នាំដល់ ១៥(ដប់ប្រាំ)ឆ្នាំ។ ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅប្រគល់ ឬ ជននោះទៅប្រទេសផ្សេងទៀត ត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខណ្ឌ១ខាងលើ។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥(ដប់ប្រាំ)ឆ្នាំ ទៅ ២០ (ម្ភៃឆ្នាំ ក្នុងករណីដែលជនរងគ្រោះជាអនីតិជន។ អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាច របស់ខ្លួនមកលើជនរងគ្រោះ។ អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង។

ពាក់ព័ន្ធករណីខាងលើនេះ បើតាមនារីរងគ្រោះ បានរៀបរាប់ឲ្យដឹងថា មុនពេលពួកនាងសម្រេចចិត្តទៅប្រទេសចិន គឺមានស្ត្រីម្នាក់ ដែលជាមេខ្យល់បានទាក់ទង និងលួងលោមថា បើប្អូនៗព្រមទៅប្រទេសចិន ពេលទៅដល់ភ្លាម និងទទួលបានលុយក្នុងម្នាក់ ចំនួន៣០០០ដុល្លារអាមេរិក ហើយរាល់ការធ្វើឯកសារ និងធ្វើដំណើរ គឺមានអ្នករ៉ាប់រងទាំងអស់តែម្តង។ នារីរងគ្រោះ បន្តទៀតថា ពេលនោះពួកនាងបានសួរថា គាត់ពុំមានលិខិតឆ្លងដែនទេ នារីមេខ្យល់ក៏បានប្រាប់ថា ពុំចាំបាច់មានលិខិតឆ្លងដែនទេ គឺត្រូវធ្វើដំណើរទៅតាមច្រកព្រំដែនអន្តរជាតិបាវិត នៅពេលទៅដល់បាវិត គឺមានមេខ្យល់ម្នាក់ទៀត ជាជនជាតិវៀតណាមចាំទទួល ដើម្បីនាំឆ្លងដែនទៅប្រទេសចិនតែម្តង។

យោងតាមកិច្ចប្រជុំរបស់អគ្គស្នងការនគរបាលជាតិកាលពីសប្តាហ៍មុន នៅក្នុងឆមាសទី១ដើមឆ្នាំ២០១៩នេះ មានអំពើជួញដូរមនុស្សចំនួន៧៨ករណីត្រូវបានសមត្ថកិច្ចបង្ក្រាបនិងចាប់ខ្លួនជនល្មើសយកមកផ្តន្ទាទោសតាមច្បាប់៕

## ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០១៩

## ឃាត់មនុស្សស្រីប្រុស៨នាក់ ពីបទផ្តល់សេវាកម្មពិសេសនៅសង្កាត់បឹងសាឡាង

http://khmeread.com/ July 30, 2019 09:10AM

ភ្នំពេញ ៖ មនុស្សស្រីប្រុស៨នាក់ ត្រូវបានសមត្ថកិច្ចចម្រុះឃាត់ខ្លួននានៅថ្ងៃទី២៩ កក្កដា ឆ្នាំ២០១៩ វេលាម៉ោង ៨ និង៣០នាទីយប់ នៅផ្ទះលេខ១៦២E០ ផ្លូវ២៧១ ក្រុម៧ ភូមិ៣ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ពីបទសញ្ចារកម្ម ។

ប៉ូលិសនិយាយថា កម្លាំងប៉ូលិសប៉ុស្តិ៍រដ្ឋបាលបឹងសាឡាង បានសហការជាមួយកម្លាំងប៉ូលិសនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដឹកនាំដោយលោកស្រី សី វណ្ណនី ព្រះរាជអាជ្ញារងសាលាដំបូងរាជធានីភ្នំពេញ បានចុះបង្ក្រាបផ្ទះលេខ១៦២E០ ផ្លូវ២៧១ ក្រុម៧ ភូមិ៣ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ដោយបានឃាត់ខ្លួនមនុស្ស៨នាក់ (ប្រុស៣នាក់) រួមជាមួយវត្ថុតាងរួមមាន ១-ស្រោមអនាម័យមិនទាន់ប្រើចំនួន២៧ស្រោម ប្រើរួចចំនួន២៣, ២-ដបកែច្នៃសម្រាប់ប្រើប្រាស់គ្រឿងញៀនចំនួន០១, ៣-ឯកសារខ្ចីលុយចំនួន០១និង ៤-ម៉ូតូចំនួន ១គ្រឿង ម៉ាកហុងដាវ៉េវ100 ពណ៌ខ្មៅពាក់ស្លាកលេខភ្នំពេញ 1FT-3308។

ក្រុមប្រតិបត្តិការបានសម្រេចបិទទីតាំងខាងលើជាបណ្តោះអាសន្ន និងជនសង្ស័យ៨នាក់ បញ្ជូនទៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃដើម្បីធ្វើការបន្ត៕

## ឃុំខ្លួនមេខ្យល់ ២នាក់ ពាក់ព័ន្ធការជួញដូរមនុស្សឆ្លងដែន ទៅកាន់ប្រទេសចិន

http://www.rasmeinews.com/ July 29, 2019, 6:12 PM

*ដោយៈសរិទ្ធ/ភ្នំពេញ* ៖ ស្រ្តីមេខ្យល់២នាក់ដែលជាប់ ពាក់ព័ន្ធនឹងការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែនទៅកាន់ប្រទេសចិន បានត្រូវចៅក្រមស៊ើបសួរសាលា ដំបូងរាជធានីភ្នំពេញ សម្រេចកាលពីរសៀលថ្ងៃទី២៩ ខែកក្កដា ឃុំខ្លួនដាក់ពន្ធនាគារ។ ស្រ្តីសង្ស័យ២នាក់មានឈ្មោះ សុខា វេជ្ជធានី ហៅនីយ៉ា អាយុ១៨ឆ្នាំ មុខរបរលក់គ្រឿងក្រអូប និងឈ្មោះ ថាច់ ដាវី អាយុ៣០ឆ្នាំ មុខរបរលក់ដូរ បានត្រូវកម្លាំងនគរបាល នៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន រាជធានីភ្នំពេញ សហការជាមួយអាជ្ញាធរមូលដ្ឋានខណ្ឌបឹងកេងកង ឃាត់ខ្លួនកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ នៅបេងវត្តមហាមន្ត្រី ផ្លូវលេខ១៧៣ សង្កាត់អូឡាំពិក ខណ្ឌបឹងកេងកង។ ក្នុងនោះសមត្ថកិច្ចបានរំដោះនារីរងគ្រោះចំនួន៤នាក់ (អនីតិជន២នាក់) ។ ប្រភពពីសមត្ថកិច្ចបានឱ្យដឹងថា មុនឈានដល់ការឃាត់ខ្លួនជនសង្ស័យ កម្លាំងនគរបាល បានស្រាវជ្រាវជាច្រើនថ្ងៃ រហូតបានចុះទៅឃាត់ខ្លួនស្រ្តីសង្ស័យភ្លាមៗនាំមកការិយាល័យជំនាញ ដើម្បីធ្វើការសាកសួរ។

នារីរងគ្រោះបានរៀបរាប់ឲ្យដឹងថា មុនពេលនារីរងគ្រោះសម្រេចចិត្តទៅប្រទេសចិន គឺមានស្រ្តីម្នាក់ដែលជាមេខ្យល់បានទាក់ទង និងលួងលោមថា បើប្អូនៗព្រមទៅប្រទេសចិន ពេលទៅដល់ភ្លាម នឹងទទួលបានក្នុងម្នាក់ ៣០០០ ដុល្លារអាមេរិក ហើយរាល់ការធ្វើឯកសារ និងធ្វើដំណើរគឺមានអ្នករ៉ាប់រងទាំងអស់។ នារីរងគ្រោះបានបន្តទៀតថា ពេលនោះពួកនាងបានសួរថា គាត់ពុំមានលិខិតឆ្លងដែនទេ។

នារីមេខ្យល់ក៏បានប្រាប់ថា ពុំចាំបាច់មានលិខិតឆ្លងដែនទេគឺត្រូវធ្វើដំណើរទៅ តាមច្រកព្រំដែនអន្តរជាតិបាវិត នៅពេលទៅដល់បាវិត គឺមានមេខ្យល់ម្នាក់ទៀតជាជនជាតិវៀតណាម ចាំទទួល ដើម្បីនាំឆ្លងដែនទៅប្រទេសចិនតែម្តង៕B/ថ្ងៃ

## ទី ៣១ ខែកក្កដា ឆ្នាំ២០១៩

## មន្ទីរទេសចរណ៍ និងគណៈកម្មាធិការសុវត្ថិភាពកុមារ រៀបចំសិក្ខាសាលាស្តីអំពី "សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ Child Safe Tourism"

http://grandnewsasia.com/ 30-07-2019

ឧត្តរមានជ័យ៖ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩នេះ លោក ឌី រ៉ាដូ អភិបាលរងខេត្ត និងជាតំណាង លោក ប៉ែន កុសល្យ អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ បានអញ្ជើញជាអធិបតីក្នុងសិក្ខាសាលាស្តីអំពី "សុវត្ថិភាព កុមារក្នុងវិស័យទេសចរណ៍ Child Safe Tourism" ដែលពិធីនេះរៀបចំដោយមន្ទីរទេសចរណ៍ និងមានការសហការពីគណៈកម្មាការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍នៃក្រសួងទេសចរណ៍ និងមានការអញ្ជើញចូលរួមពីក្រុង សង្កាត់ លោកប្រធាន អនុប្រធានមន្ទីរ ប្រតិបត្តិករទេសចរណ៍ អ្នកគ្រូ យុវជនកាកបាទក្រហម ស.ស.យ.ក សិស្សានុសិស្សសរុប ៧០នាក់។ នាឱកាសនោះ លោកអធិបតី បានលើកឡើងអំពីគោលបំណងនៃសិក្ខាសាលា ដើម្បីអោយសមាជិក សមាជិកានៃអង្គពិធីជ្រាបថា៖

-គឺដើម្បីបង្កើនការយល់ដឹង និងចូលរួមទប់ស្កាត់ពីផលប៉ះពាល់អវិជ្ជមាននៃវិស័យទេសចរណ៍

-ការការពារកុមារក្នុងឧស្សាហកម្មទេសចរណ៍ និងជាការលើកកម្ពស់សុវត្ថិភាពកុមារពីការរំលោភបំពាន និង

ការកែងប្រវ័ញ្ចផ្លូវភេទក្នុងវិស័យទេសចរណ៍ឱ្យបានល្អប្រសើរថែមទៀត។

ជាកិច្ចបញ្ចប់នៃកម្មវិធីនេះ លោក បានមានមតិផ្តាំផ្ញើរ និងណែនាំអោយមន្ទីរជំនាញ អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ចូលរួមសហការគ្នា ក្នុងការទប់ស្កាត់រាល់បទល្មើសទាំងឡាយដែលទាក់ទង់នឹងសុវត្ថិភាព កុមារក្នុងវិស័យទេសចរណ៍ ដើម្បីអោយការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពខ្ពស់ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលមានក្រសួងទេសចរណ៍ជាសេនាធិការ ។

## ជន ៣ នាក់ ត្រូវបញ្ជូនទៅតុលាការករណីបើកម៉ាស្សាបង្កប់សេវាផ្លូវភេទ

https://www.postkhmer.com/ គីម សារុំ | Publication date 31 July 2019 | 08:10 ICT

**ភ្នំពេញ:** នគរបាលនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នឹងបញ្ជូនជនសង្ស័យប្រុសស្រី ៣ នាក់ ពាក់ព័ន្ធការបើកសេវាកម្មផ្លូវភេទទៅសាលាដំបូងរាជធានីភ្នំពេញនៅថ្ងៃទី ៣១ កក្កដា នេះ ខណៈនារីរងគ្រោះ ៤ នាក់ ត្រូវប្រគល់ទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញបន្ទាប់ពីចាប់ខ្លួន នៅទីតាំងម៉ាស្សាមួយកន្លែង ក្នុងសង្កាត់បឹងសាឡាង ខណ្ឌទួលគោក កាលពីថ្ងៃទី ២៩ កក្កដា។

លោក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃ ប្រាប់ពីម្សិលមិញថា ករណីជនសង្ស័យប្រុសស្រីចំនួន ៣ នាក់ ដែលជាម្ចាស់ទីតាំងម៉ាស្សានោះត្រូវចាប់បញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី ៣១ កក្កដានេះហើយ។ ប៉ុន្តែ លោកសុំមិនប្រាប់ឈ្មោះជនសង្ស័យប្រុសស្រីទាំង ៣ នាក់នោះទេ ដោយលោកថា នេះជាកិច្ចការរបស់សមត្ថកិច្ច។ លោកបន្តថា៖ «ជនសង្ស័យទាំង ៣ នាក់នេះខាងនាយកដ្ឋានខ្ញុំបញ្ជូនពួកគេទៅតុលាការនៅថ្ងៃស្អែក (ថ្ងៃនេះ) ហើយ ដើម្បីចាត់ការតាមនីតិវិធីច្បាប់»។ លោកបន្តថា មាននារីរងគ្រោះអាយុ ១៧ ឆ្នាំ ចំនួន ៣ នាក់ ជាអនីតិជន និងស្ត្រីអាយុពេញវ័យម្នាក់។ ពួកគេត្រូវបានខាងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សប្រគល់ទៅឲ្យមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញហើយ។ រីឯខាងមន្ទីរសង្គមកិច្ចនឹងបញ្ជូនពួកគេបន្តទៅមណ្ឌលគាំពារណាមួយទៀតដើម្បីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ពួកគេ។

លោកប្រាប់ថា ប្រតិបត្តិការបង្ក្រាបទីតាំងម៉ាស្សានេះ កម្លាំងសមត្ថកិច្ចរបស់លោកសហការជាមួយអាជ្ញាធរមូលដ្ឋានដែលធ្វើឡើង នៅវេលាម៉ោង ៧ កន្លះ យប់ថ្ងៃទី ២៩ កក្កដា នៅចំណុចផ្លូវលេខ ១៦៤ ក្នុងភូមិ ១៣ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ចំពោះវត្ថុតាងក្នុងការឆែកឆេរនោះសមត្ថកិច្ចបានរកឃើញស្រោមអនាម័យប្រើរួច និងមិនទាន់ប្រើមួយចំនួន សៀវភៅកត់ត្រាអំពីចំណូលចំនួន ២ ក្បាល រួមនឹងឯកសារខ្ចីលុយមួយចំនួន និងលិខិតឆ្លងដែនរបស់ជនជាតិចិនចំនួន ១ ក្បាលទៀតផង។ លោកបានបន្ថែមថា ក្រៅពីនោះ កម្លាំងសមត្ថកិច្ចបានបន្តចុះទៅឆែកឆេរនៅក្នុងបន្ទប់ក្រោមដីស្ថិតនៅផ្ទះទីតាំងម៉ាស្សានោះដោយបានរកឃើញឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួនទៀត។ ដូច្នេះហើយលោកបានសហការជាមួយមន្ទីរប្រឆាំងគ្រឿងញៀន ដើម្បីត្រួតពិនិត្យមើល ដោយបានហៅមនុស្ស ដែលឃាត់ខ្លួនបានទាំងអស់យកមកពិនិត្យទឹកនោមទៀតដើម្បីរកសារធាតុញៀន។ លោកបញ្ជាក់ថា៖ «ចំពោះលិខិតឆ្លងដែន ១ ក្បាលនោះ យើងមិនទាន់កំណត់ច្បាស់ថាយ៉ាងណានៅឡើយទេ រង់ចាំការស្រាវជ្រាវបន្តទៀត»៕

## ក្រសួងមហាផ្ទៃ នឹងពង្រីកទីតាំងផ្តល់បណ្ណព្រំដែនដល់ពលរដ្ឋនៅខេត្តជាប់ព្រំដែនថៃ

https://www.postkhmer.com/ ម៉ុច ដារ៉ា | Publication date 31 July 2019 | 10:20 ICT

**ភ្នំពេញ:** អគ្គនាយកដ្ឋានអន្តោប្រវេសន៍បានស្នើរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបិទច្រករបៀងមួយចំនួនហើយ និងពង្រីកទីតាំង ផ្តល់បណ្ណព្រំដែនដល់ប្រជាពលរដ្ឋឲ្យបានច្រើនកន្លែងបន្ថែមទៀត ដើម្បីទប់ស្កាត់ពលករចំណាកស្រុកនិងទំនិញគេចពន្ធ។ នេះបើយោងតាមលោក សុខ ផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ។

ការដាក់ស្នើនេះធ្វើឡើងបន្ទាប់ពីកិច្ចប្រជុំពិភាក្សាលើការចេញចូលច្រកទ្វារព្រំដែន និងការប្រើប្រាស់បណ្ណព្រំដែន កាលពីព្រឹកថ្ងៃចន្ទ ទី ២៩ ខែ កក្កដា ឆ្នាំ ២០១៩ ដែលបានដឹកនាំ ដោយ លោក សុខ ផល និងមានការចូលរួមពីអនុរដ្ឋលេខាធិការ អគ្គនាយករដ្ឋបាល អគ្គស្នងការរងនគរបាលជាតិទទួលបន្ទុកការពារព្រំដែន និងអគ្គនាយករងនៃអគ្គនាយក ដ្ឋានអន្តោប្រវេសន៍នៅក្រសួងមហាផ្ទៃ។ លោកបញ្ជាក់ថា៖ «យើងជំរុញបើកច្រកទ្វេភាគីរវាងប្រទេសថៃ និងប្រទេសកម្ពុជាតាមរយៈការប្រើប្រាស់ បណ្ណព្រំដែនដែលទទួលស្គាល់ដោយផ្លូវច្បាប់ដោយប្រទេសទាំង ២ ដូច្នេះយើងជំរុញឲ្យប្រជាជន ប្រើប្រាស់ច្រកផ្លូវការដែលទទួលស្គាល់ទាំងទ្វេភាគីនៅពេលដែលយើងបើកច្រកផ្លូវការបានច្រើន ហើយយើងនឹងខិតខំបិទច្រកខុសច្បាប់»។ លោកបានឲ្យដឹងទៀតថា បណ្ណព្រំដែនគឺជាបណ្ណមួយសម្រាប់សម្រួលឲ្យប្រជាជនចេញចូលតាមខេត្តដែលនៅជាប់ជាមួយនឹងព្រំដែន។ ប៉ុន្តែលោកមិនអាចធ្វើអត្ថាធិប្បាយថា តើមានច្រករបៀងចំនួនប៉ុន្មានដែលបានដាក់ស្នើទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីបិទនោះទេ តែអគ្គនាយកដ្ឋានអន្តោប្រវេសន៍បានស្នើបិទច្រករបៀងមួយចំនួនដែលប្រជាពលរដ្ឋបាននិងកំពុងប្រើប្រាស់។ លោកថ្លែងថា៖ «ក្នុងកិច្ចប្រជុំរបស់យើង យើងបានលើកស្នើទៅសម្តេចរួចហើយ (បិទច្រករបៀង) យើង មិនទាន់កំណត់ ថាច្រកឈ្មោះមួយណា នៅឡើយទេតែយើងដឹង ហើយយើងស្នើជាគោលការណ៍សិន ហើយច្រករបៀងនេះ ក៏មាន ច្រើនដែរ ដែលបច្ចុប្បន្នប្រជាជនបាននិងកំពុងប្រើប្រាស់ដើម្បីចេញចូលរាល់ថ្ងៃ»។ លោកបានប្រាប់ឲ្យដឹងថា រាជរដ្ឋាភិបាលប្រទេសកម្ពុជា និងប្រទេសថៃបានឯកភាព បង្កើត ៤ ច្រកថ្មី ដែលក្នុងនោះ ច្រកភ្នំដីនៅខេត្តបាត់ដំបង ច្រកអន្តរជាតិស្ទឹងបត់នៅបន្ទាយមានជ័យ ដែលបាននិងកំពុង តែដំណើរការប្រើប្រាស់ ហើយអគ្គនាយកដ្ឋានអន្តោប្រវេសន៍បានកំពុងជំរុញឲ្យមានការបើកច្រកអន្តរជាតិ ២ ផ្សេងទៀត។

លោក មឿន តុលា នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សបានគាំទ្រនិងស្វាគមន៍វិធានការនេះអាចនឹងជួយកាត់បន្ថយពលករចំណាកស្រុក និងទំនិញគេចពន្ធលុះត្រាណា តែក្រសួងមហាផ្ទៃអាចទប់ស្កាត់អំពើពុក រលួយនៅតាមព្រំដែនបានផងដែរ។ លោកបញ្ជាក់ថា៖ «ការបិទច្រករបៀងវាអាចមានប្រសិទ្ធភាពដោយសារតែកន្លងមកមានការឆ្លងដែនដោយខុសច្បាប់តាមច្រករបៀង។ ក៏ប៉ុន្តែប្រសិទ្ធភាពឬយ៉ាងណាវាអាស្រ័យទៅលើការកាត់បន្ថយអំពើពុករលួយរបស់មន្ត្រីតាមច្រកព្រំដែនលុះត្រាយើងធ្វើការ សហការគ្នារវាងអាជ្ញាធរថៃនិងកម្ពុជាឲ្យបានហ្មត់ចត់ទើបយើងអាចកាត់បន្ថយបាន»។

បើយោងតាមគេហទំព័រក្រសួងមហាផ្ទៃដែលបានចុះផ្សាយកាលពីថ្ងៃចន្ទទី ២៩ ខែ កក្កដា ឆ្នាំ ២០១៩ បានឲ្យដឹងថា កិច្ចប្រជុំនេះមានគោលដៅស្តាប់របាយការណ៍ជំនាញ និងរបាយការណ៍ស្តីពីការថ្នាំងថ្នាក់ចិត្តរបស់ប្រជាពលរដ្ឋនៅ តាមតំបន់ព្រំដែនមួយចំនួន ជាពិសេសតំបន់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃដែលជួបការលំបាកក្នុងការចេញចូល ឆ្លងកាត់ព្រំដែនឲ្យបានសមស្របក្រោយពីមានការបិទច្រករបៀង ជាច្រកមិនផ្លូវការមួយចំនួនរួចមក។ គេហទំព័រដដែលនេះបានឲ្យដឹងថា ការងារសំខាន់ចំពោះមុខដែលតម្រូវឲ្យមានការដោះស្រាយក្រោយកិច្ចប្រជុំនេះមានចំនួន ០៣ រួមមាន៖ ១-ពង្រីកទីតាំងផ្តល់បណ្ណព្រំដែន ដល់ប្រជាពលរដ្ឋឲ្យបាន ច្រើនកន្លែងបន្ថែមទៀត ២-បង្កើតច្រកសំខាន់ៗមួយចំនួនឲ្យទៅជាច្រកតំបន់ជាផ្លូវការ ៣-រក្សាការចេញចូលតាម ទម្លាប់បច្ចុប្បន្នឱ្យស្ថិតក្នុងស្ថានភាពដូចប្រក្រតីមួយរយៈដដែល ដោយការដោះស្រាយតាមផ្លូវច្បាប់ជាមួយប្រទេសជិតខាងអាចចំណាយរយៈពេលយូរ។

លោក ឈុំ សុជាតិ អ្នកនាំពាក្យក្រសួងការពារជាតិបានថ្លែងកាលពីដើមខែ កក្កដា ឆ្នាំ២០១៩ ថា ក្នុងឆ្នាំ ២០១៩ ក្នុងរយៈពេលឆមាសទី១ កងយោធពលខេមរភូមិន្ទបានទប់ស្កាត់ និងបង្ក្រាបបទល្មើសផ្សេងៗសរុបបានចំនួន២៩៨១ករណី នៅតាមខ្សែបន្ទាត់ព្រំដែនក្នុងនោះនៅតាមបណ្តោយព្រំដែនកម្ពុជាថៃមានចំនួន១២៨៩ ករណី៕

# នេះហើយលទ្ធផលទទួលបានរបស់មេអណ្តើកវ័យក្មេងទាំង2

https://kohsantepheapdaily.com.kh/ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៩ ម៉ោង ១១:៥៥ យឹម ប៊ុនណាក់

រាជធានីភ្នំពេញ ៖ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ នារសៀលថ្ងៃទី២៩ ខែកក្កដា បានសម្រេចចេញដីកាឃុំខ្លួនស្ត្រីមេអណ្តើក២នាក់ ពាក់ព័ន្ធនឹងករណីនាំស្ត្រីខ្មែរបម្រុងឆ្លងដែន ដោយខុសច្បាប់ទៅរៀបការប្តីជាជនជាតិចិន ។ ការសម្រេចឃុំខ្លួនជនត្រូវចោទ គឺបន្ទាប់ពីបញ្ចប់ការស៊ើបសួរជនសង្ស័យនៅដំណាក់កាលអយ្យការ ដែលបានចោទពីប្រកាន់ពីបទនាំមនុស្សចេញសម្រាប់ឆ្លងដែនដោយមិនស្របច្បាប់ ។ ការនាំចេញដោយមិនស្របច្បាប់ សម្រាប់ឆ្លងដែន នៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមបញ្ញត្តិមាត្រា ១១ គឺជនជាប់ចោទត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ ទៅ១៥ឆ្នាំ ។

ស្ត្រីជាមេអណ្តើកទាំង២នាក់ ត្រូវបាននគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនរាជធានីភ្នំពេញ បញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៩ ក្នុងនោះម្នាក់ឈ្មោះ សុខា វឌ្ឍជានី ហៅយ៉ា អាយុ១៨ឆ្នាំ មុខរបរលក់គ្រឿងក្រអូប និងម្នាក់ទៀតឈ្មោះ ថាច់ ដាវី អាយុ៣0ឆ្នាំ មុខរបរលក់ដូរ ។ ពួកគេត្រូវបានឃាត់ខ្លួននៅមុខវត្តមហាមន្ត្រី តាមផ្លូវលេខ១៧៣ ក្នុងសង្កាត់អូឡាំពិក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ។

លោកវរសេនីយ៍ឯក កែវ ធា នាយការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនរាជធានីភ្នំពេញ បានឲ្យដឹងថា កាលពីព្រឹកថ្ងៃទី២៦ ខែកក្កដា កម្លាំងការិយាល័យរបស់លោកបានធ្វើការស្រាវជ្រាវ និងឈានដល់ឃាត់ខ្លួនស្ត្រី២នាក់ខាងលើ នៅមុខវត្តមហាមន្ត្រី ខណៈពួកគេទាំង២នាក់ កំពុងនាំស្ត្រីរងគ្រោះ ដើម្បីឆ្លងដែនតាមប្រទេសវៀតណាមបន្តទៅប្រទេសចិន ។ ជាមួយគ្នានេះ សមត្ថកិច្ចក៏បានរំដោះនិងអញ្ជើញជនរងគ្រោះ៤នាក់ទៅធ្វើការ បំភ្លឺជុំវិញអ្វីដែលពួកនាងចង់ទៅយកប្តីចិន ។

ជនរងគ្រោះម្នាក់រៀបរាប់ថា កាលពីខែមុនប្អូនជីទូតមួយឈ្មោះ យ៉ា(សុខា វឌ្ឍជានី) ដែលមានប្តីជាជនជាតិចិននិងរស់នៅប្រទេសចិន បានមក លេងស្រុកខ្មែរជួបនាង ។ ដោយឃើញជីវភាពនាងមានការខ្វះខាត គេក៏បានសួរនាងថាចង់យកប្តីចិន និងទៅរស់នៅប្រទេសចិនឬអត់ ? បើយកប្តីចិននឹងមានលុយចាយធូរធារ ហើយបើកូនកំលោះចិនគេពេញចិត្ត គេប្រគល់លុយឲ្យច្រើនៗ នាងនឹងបានលុយផ្ញើមកឪពុកម្តាយទៀតផង ។ ពេលឮថាបានប្តីចិននិងទៅរស់នៅប្រទេសចិន នាងក៏ឆ្លើយតបភ្លាមៗថាចង់ទៅ ទើបអ្វីៗសម្រេចតាមមេអណ្តើកទាំងអស់ គ្រាន់តែដំបូងមេអណ្តើកតម្រូវឲ្យនាងធ្វើលិខិតឆ្លងដែន ដើម្បីត្រៀមចាំគេនាំចេញពីស្រុកខ្មែរ ។ លុះនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ ឈ្មោះ យ៉ា បានមកស្រុកខ្មែរ និងបាននាំនាងទៅស្នាក់នៅផ្ទះសំណាក់កាពីតូល បន្ទប់លេខ១២ ជាន់ទី២ ហើយពេលនាងទៅស្នាក់នៅទីនោះ ក៏បានជួបស្ត្រីរងគ្រោះ៣ នាក់ទៀត ។ ថ្ងៃទី២៥ ខែកក្កដា ឈ្មោះ យ៉ា បាននាំពួកនាង៤នាក់ទៅដើរលេងផ្សារ និងទិញសម្លៀកបំពាក់ឲ្យគ្រប់គ្នា ដើម្បីរៀបចំខ្លួនទៅយកប្តីចិន ក្នុងនោះក៏មានឈ្មោះ ថាច់ ដាវី(ជនសង្ស័យ) ចូលរួមដែរ ។ លុះព្រឹកថ្ងៃទី២៦ ខែកក្កដា ឈ្មោះ យ៉ា បាននាំពួកនាងជិះម៉ូតូកង់បីឥណ្ឌាមក ដល់មុខវត្តមហាមន្ត្រី បម្រុងជិះរថយន្តហាយឡែនឌ័រ ចេញដំណើរទៅកាន់ប្រទេសវៀតណាម និងបន្តទៅប្រទេសចិន ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនទាំងអស់គ្នាតែម្តង ។

ចំណែកស្ត្រីរងគ្រោះ៣នាក់ទៀត ដែលមានឈ្មោះ ស៊ុម ថាវី អាយុ១៧ឆ្នាំ ឈ្មោះ ថន ចាន់ធី អាយុ១៦ឆ្នាំ និងឈ្មោះ នី ម៉ី អាយុ១៧ឆ្នាំ បាននិយាយប្រហាក់ប្រហែលជនរងគ្រោះខាងលើនេះដែរ ដូច្នេះសមត្ថកិច្ចសន្និដ្ឋានថា ជនសង្ស័យជាមេអណ្តើកទាំង២នាក់ ពិតជាបានប្រព្រឹត្តអំពើល្មើសទាក់ទិនទៅនឹងករណីនាំមនុស្សឆ្លងដែនដោយមិនស្របច្បាប់ ទើបត្រូវបានកសាងសំណុំរឿងបញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញតាមនីតិវិធី ។ ចំណែកជនរង

គ្រោះដែលចង់បានប្តីចិន សមត្ថកិច្ចប្រគល់ឲ្យអាណាព្យាបាលរបស់ពួកគេវិញ ។ ស្រ្តីមេអណ្តើកទាំង២នាក់នេះ នឹងត្រូវឃុំខ្លួននៅពន្ធនាគារជាបណ្តោះអាសន្ន ដើម្បីរង់ចាំបើកសវនាការជំនុំជម្រះទោសតាមច្បាប់ ។ (ដោយៈស្រីណា)

## សាហាវណាស់ ឃាតករថៃបាញ់ប្រហារកម្មករខ្មែរប្លន់យកលុយ ដើម្បី ទៅដោះបំណុលគេ ដោយសារ ចាញ់ល្បែងភ្នាល់ បាល់

http://khmer.peoplenews.asia/ ដោយ ៖ រិទ្ធី ថ្ងៃទី29 ខែ07 ឆ្នាំ2019 ម៉ោង 2:18 PM

ប្រទេសថៃ ៖ ឃាតករ ដៃឆៅ ជាជនជាតិថៃ បាន បាញ់ប្រហារ ទៅលើផ ពលករខ្មែរម្នាក់ដែលបម្រើការងារនៅស្ថានីយ៍ហ្គាសមួយកន្លែងនៅក្នុងប្រទេសថៃ ទាំងកណ្តាលអាធ្រាត្រ បណ្តាលឲ្យ កម្មករខ្មែរស្លាប់ នៅនឹងតុក្នុងស្ថានីយ៍ យ៉ាងអណោចអធម៌បំផុត ។អំពើបាញ់ប្រហារនេះបានកើតឡើង កាលពីពេលទៀបភ្លឺនាថ្ងៃទី២៧ខែកក្កដា ឆ្នាំ ២០១៩ត្រង់ចំណុចស្ថានីយ៍ហ្គាស LPG មួយកន្លែងក្នុងភូមិ៨ឃុំណុកអកស្រុកប៉ាក់ថុងឆៃខេត្ត នគររាជសីមាប្រទេសថៃលើកំណាត់ផ្លូវលេខ ៣០៤ ( រាជសីមា-កាប៊ីនបុរី ) ។

សមត្ថកិច្ចបានឲ្យដឹងថា នៅកន្លែងកើតហេតុគេង្កេតឃើញថាកម្មករក្នុងស្ថានីយ៍ម្នាក់ឈ្មោះ ម៉ូរ៉ូត ភេទប្រុស អាយុ ៣០ ឆ្នាំជាពលករខ្មែរត្រូវបានឃាតករបាញ់ចំក្បាល១ គ្រាប់ដែលអាវុធនេះគេនៅមិនទាន់ដឹងថាជាអាវុធប្រភេទអ្វីនោះទេដែលធ្វើអោយជនរងគ្រោះដេកដួលស្លាប់នៅក្នុងថ្លុកឈាម។ក្រោយពីសមត្ថកិច្ចថៃចុះត្រួតពិនិត្យទៅលើកាមេរ៉ាសុវត្ថិភាពរួចមកទើបដឹងថាខណៈដែលជនរងគ្រោះកំពុងអង្គុយដេកក្រាបនៅលើតុក្នុងស្ថានីយ៍នោះខ្មាន់កាំភ្លើងបានជិះម៉ូតូមកចតពីក្រោយប្រមាណ ២ ម៉ែត្រពីជនរងគ្រោះរួចបានដកកាំភ្លើងបាញ់ក្បាលពីក្រោយតែម្តងព្រមទាំងបានឆក់យកកាបូបលុយឡើងម៉ូតូជិះចេញទៅបាត់ ។

យោងតាមរូបភាព នៃសកម្មភាពខាងលើ នៅរសៀលថ្ងៃដដែលសមត្ថកិច្ចថៃបានចាប់ខ្លួនមុខសញ្ញាយកមកសាកសួរដែលជនសង្ស័យរូបនេះគឺជាកូនប្រុសរបស់តម្រួតថៃថែមទៀតផង ដោយជនរូបនេះមានឈ្មោះ សារ៉ូត វីផាត់ សារីហៅ បយ ភេទប្រុសអាយុ ២៣ ឆ្នាំព្រមទាំងបានដកហូត កូនកាំបិតដងឈើ ១លុយចំនួន៣១៨១បាតនិងម៉ូតូធ្វើសកម្មភាព១គ្រឿង ។ នៅចំពោះមុខសមត្ថកិច្ចថៃជនសង្ស័យដែលជាខ្មាន់កាំភ្លើងបានសារភាពថាកន្លងមកខ្លួនគឺជាអ្នកញៀននឹងល្បែងភ្នាល់បាល់ ដោយពេលខ្លះខ្លួនក៏បានទៅសុំលុយប្រពន្ធតែត្រូវប្រពន្ធស្តីអោយព្រមទាំងបានពោលពាក្យថា « បើចង់បានលុយ ទៅប្លន់គេទៅ » ។ជនសង្ស័យរូបនេះបានបន្តថានៅល្ងាចមុនពេលកើតហេតុខ្លួនក៏បានទៅលេងល្បែងភ្នាល់បាល់ជាធម្មតា ហើយក៏បានចាញ់អស់និងជំពាក់គេចំនួន ៤ ០០០ បាតថែមទៀត ។ បន្ទាប់មកម្ចាស់លុយក៏បានទូរស័ព្ទមកទារលុយញឹកពេក ដែលជាការរំខានបំផុតទើបខ្លួនក៏បានចូលទៅក្នុងបន្ទប់របស់លោកប៉ាដែលគាត់មានតួនាទីជាតម្រួតព្រមទាំងបានលួចយកកាំភ្លើងខ្លី ដែលគាត់ទុកចោលនៅលើក្បាលគ្រែរួចក៏ជិះម៉ូតូចេញទៅក្រៅទាំងរំលងអាធ្រាត្រដើម្បីរកធ្វើសកម្មភាព ។ នៅពេលជិះទៅដល់ស្ថានីយ៍ហ្គាសខាងលើក៏បានឃើញកម្មករស្ថានីយ៍នៅម្នាក់ឯងទើបបានពន្លត់ម៉ាសុ៊ីនម៉ូតូពីចម្ងាយ រួចដើរដឹកទៅដល់ពីក្រោយខ្នងខណៈដែលកម្មកររូបនោះកំពុងដេកលក់ដោយបានដកកាំភ្លើងបាញ់តំរង់ក្បាល ពីក្រោយរួចចុះទៅឆក់យកកាបូបលុយជិះគេចចេញទៅទាំងយប់ ដោយក្នុងកាបូបមានលុយចំនួន ៣ ០០០ បាតខ្លួនក៏បានយកទៅសងបំណុលគេទាំងយប់លុះស្អែកឡើងក៏ត្រូវប៉ូលិសចាប់ខ្លួនតែម្តង ។

ក្រោយការចាប់ខ្លួនសមត្ថកិច្ចថៃបានអះអាងថា នឹងធ្វើការកោះហៅឪពុកមកសាកសួរបន្តទៀតទោះបីជាឪពុកដែលជាតម្រួតមិនមានការពាក់ព័ន្ធ និងមិនបានដឹងរឿងនេះក៏ដោយក៏ប៉ុន្តែកាំភ្លើងខ្លីដែលជនសង្ស័យយកមកធ្វើសកម្មភាពគឺជាកាំភ្លើងរបស់ឪពុក ដោយឡែកឃាតករត្រូវបានសមត្ថកិច្ចបញ្ជូនទៅសាលាដំបូងហើយដើម្បីចាត់វិធានការតាមច្បាប់រីឯសពពលករខ្មែរ ក៏កំពុងស្រាវជ្រាវរកក្រុមគ្រួសារដើម្បីបញ្ជូនត្រឡប់មកស្រុកកំណើតវិញដែរ ៕